**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics


# សារណាបញ្ចប់ការសិក្សា

# ការរៀបចំសោភ័ណភាព និងសណ្តាប់ធ្នាប់ ខណ្ឌមានជ័យ

ស្រាវជ្រាវចាប់ផ្តើមពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី ១០ ខែសីហា ឆ្នាំ២០២៤


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ៖ លោក **សេង ហាប់**

លោក **ងុន សារ៉ាងុធ**

ណែនាំដោយ

លោក **ថោង ចន្ត្រា**



ថ្នាក់បរិញ្ញាបត្រ **រដ្ឋបាលសាធារណៈ**

ឆ្នាំសិក្សា ២០២០

ជំនាន់ទី១៧

ឆ្នាំបញ្ចប់សិក្សា ២០២៤

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# ការរៀបចំសោភ័ណភាព និងសណ្ដាប់ធ្នាប់ ខណ្ឌមានជ័យ

ស្រាវជ្រាវចាប់ផ្ដើមពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី ១០ ខែសីហា ឆ្នាំ២០២៤

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ៖ លោក **សេង ហាប់**

លោក **ខុន សារ៉ាវុធ**

ណែនាំដោយ

លោក **ថោង ចន្ត្រា**

ថ្នាក់បរិញ្ញាបត្រ **រដ្ឋបាលសាធារណៈ**

ជំនាន់ទី១៧

ឆ្នាំសិក្សា ២០២០

ឆ្នាំបញ្ចប់សិក្សា ២០២៤

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ **សេង ហាប់** និងឈ្មោះ **វុន សារ៉ាវុធ** ជានិស្សិតឆ្នាំទី៤ ថ្នាក់បរិញ្ញាបត្រផ្នែករដ្ឋបាលសាធារណៈ ជំនាន់ទី១៧ **នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** ក្នុងឆ្នាំសិក្សា ២០២០-២០២៤។ យើងខ្ញុំសូមសម្តែងនូវ កតញ្ញូតាធម៌ និងគោរពដឹងគុណយ៉ាងជ្រាលជ្រៅចំពោះៈ

| | |
|---|---|
| **លោកឪពុក គង់ សេង** | **លោកឪពុក វឿន ទុន** |
| **អ្នកម្តាយ សយ សុខហេង** | **អ្នកម្តាយ ហ៊ូ ណាវី** |

ជាកិច្ចបឋមកូនៗសូមគោរពលំឱនកាយក្រាបប្រណិប័តន៍ និងសម្តែងនូវកតញ្ញូកតវេទីតាធម៌ដ៏ខ្ពង់ខ្ពស់ចំពោះមាតាបិតារបស់កូនៗដែលបានផ្តល់កំណើត ចិញ្ចឹមបីបាច់ថែរក្សា និងអប់រំ ទូន្មានប្រៀនប្រដៅប្រកបដោយព្រហ្មវិហារធម៌ ព្រមទាំងបានជួយទំនុកបម្រុង ផ្គត់ផ្គង់គ្រប់សព្វបែបយ៉ាងរួមលើការសិក្សាទាំងផ្នែកស្មារតី និងគាំទ្រផ្នែកធនធាន ចាប់តាំងពីកុមារភាពរហូតដល់ធំពេញវ័យ រាប់ចាប់ពីបឋមសិក្សារ ហូតដល់បញ្ចប់ថ្នាក់បរិញ្ញាបត្រ ដោយជោគជ័យ។ លោកទាំងទ្វេតែងតែយកចិត្តទុកដាក់ពុះពារគ្រប់ឧបសគ្គមិនថាលំបាកប៉ុណ្ណាគឺដើម្បីផ្គូងផ្គើម ការសិក្សារបស់កូន ព្រមទាំងលះបង់នូវកម្លាំងញើសឈាមប្តូរយកប្រាក់ដើម្បីឱ្យកូនរៀនសូត្រមានអនាគត និង ការព្យាយាមប្រឹងប្រែងអស់ពីកម្លាំងកាយចិត្តក្នុងការជួយតម្រង់ទិស ឱ្យចេះយល់ដឹងពីអ្វីៗទាំងអស់ហើយបែង ចែកអ្វីជាអំពើល្អ និងអភិវឌ្ឍចរិយាសម្បត្តិឱ្យសក្តិសមជាសិស្សល្អ ពលរដ្ឋល្អ និងមានសេចក្តីថ្លៃថ្នូរក្នុងការស់នៅ ក្នុងសង្គមដោយជំហររឹងមាំ និងតស៊ូជំនះគ្រប់ឧបសគ្គក្នុងជីវិត។ កូនៗសូមសម្តែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅ ចំពោះគុណនូបការៈ យ៉ាងធំធេងបំផុតរបស់លោកទាំងពីរ ដែលគុណនូបការៈនេះធ្វើឱ្យ កូនៗមិនអាចបំភ្លេច បាននិងស្ថិតនៅដក់ជាប់ក្នុងចិត្តរបស់កូនៗជារៀងដរាប។

សូមគោរពថ្លែងអំណរគុណចំពោះ **ឯកឧត្តមសាកលវិទ្យាធិការ លុយ ចណ្ណា** ព្រមទាំងលោកលោកស្រី សាស្ត្រាចារ្យគ្រប់ផ្នែកទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចដែលបានដឹកនាំគ្រប់គ្រង បង្ហាត់បង្រៀន លះបង់កម្លាំងកាយ ប្រាជ្ញា ស្មារតីក្នុងការបណ្តុះបណ្តាលមូលធនបញ្ញាដល់យើងខ្ញុំទាំងពីរ និងបានជួយសម្របសម្រួលដល់យើងខ្ញុំឱ្យទទួលបាននូវពុទ្ធិ បទពិសោធន៍ ជាច្រើននៅក្នុងវិស័យនីតិសាស្ត្រដែលញ៉ាំងឱ្យយើងខ្ញុំអាចបញ្ចប់ការសិក្សានៅសាកលវិទ្យាល័យនេះដោយជោគជ័យ ។

សូមគោរពអរគុណដល់ លោកគ្រូ **ថោង ចន្ថា** ដែលបានដឹកនាំកែលម្អ ពន្យល់ ណែនាំ ព្រមទាំងលះបង់បង់ពេលវេលាដ៏មានតម្លៃ ដោយមិនគិតពីការនឿយហត់ផ្ទាល់ខ្លួន ជួយសម្របសម្រួល និងចង្អុលបង្ហាញផ្តល់ដំបូន្មាន និងអនុសាសន៍ល្អៗ ព្រមទាំងជួយពន្យល់អំពីវិធីសាស្ត្រក្នុងការស្រាវជ្រាវឯកសារ របៀបតាក់តែងបច្ចេកទេស និងកែប្រែចំណុចខ្វះខាត ដើម្បីធ្វើការរៀបចំសរសេរសារណាមួយនេះឱ្យ លេចចេញជារូបរាងឡើងតាំងពីចាប់ផ្តើមរហូតបានសម្រេចជាស្ថាពរប្រកបដោយជោគជ័យ។

ជាទីបញ្ចប់នេះ កូនទាំងពីរសូមបួងសួងដល់គុណបុណ្យព្រះរតនត្រ័យ និងវត្ថុសក្តិសិទ្ធិទាំងអស់ក្នុងលោកនេះឱ្យជួយបីបាច់ថែរក្សា និងប្រទានពរជ័យ បវរមហាប្រសើរជូនចំពោះលោកអ្នកមានគុណទាំងទ្វេ លោកយាយ លោកតា ព្រមទាំង ឯកឧត្តមសាកលវិទ្យាធិកា លោកជំទាវ លោក-លោកស្រីសាស្ត្រាចារ្យ បុគ្គលិកសិក្សា និងមិត្តរួមថ្នាក់ទាំងអស់ សូមបានប្រកបដោយពុទ្ធិពរ ទាំងបួនប្រការពោលគឺ អាយុ វណ្ណៈ សុខៈ ពលៈ បដិភាណៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ក្នុងរយៈពេល៤ឆ្នាំនៃការសិក្សាថ្នាក់បរិញ្ញាបត្រផ្នែក រដ្ឋបាលសាធារណៈ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច ជំនាន់ទី១៧ ឆ្នាំសិក្សា ២០២០-២០២៤ នេះយើងខ្ញុំមានសេចក្ដីសោមនស្សរីករាយ យ៉ាងក្រៃលែង ដោយបានទទួលនូវរាល់ទំនាក់ទំនង បទពិសោធន៍ថ្មីៗ និងធនធានផ្នែកបញ្ញាជាច្រើនពីសំណាក់ លោក-លោកស្រីសាស្ត្រាចារ្យគ្រប់មុខវិជ្ជាដ៏ឆ្នើមបានបង្ហាត់បង្ហាញ បង្រៀនណែនាំ ត្រួសត្រាយផ្លូវ និងផ្ដល់ ដំបូន្មានល្អៗដល់យើងខ្ញុំ។ ដើម្បីស្រាយចម្ងល់ ភាពស្មុគស្មាញ និងបន្ថែមការយល់ដឹងលម្អិតអំពីលំហូរនៃផ្នែកមួយនៃរដ្ឋបាលសាធារណៈ យើងខ្ញុំបានសម្រេចជ្រើសរើសយកប្រធានបទ **ការរៀបចំសោភ័ណភាព និងសណ្ដាប់ធ្នាប់ខណ្ឌមានជ័យ** ក្នុងការសរសេរសារណាបញ្ចប់ការសិក្សា។ ហើយនេះជាឱកាសដ៏ពិសេសមួយចំពោះយើងខ្ញុំ ដែលអនុញ្ញាតបានបញ្ចេញសមត្ថភាពដែលបានខិតខំប្រឹងប្រែងរៀនសូត្រក្នុងរយៈពេល៤ឆ្នាំកន្លងមកនេះ តាមរយៈការសរសេរសារណាបញ្ចប់ការសិក្សានេះផងដែរ។

គោលបំណងដែលយើងខ្ញុំ ជ្រើសរើសយកប្រធានបទនេះមកធ្វើ ការសិក្សាស្រាវជ្រាវដោយហេតុថាការរៀបចំសោភ័ណភាព និងសណ្ដាប់ធ្នាប់ខណ្ឌមានជ័យ មានលក្ខណៈស្មុគស្មាញ និងមិនទាន់បានយល់ជាទូលំទូលាយនៅឡើយទេ ទាំងនិស្សិតសិក្សាផ្នែករដ្ឋបាលសាធារណៈផ្ទាល់ រួមទាំងប្រជាពលរដ្ឋទូទៅផងដែរ។ ដើម្បីជួយសម្រួលលដល់ ការសិក្សាស្រាវជ្រាវដល់ប្អូនៗជំនាន់ក្រោយ យើងខ្ញុំបានព្យាយាមធ្វើការស្រាវជ្រាវប្រធានបទនេះតាមលទ្ធភាព ដែលអាចធ្វើទៅបាន ដោយបានស្វែងរកឯកសារពាក់ព័ន្ធសំខាន់ៗមករៀបចំចងក្រងតម្កល់ទុកឱ្យនិស្សិតជំនាន់ ក្រោយធ្វើការសិក្សា និងស្វែងយល់ក៏ដូចជាយើងខ្ញុំផ្ទាល់បានបញ្ចេញសមត្ថភាពឱ្យអស់ពីលទ្ធភាពក្នុងការពង្រីកបន្ថែមនូវពុទ្ធិផ្នែក រដ្ឋបាលសាធារណៈនិងពង្រឹងសមត្ថភាពឱ្យបានទូលំទូលាយ។ ចំពោះកិច្ចការស្រាវជ្រាវនេះ ជាសមិទ្ធិផលដ៏ មានតម្លៃដែលយើងខ្ញុំបានប្រឹងប្រែង ព្យាយាមទាំងកម្លាំងកាយកម្លាំងប្រាជ្ញាស្មារតី ជម្នះនូវរាល់ឧបសគ្គផ្សេងៗ បានដោយរលូន។ ទោះជាយ៉ាងណាក្ដី ការសរសេរសារណាមួយនេះប្រាកដអាចមានចំណុចខ្វះខាតជាក់ជាពុំខាន អាស្រ័យហេតុនេះយើងខ្ញុំ សូមមេត្តាយោគយល់អធ្យាស្រ័យអភ័យទោសទុកជាមុនពីសំណាក់លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ មិត្តអ្នកអាននានា ក្នុងករណីកិច្ចការស្រាវជ្រាវនេះមានកំហុសឆ្គងណាមួយទាំងខ្លឹមសារ និងអក្ខរាវិរុទ្ធិ ឬចំណុចផ្សេងៗដោយអចេតនាក្នុងស្នាដៃស្រាវជ្រាវមួយនេះ។ ជាចុងក្រោយយើងខ្ញុំរង់ចាំទទួលការរិះគន់ និងការកែលម្អ ពីសំណាក់មិត្តអ្នកអាន អ្នកស្រាវជ្រាវ លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ មិត្តរួមជំនាន់ និងប្អូនៗជំនាន់ក្រោយ រាល់កំហុសឆ្គងដែលកើតមានដោយប្រការណាមួយ ។

យើងខ្ញុំទាំងពីរមានសេចក្ដីសោមនស្សរីករាយ ក្នុងការទទួលមតិរិះគន់ក្នុងន័យស្ថាបនាពីគ្រប់មជ្ឈដ្ឋាន និងផ្ដល់យោបល់ផ្សេងៗ ដើម្បីកែលម្អចំណុចខ្វះខាតនៃអត្ថបទស្រាវជ្រាវមួយនេះ ឱ្យមានលក្ខណៈល្អប្រសើរជាងមុនបន្ថែមទៀតដោយក្ដីរីករាយបំផុត។

# មាតិកា

**ទំព័រ**

**សេចក្ដីផ្ដើម** ........ ១

**ជំពូកទី១**

**សញ្ញាណទូទៅនៃការរៀបចំខណ្ឌមានជ័យ**

**១.១. ទិដ្ឋភាពទូទៅ** ........ ៣

១.១.១. ទីតាំងភូមិសាស្ត្រ ........ ៣

១.១.១.១. ប្លង់គោល ........ ៣

១.១.១.២. ស្ថានភាពសេដ្ឋកិច្ចនិងសង្គមកិច្ច ........ ៥

១.១.២ ដង់ស៊ីតេប្រជាជន ........ ៦

**១.២. ក្រុមប្រឹក្សា និងគណៈអភិបាលខណ្ឌ** ........ ៦

១.២.១.ក្រុមប្រឹក្សា ........ ៨

១.២.១.១. សមាសភាពក្រុមប្រឹក្សាខណ្ឌ ........ ៩

១.២.១.២. តួនាទីក្រុមប្រឹក្សាខណ្ឌ ........ ១០

១.២.២. គណៈអភិបាលខណ្ឌ ........ ១៣

១.២.២.១ សមាសភាពអភិបាលនៃគណៈអភិបាលខណ្ឌ ........ ១៤

១.២.២.២. តួនាទីគណៈអភិបាលខណ្ឌ ........ ១៤

**១.៣. កត្តាដែលជំរុញឱ្យមានការរៀបចំខណ្ឌ** ........ ១៦

១.៣.១. កំណើនប្រជាជន ........ ១៧

១.៣.២. គមនាគមន៍ ........ ១៨

១.៣.៣. ភាពក្រីក្រ ........ ១៨

**ជំពូកទី២**

**ការរៀបចំសោភ័ណភាព និងសណ្ដាប់ធ្នាប់ខណ្ឌមានជ័យ**

**២.១. ការរៀបចំសោភ័ណភាពខណ្ឌមានជ័យ** ........ ២០

២.១.១.សោភ័ណភាពពេលថ្ងៃ ........ ២១

២.១.២. ការរៀបចំសោភ័ណភាពពេលយប់ ........ ២១

**២.២. ការរៀបចំសណ្ដាប់ធ្នាប់** ........ ២២

២.២.១. សន្តិសុខ ........ ២២

២.២.២. ភាពស្ងប់ស្ងាត់ ........ ២៥

២.២.៣. ផាសុកភាព ........ ២៥

២.២.៤. ផ្លូវគមនាគមន៍......២៥
២.២.៥. សំណង់......២៨
២.២.៦. ការរៀបចំបរិស្ថាននិងការគ្រប់គ្រងសំណល់ក្នុងខណ្ឌមានជ័យ......៣១

## ជំពូកទី៣
## បញ្ហាប្រឈម និងដំណោះស្រាយ

**៣.១.បញ្ហាប្រឈម**......៣៣
៣.១.១. ធនធានមនុស្ស......៣៣
៣.១.២. គម្រោងថវិការ......៣៣
៣.១.៣. កង្វះបច្ចេកទេស......៣៤
៣.១.៤. ការបង្កឱ្យមានការកកស្ទះចរាចរណ៍......៣៤
**៣.២. ដំណោះស្រាយ**......៣៥
៣.២.១ ការសហការពីប្រជាពលរដ្ឋ......៣៦
៣.២.២.ការកាត់បន្ថយការកកស្ទះចរាចរណ៍......៣៦
**សេចក្តីសន្និដ្ឋាន**......៣៩
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

ក្រោយពីបញ្ចប់សង្គ្រាមស៊ីវិលនៅកម្ពុជាតាមរយៈការអនុវត្តដោយជោគជ័យនូវ នយោបាយ ឈ្នះ ឈ្នះ របស់សម្តេចតេជោ ហ៊ុន សែន អតីតនាយករដ្ឋមន្ត្រី ដែលនាំមកនូវ សុខសន្តិភាព និងការផ្សះផ្សារជាតិជូនមាតុភូមិកម្ពុជារហូតមកដល់បច្ចុប្បន្ន។ ក្រោមម្លប់សន្តិភាព រយៈពេលជាង២០ឆ្នាំមកនេះ ប្រទេសកម្ពុជាទាំងមូលមានការអភិវឌ្ឍយ៉ាងលឿនស្ទើរតែគ្រប់វិស័យគួរឲ្យកត់សម្គាល់ មុនពេលឆ្លងរីករាលដាលជាសកលនៃជំងឺកូវីដ-១៩ គឺកម្ពុជាស្ថិតនៅក្នុងចំណោមប្រទេសដែលកំណើនសេដ្ឋកិច្ចខ្ពស់ ទាំងនៅក្នុងតំបន់ និងលើសកលលោក ជាមួយនិងអត្រាកំណើនជាមធ្យមប្រមាណ ៧% ក្នុងមួយឆ្នាំ។ កំណើនដ៏ខ្ពស់នេះ បានធ្វើឱ្យកម្ពុជាប្រែក្លាយ ពីប្រទេសក្រីក្របាតដៃទទេកាលពីជាង ៤០ឆ្នាំមុន ទៅជាប្រទេសមានចំណូលមធ្យមកម្រិតទាបនៅឆ្នាំ២០១៥ នឹងបន្តឱ្យទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០ខាងមុខ។

មកដល់បច្ចុប្បន្ននេះយើងសង្កេតឃើញថា រាជធានីភ្នំពេញបេះដូងនៃប្រទេសកម្ពុជាមានរីកចម្រើនយ៉ាងខ្លាំងប្រសិនបើប្រៀបធៀបទៅនឹងអតីតកាល។ រាជធានីភ្នំពេញ សព្វថ្ងៃនេះមានការអភិវឌ្ឍយ៉ាងឆាប់រហ័សលើគ្រប់វិស័យ ជាពិសេសនោះគឺ ទៅលើវិស័យនគរូបនីយកម្មតែម្តង។ សំណង់ អាគារធំៗ ខ្ពស់ៗ ស្ពាន ជាច្រើនបានកំពុងនឹងលេចរូបរាងឡើងជាបន្តបន្ទាប់។ ជាក់ស្តែងនៅក្នុងខណ្ឌមានជ័យ ផ្នែកហេដ្ឋារចនាសម្ព័ន្ធគឺមានការមមាញឹក កសាងផ្លូវថ្នល់ ស្ពាន និងស្ពានអាកាសខ្វាត់ខ្វែងជាច្រើនដើម្បីជួយសម្រួលឲ្យប្រជាពលរដ្ឋមានភាពងាយស្រួល លឿននិងឆាប់រហ័ស កាត់បន្ថយការកកស្ទះចារចរ ក្នុងការធ្វើដំណើរ។ បន្ថែមពីលើនេះទៅទៀត ស្ថានភាពផ្លូវគមនាគមន៍ក៏មានភាពល្អប្រសើរជាងមុន ផ្លូវដើរត្រូវបានជំនួសដោយផ្លូវក្រាលដោយកៅស៊ូ និងស៊ីម៉ង់ត៍ ចំពោះទំហំនៃផ្លូវថ្នល់ក៏ត្រូវបានពង្រីកផងដែរ។

ទន្ទឹមនឹងការអភិវឌ្ឍដ៏ឆាប់រហ័សនេះ គឺតែងតែផ្តល់នូវផលអវិជ្ជមាន និង ផលវិជ្ជមានជាច្រើនដូចជាផ្តល់ផលប្រយោជន៍រួមដល់ប្រទេសជាតិ កំណើនភ្ញៀវទេសចរជាតិ និងអន្តរជាតិ និងកើនឡើងនូវចំណូលថវិកាជាតិ។ ចំណែកឯផលអវិជ្ជមានវិញ បញ្ហាមួយចំនួនក៏បានលេចចេញឡើងជាមួយផងដែររួមមាន បញ្ហាកកស្ទះចរាចរណ៍ ប្រព័ន្ធលូ ផ្លូវថ្នល់ សំណង់អាគារ ការបំពុល ជាដើម។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ដោយសង្កេតឃើញថាក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ខណ្ឌមានជ័យមានការរីកចម្រើនយ៉ាងខ្លាំងទាំងការអភិវឌ្ឍ និងការគ្រប់គ្រង។ ដូចនេះការស្រាវជ្រាវលើប្រធានបទ៖ **ការរៀបចំសោភ័ណភាព និងសណ្តាប់ធ្នាប់ខណ្ឌមានជ័យ** នេះត្រូវធ្វើឡើងដើម្បីឆ្លើយតបទៅនឹងសំណួរដូចខាងក្រោម៖

- តើកត្តាអ្វីខ្លះជាមូលហេតុចាំបាច់ក្នុងការរៀបខណ្ឌ?
- តើកត្តាអ្វីខ្លះជាមូលហេតុចាំបាច់ក្នុងការរៀបចំសណ្តាប់ធ្នាប់ និងសោភ័ណភាព?
- តើការរៀបចំទាំងនេះផ្តល់ផលប្រយោជន៍ និង ផលវិបាកអ្វីខ្លះ?

## ៣. គោលបំណងនៃការសិក្សាស្រាវជ្រាវ

ការស្រាវជ្រាវខាងលើនេះ គឺមានគោលបំណងក្នុងការចែករំលែកនូវចំណេះដឹងថ្មីមួយទៀតសម្រាប់ជាជំនួយដល់សិស្សនិស្សិតជំនាន់ក្រោយ និងបុគ្គលដែលមានបំណងចង់ស្វែងយល់ពីចំណេះដឹងទូទៅពាក់ព័ន្ធផែនការយុទ្ធសាស្ត្រក្នុងការរៀបចំខណ្ឌមានជ័យនិងចង់បង្ហាញពី សមិទ្ធផលដែលទទួលបានក្រោយការរៀបចំសណ្ដាប់ធ្នាប់រួចនៅក្នុងខណ្ឌមានជ័យ។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ចំពោះការស្រាវជ្រាវទៅលើប្រធានបទមួយនេះ គឺយើងខ្ញុំបានផ្ដោតសំខាន់ទៅលើការរៀបចំខណ្ឌឱ្យមានរបៀបរៀបរយ ទាំងសោភ័ណភាព និងសណ្ដាប់ធ្នាប់ក្នុងខណ្ឌមានជ័យ ស្ថិតនៅក្នុងរាជធានីភ្នំពេញតែមួយប៉ុណ្ណោះ ពុំមានវិសាលភាពធំធេងលើសពីនេះទេ។ ចំពោះការស្រាវជ្រាវរៀបចំឡើងតាមរយៈការ ប្រមូលឯកសារបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធទៅនឹងប្រធានបទខាងលើដើម្បីសរសេរចងក្រងជាសារណា។

## ៥. សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ

ប្រធានបទខាងលើ ពិតជាមានសារៈសំខាន់ខ្លាំងណាស់ចំពោះ សិស្សានុសិស្ស និស្សិត មិត្តអ្នកអាន អ្នកស្រាវជ្រាវ សាធារណៈជននិងមិត្តជំនាន់ក្រោយទុកស្វែងយល់បន្ថែមដើម្បីជាជំនួយទៅដល់ការសិក្សានិង មានការយល់ដឹងពីយុទ្ធសាស្ត្រ និងនីតិវិធីមួយចំនួនក្នុងការរៀបចំសោភ័ណភាព និងសណ្ដាប់ធ្នាប់ខណ្ឌមានជ័យ។

## ៦. វិធីសាស្ត្រស្រាវជ្រាវ

វិធីនៃការស្រាវជ្រាវប្រធានបទនេះ គឺយើងខ្ញុំទាំងពីរបានធ្វើការពិភាក្សាមតិយោបល់ និងទទួលបានការចង្អុលបង្ហាញពីសំណាក់ **លោកគ្រូ ថោង ចន្ត្រា** ពាក់ព័ន្ធទៅនឹងឯកសារនានាដែលមាននៅក្នុងបណ្ណាល័យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច នៅសាលាខណ្ឌមានជ័យផ្ទាល់ និងនៅលើប្រព័ន្ធអ៊ិនធើណិត។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

សារណាបញ្ចប់ការសិក្សាមួយនេះ យើងខ្ញុំបានបែងចែកចេញជា ៣ ជំពូកគឺ៖

- **ជំពូកទី១ "សញ្ញាណទូទៅនៃការរៀបចំខណ្ឌមានជ័យ"** ៖ នៅជំពូកនេះ យើងខ្ញុំផ្ដោតសំខាន់ទៅលើ ៣ ចំណុចគឺ ទិដ្ឋភាពទូទៅ ក្រុមប្រឹក្សា និងគណៈអភិបាលខណ្ឌមានជ័យ និងកត្តាដែលជំរុញឱ្យមានការរៀបចំខណ្ឌ។
- **ជំពូកទី២ "ការរៀបចំសោភ័ណភាព និងសណ្ដាប់ធ្នាប់ខណ្ឌមានជ័យ"** ៖ នៅជំពូកនេះ យើងខ្ញុំផ្ដោតសំខាន់ទៅលើ ២ ចំណុចគឺ ការរៀបចំសោភ័ណភាពខណ្ឌមានជ័យ និងការរៀបចំសណ្ដាប់ធ្នាប់។
- **ជំពូកទី៣ "បញ្ហាប្រឈមនិងដំណោះស្រាយ"** ៖ នៅជំពូកនេះ យើងខ្ញុំផ្ដោតសំខាន់ទៅលើ ២ ចំណុចគឺ បញ្ហាប្រឈម និងដំណោះស្រាយ។

# ជំពូកទី១
# សញ្ញាណទូទៅនៃការរៀបចំ
# ខណ្ឌមានជ័យ

# ជំពូកទី១

# សញ្ញាណទូទៅនៃការរៀបចំខណ្ឌមានជ័យ

តាមការលើកឡើងរបស់មន្ត្រីរដ្ឋបាលខណ្ឌបានឱ្យដឹងថា ខណ្ឌមានជ័យបានកកើតតាំងពីសម័យអាណានិគមនិយមបារាំងមកម្ល៉េះ ដោយខាងកើតទន្លេបាសាក់មានឈ្មោះថា ឃុំច្បារអំពៅ និងខាងលិចទន្លេបាសាក់ មានឈ្មោះថា ឃុំចាក់អង្រែ។ នៅក្នុងរបបសាធារណៈរដ្ឋខ្មែរ ឃុំទាំងពីរបានផ្លាស់ប្តូរទៅជាខណ្ឌច្បារអំពៅ និងខណ្ឌចាក់អង្រែនៃក្រុងភ្នំពេញ។ តំបន់នេះបានផ្លាស់ប្តូរទៅជាសង្កាត់ច្បារអំពៅ សង្កាត់ចាក់អង្រែ សង្កាត់បឹងទំពន់ និង សង្កាត់ស្ទឹងមានជ័យ។

## ១.១. ទិដ្ឋភាពទូទៅ

### ១.១.១. ទីតាំងភូមិសាស្ត្រ

ខណ្ឌមានជ័យជាខណ្ឌមួយក្នុងចំណោមខណ្ឌទាំង១៤ របស់រាជធានីភ្នំពេញ និងត្រូវបានកំណត់ជាតំបន់អភិវឌ្ឍនៃរាជធានីភ្នំពេញក្នុងចំណោមតំបន់អភិវឌ្ឍផ្សេងទៀតដូចជាខណ្ឌច្បារអំពៅ ខណ្ឌដង្កោ ខណ្ឌពោធិ៍សែនជ័យ ខណ្ឌព្រែកព្នៅ ខណ្ឌជ្រោយចង្វារ និងខណ្ឌសែនសុខ និងជាមជ្ឈមណ្ឌលវប្បធម៌ នយោបាយ សន្តិសុខ សេដ្ឋកិច្ចសង្គមដែលមានការអភិវឌ្ឍប្រកបដោយសក្តានុពលប្រកួតប្រជែង និងនិរន្តរភាពលើគ្រប់វិស័យ។

បើតាមប្លង់គោលប្រើប្រាស់ដីខណ្ឌមានជ័យ ចក្ខុវិស័យឆ្នាំ២០៣៥ បច្ចុប្បន្នខណ្ឌមានជ័យមានព្រំប្រទល់ ផ្នែកខាងជើងជាប់នឹងខណ្ឌចំការមន ខណ្ឌទួលគោក ខណ្ឌសែនសុខ ផ្នែកខាងត្បូងជាប់នឹងខណ្ឌដង្កោ និងក្រុងតាខ្មៅ ខេត្តកណ្តាល ផ្នែកខាងលិចជាប់នឹងខណ្ឌ ពោធិ៍សែនជ័យ និងផ្នែកខាងកើតជាប់នឹងទន្លេបាសាក់។

ខណ្ឌមានជ័យមានផ្ទៃដីប្រមាណ២ ៤៩០,៤៤ហិកតា និងចែកជា៧សង្កាត់ និង៥៩ភូមិ ដូចតទៅ៖

- សង្កាត់ចាក់អង្រែលើមានលេខកូដ 120606 និងមានភូមិចំនួន៧
- សង្កាត់ចាក់អង្រែក្រោមមានលេខកូដ 120607 និងមានភូមិចំនួន៨
- សង្កាត់ស្ទឹងមានជ័យទី១មានលេខកូដ 120608 និងមានភូមិចំនួន៨
- សង្កាត់ស្ទឹងមានជ័យទី២មានលេខកូដ 120609 និងមានភូមិចំនួន៨
- សង្កាត់ស្ទឹងមានជ័យទី៣មានលេខកូដ 120610 និងមានភូមិចំនួន៦
- សង្កាត់បឹងទំពុនទី១មានលេខកូដ 120611 និងមានភូមិចំនួន១១
- សង្កាត់បឹងទំពុនទី២មានលេខកូដ 120612 និងមានភូមិចំនួន១១។

#### ១.១.១.១. ប្លង់គោល

ប្លង់គោលអភិវឌ្ឍន៍នីមួយៗ ឬប្លង់ប្រើប្រាស់ដី គឺតែងតែពិតជាមានសារៈសំខាន់ខ្លាំងបំផុតដោយសារតែប្លង់គោលជាអ្នកតម្រង់ទិសក្នុងការរៀបចំ ហើយបានបែងចែកផ្ទៃដីសម្រាប់តំបន់សំណង់ តំបន់ទេសចរណ៍ តំបន់ ឧស្សាហកម្ម តំបន់សណ្ឋាគារ កន្លែងសួនសាធារណៈ តំបន់សម្រាប់ចាក់សំរាម តំបន់សាលារៀន តំបន់ដែលត្រូវ ការពារ តំបន់ដែលត្រូវអភិវឌ្ឍន៍ និង បានកំណត់ពីទំហំផ្លូវ ដើម្បីកំណត់ពីផែនការប្រើប្រាស់ដីធ្លី នៅក្នុងមូលដ្ឋាន ណាមួយមានភាពសមស្រប ដើម្បីជំរុញការប្រើប្រាស់ដី និងការអភិវឌ្ឍប្រកបដោយនិរន្តភាព។ សម្រាប់ផែនការ អភិវឌ្ឍន៍ក្រុងនីមួយៗត្រូវឈរលើប្លង់គោល ឬ ប្លង់គោលប្រើប្រាស់ (Master Plan) ដែលជា

ផែនការកំណត់ ចក្ខុវិស័យ និងយុទ្ធសាស្ត្ររួម សម្រាប់ការអភិវឌ្ឍរូបវ័ន្ត និងកំណត់អំពីប្រភេទប្រើប្រាស់ដី ព្រមទាំងបង្ហាញអំពី ទម្រង់ទីក្រុង បណ្ដាញហេដ្ឋារចនាសម្ព័ន្ធទីក្រុង គមនាគមន៍សំខាន់ៗនៃទីក្រុង និងការធ្វើសមាហរណកម្ម។

ក្នុងគោលដៅធានាការគ្រប់គ្រងនិងការអភិវឌ្ឍខណ្ឌមានជ័យប្រកបដោយចីរភាព គណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មរាជធានីភ្នំពេញ និងគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្ម ខណ្ឌមានជ័យ ក្រោមការគាំទ្របច្ចេកទេសដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់បានរៀបចំនូវ**ប្លង់គោលប្រើប្រាស់ដីខណ្ឌមានជ័យចក្ខុវិស័យឆ្នាំ២០៣៥**ដើម្បីជាមូលដ្ឋានក្នុងការគ្រប់គ្រង និងតម្រង់ទិសការអភិវឌ្ឍដែនដីខណ្ឌមានជ័យទាំងមូលឱ្យស្របតាមចក្ខុវិស័យគោលនយោបាយជាតិស្ដីពីការរៀបចំដែនដីនៃព្រះរាជាណាចក្រកម្ពុជា **ប្លង់គោលប្រើប្រាស់ដីរាជធានីភ្នំពេញ ឆ្នាំ២០៣៥** និងគោលនយោបាយតាមវិស័យសំខាន់ៗជាច្រើនទៀត។

យោងទៅតាមនីតិវិធី និងដំណើរការនៃការរៀបចំប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដីទីប្រជុំជន និងការរៀបចំដែនដីនគរូបនីយកម្ម ថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវអនុវត្តដូចខាងក្រោម៖

- ប្រមូល សម្រង់ ចងក្រង និងវិភាគទិន្នន័យ
- រៀបចំចក្ខុវិស័យ យុទ្ធសាស្ត្រ គំនូសប្លង់ ផែនការសកម្មភាពនិងសេចក្ដីណែនាំអនុវត្ត ការគ្រប់គ្រង ការអភិវឌ្ឍ ការអភិរក្ស និង ការសាងសង់ ព្រមទាំងរបាយការណ៍បច្ចេកទេស
- រៀបចំសិក្ខាសាលាពិគ្រោះយោបល់ ដោយមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ
- បិទផ្សាយជាសាធារណៈ នូវសេចក្ដីព្រាងចុងក្រោយនៃ ការរៀបចំប្លង់គោលប្រើប្រាស់ដីនិង ផែនការប្រើប្រាស់ដីរយៈពេល ៣០ (សាមសិប) ថ្ងៃ ដើម្បីទទួលមតិយោបល់សាធារណៈឬ ការតវ៉ាផ្សេងៗ
- ធ្វើការបូកសរុបមតិសាធារណៈក្នុងរយៈពេលមិនលើសពី ៣០(សាមសិប) ថ្ងៃ ថ្នាក់រាជធានី ខេត្ត ពិនិត្យ និងផ្ដល់ការឯកភាព។ ក្នុងករណីដែលតម្រូវឱ្យមានការកែសម្រួលសេចក្ដីព្រាងចុង ក្រោយ រយៈពេល ៣០ (សាមសិប) ថ្ងៃ ខាងលើនេះ អាចត្រូវបានបន្ថែមរយៈពេលយ៉ាងយូរ ៣០ (សាមសិប) ថ្ងៃទៀតនៃថ្ងៃធ្វើការឬស្របតាមទំហំការងារជាក់ស្ដែង។
- គណៈកម្មាធិការរៀបចំដែនដី និង នគរូបនីយកម្មថ្នាក់ខេត្ត ត្រូវត្រួតពិនិត្យ ផ្ដល់ការឯកភាព និង ធ្វើសំណើសុំសម្រេចចុងក្រោយពីគណៈកម្មាធិការរៀបចំដែនដីនគរូបនីយកម្មថ្នាក់ជាតិ ក្នុងរយៈពេលយ៉ាងយូរ ៦០(ហុកសិប)ថ្ងៃ នៃថ្ងៃធ្វើការ។ ក្នុងករណីដែលតម្រូវឱ្យមានការកែសម្រួលសេចក្ដីព្រាងចុងក្រោយរយៈពេល ៦០(ហុកសិប) ថ្ងៃ ខាងលើនេះ អាចត្រូវបានបន្ថែម ស្របតាមទំហំការងារជាក់ស្ដែង ដែលត្រូវបានកំណត់ដោយគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់ជាតិ។[1]

[1] អនុក្រឹត្យលេខ ៤២ អនក្រ.ប្រក ស្ដីពី នគរូបនីកម្ម រាជធានី ក្រុង និងទីប្រជុំជន, មាត្រា១៦

ការកែសម្រួលប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដីនៅទីក្រុងមុនពេលកំណត់ អាចប្រព្រឹត្តិទៅបានក្នុងករណីដែលមានតម្រូវការចាំបាច់សម្រាប់បម្រើផលប្រយោជន៍សារធារណៈ ឬផលប្រយោជន៍ជាតិ។[2]

**១.១.១.២. ស្ថានភាពសេដ្ឋកិច្ចនិងសង្គមកិច្ច**

ប្រជាពលរដ្ឋក្នុងខណ្ឌមានជ័យប្រកបរបរជាៈ 0.0១% ជាអ្នកប្រកបរបរផ្នែកកសិកម្ម ២.៤% ជាអ្នកប្រកបរបរផ្នែកសិប្បកម្ម និង៩៧.៥%ជាអ្នកប្រកបរបរផ្នែកសេវាកម្ម(១៩%បម្រើការងារជាមន្ត្រីរាជការ)។ ខណ្ឌមានជ័យ ជាខណ្ឌធំមួយនៃរាជធានីភ្នំពេញ នៅតាមបណ្តាសង្កាត់នីមួយៗ មានផ្សាររដ្ឋ និងផ្សារក្រមួនតូចធំជាច្រើន ក្នុងនោះដូចជា៖

- **សង្កាត់បឹងទំពុនទី១** មានផ្សារបឹងទំពុន ដែលជាផ្សារធំមួយគ្រប់គ្រងដោយរដ្ឋ ស្ថិតនៅតាមបណ្តោយផ្លូវលេខ២៧១ ផ្លូវច្រកចូលវត្តសន្សំកុសល និងមានផ្សារក្រមួនមួយកន្លែងទៀត ដោយពុំមានឈ្មោះ ស្ថិតនៅភូមិចំរើនផល ។
- **សង្កាត់បឹងទំពុនទី២** គឺមានផ្សារចំនួន២ ក្នុងនោះទី១គឺផ្សារប៉េសេ ស្ថិតតាមបណ្តោយផ្លូវលេខ៣៧១ ក្នុងភូមិក្បាលទំនប់ និងមួយទៀតជាផ្សារក្រមួនតូចល្មម ស្ថិតតាមបណ្តោយផ្លូវបេតុង ក្បែរវត្តអង្គពោធិ៍ញាណ ស្ថិតតាមបណ្តោយផ្លូវបេតុង ក្នុងភូមិត្នោតជ្រុំទី៤ ។
- **សង្កាត់ស្ទឹងមានជ័យទី១** មានផ្សារចំនួន៤ គឺផ្សារស្ទឹងមានជ័យចាស់ ស្ថិតក្រោមការគ្រប់គ្រងដោយរដ្ឋ និងផ្សារស្ទឹងមានជ័យថ្មី ជាផ្សារឯកជន ស្ថាបនា ស្ថិតតាមបណ្តោយផ្លូវលេខ២១៧ ហៅផ្លូវព្រះមុនីវ៉ែត ។ ផ្សារក្រមួនវត្តសាមគ្គីរង្សី និងផ្សារញ៉ែមហ៊ុលថ្មី ស្ថិតក្បែរវត្តសាមគ្គីរង្សី, ក្នុងភូមិទ្រា២ ។
- **សង្កាត់ស្ទឹងមានជ័យទី២** មានផ្សារក្រមួន២ គឺផ្សារក្រមួនភូមិឫស្សី ស្ថិតក្បែរវត្តអង្គពោធិ៍ញាណ ក្នុងភូមិឫស្សី១ និងផ្សារក្រមួនស្ពានដែក ស្ថិតតាមបណ្តោយផ្លូវលេខ២១៧ ក្បែរស្ពានដែកចំការដូង ។
- **សង្កាត់ស្ទឹងមានជ័យទី៣** មានផ្សារចំនួន៣ គឺផ្សារក្រមួនលូ៥ ស្ថិតនៅចំណុចស្តុបលូ៥តាមបណ្តោយផ្លូវវែងស្រេង ក្នុងភូមិដំណាក់ធំ៣ ផ្សារដីថ្មី ស្ថិតតាមបណ្តោយផ្លូវបេតុង ក្នុងភូមិដំណាក់ធំ២ និងផ្សារឯករាជ្យ៣ ស្ថិតតាមបណ្តោយផ្លូវវែងស្រេង ក្នុងភូមិដំណាក់ធំ២ ។
- **សង្កាត់ចាក់អង្រែលើ** មានផ្សារក្រមួនតូចចំនួន១ ស្ថិតក្នុងភូមិព្រែកតានូ ។
- **សង្កាត់ចាក់អង្រែក្រោម** គឺផ្សារចំនួន៤ មានផ្សារចាក់អង្រែក្រោម ដែលស្ថិតក្រោមការគ្រប់គ្រងរបស់រដ្ឋ ស្ថិតក្នុងភូមិទួលរកា និងផ្សារក្រមួនតូចៗចំនួន៣ទៀត ស្ថិតតាមបណ្តោយផ្លូវជាតិលេខ២ ក្នុងភូមិទួលរកា៣ និងភូមិព្រែកតាឡុង ។[3]

**ក. វិស័យអប់រំ**

រដ្ឋបាលខណ្ឌមានជ័យ មានគ្រឹះស្ថានសិក្សាសាធារណៈ ឯកជន និងអង្គការគ្រប់កម្រិតរួមមាន៖ វិទ្យាល័យ ចំនួន១ អនុវិទ្យាល័យ ចំនួន២ បឋមសិក្សាសាធារណៈ ចំនួន៩ បឋមសិក្សាឯកជន និងអង្គការចំនួន ១២ សាលាមត្តេយ្យដំណើរការ ចំនួន២ ថ្នាក់មត្តេយ្យក្នុងបឋម ចំនួន៥។

[2] អនុក្រឹត្យលេខ ៤២ អនក្រ.បក ស្តីពី នគរូបនីកម្ម រាជធានី ក្រុង និងទីប្រជុំជន, មាត្រា១៧

[3] https://kohsantepheapdaily.com.kh/article/723237.html

**ខ. វិស័យសុខាភិបាល**

ចំណែកឯវិស័យសុខាភិបាលវិញ មានមណ្ឌលសុខភាពរដ្ឋចំនួន២គឺៈ មណ្ឌសុខភាពស្ទឹងមានជ័យ ដែលស្ថិតនៅផ្លូវលេខ៣៦៤ ភូមិត្នោត ក្រុម១១ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ[4] និង មណ្ឌលសុខភាពចាក់អង្រែ មានទីតាំងស្ថិតនៅតាមបណ្តោយផ្លូវជាតិលេខ២ ភូមិព្រែកតាឡុង សង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានីភ្នំពេញ។[5] និង ឯកជន១ គឺ គ្លីនិកសម្ភពក្បាលថ្នល់។

**គ. វិស័យធម្មការ និងសាសនា**

ក្នុងខណ្ឌមានជ័យមានវត្តពុទ្ធសាសនាចំនួន៨គឺ វត្តចាក់អង្រែលើ វត្តចាក់អង្រែក្រោម វត្តសន្សំកុសល វត្តដំបូកខ្ពស់ វត្តសាមគ្គីរង្សី វត្តចង្ក្រានតាព្រហ្មស្ទឹងមានជ័យ វត្តពោធិ៍ញាណ វត្តនន្ទមុនី។ គ្រិស្តសាសនា៤១ ទីតាំង និងមហាយាន៣ទីតាំង។

**១.១.២ ជន់ស៊ីតេប្រជាជន**

យោងតាមលទ្ធផលជំរឿនទូទៅប្រជាជននៅកម្ពុជាឆ្នាំ២០១៩ចំនួនប្រជាជនសរុបមាន១៥.៥៥២.២២១នាក់ ក្នុងនោះប្រុសចំនួន៧.៥៧១.៨៣៧នាក់ ស្មើនឹង៤៨.៧ភាគរយ ដោយឡែកស្រីចំនួន៧.៩៨០.៣៧៤នាក់ ស្មើនឹង៥១ .៣ភាគរយ។

តាមរយៈការសិក្សា ខណ្ឌមានជ័យ មានប្រជាជននៅឆ្នាំ២០០៨ មានចំនួន១៩៤ ៦៣៦នាក់ និងនៅឆ្នាំ ២០១៩ មានចំនួន ២៥៦ ៥៧៧នាក់ ហើយតាមការព្យាករណ៍នៅឆ្នាំ២០៣៥ ប្រជាជននឹងកើនឡើងដល់ចំនួន ២៨៨ ០៥៦នាក់ ផ្អែកតាមការគណនាអត្រាកំណើនប្រចាំឆ្នាំ។

**១.២. ក្រុមប្រឹក្សា និងគណៈអភិបាលខណ្ឌ**

សមត្ថកិច្ចដែលមានសារៈសំខាន់ដែលពាក់ព័ន្ធទៅនឹងការរៀបចំខណ្ឌ គឺរដ្ឋបាលខណ្ឌដែលក្នុងនោះ មាន ក្រុមប្រឹក្សាខណ្ឌ និងគណៈអភិបាលខណ្ឌ។

យោងមាត្រា២ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវគ្រប់គ្រងតាមគោលការណ៍នៃរដ្ឋបាលឯកភាព ដើម្បីបង្កើត ជំរុញ និងធ្វើឱ្យមានចីរភាព ដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យតាមរយៈនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ។

រដ្ឋបាលឯកភាព គឺជាការរៀបចំឲ្យមានក្រុមប្រឹក្សានៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលអាចម្ចាស់ការ ក្នុងការគ្រប់គ្រង ចាត់ចែងមុខងារនិងធនធានហើយក្រុមប្រឹក្សានីមួយៗមានសមត្ថភាពសម្របសម្រួល ប្រកបដោយប្រសិទ្ធភាពនូវសកម្មភាពនៃការផ្តល់សេវាកម្ម និងការអភិវឌ្ឍដែលធ្វើឡើងដោយក្រសួង ស្ថាប័ន នៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា សំដៅឆ្លើយតបសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន។

យោងតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អនុម័តកាលពីថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ មាត្រា១៤០ បានចែងថាគណៈអភិបាលក្រុង ស្រុក ខណ្ឌមានចំនួនពីបី(០៣)រូបទៅប្រាំ

[4] បញ្ជីមូលដ្ឋានសុខាភិបាលដែលបានចុះកិច្ចព្រមព្រៀងជាមួយបេឡាជាតិរបបសន្តិសុខសង្គម សម្រាប់ផ្នែកហានិភ័យការងារ

[5] សេចក្តីជូនព័ត៌មាន ស្តីពីការដាក់មណ្ឌលសុខភាពចាក់អង្រែ ជាមន្ទីរពេទ្យសម្រាប់ពិនិត្យ ថែទាំ និងព្យាបាលអ្នកជំងឺកូវីដ ១៩

(០៥) រូប ចំនួនជាក់ ស្តែងនៃគណៈអភិបាលសម្រាប់ខេត្ត ក្រុង ស្រុក ខណ្ឌត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើ របស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។[6]ក៏ប៉ុន្តែដោយសារតម្រូវការចាំបាច់ធនធានមនុស្សរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ច សង្គម និងគុណភាពនៃជីវិតរបស់ប្រជាពលរដ្ឋ និងសក្តានុពលក្នុងការរួមចំណែកសម្រេចបាននូវចក្ខុវិស័យរបស់រាជរដ្ឋាភិបាលក្នុងគោលបំណងប្រែក្លាយកម្ពុជាឱ្យទៅជាប្រទេសដែលមានចំណូលមធ្យម និងខ្ពស់នៅឆ្នាំ២០៣០ខាងមុខ។ មាត្រា១៤០នៃច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវបានធ្វើវិសោធនកម្មដូចតទៅៈ មាត្រា១៤០ថ្មីបាន ចែងថា គណៈអភិបាលរាជធានីភ្នំពេញមានចំនួនយ៉ាងច្រើនដប់មួយ(១១)រូប។ គណៈអភិបាលខេត្តមានចំនួនពី ប្រាំពីរ(០៧) រូបទៅដប់មួយ (១១) រូប។ គណៈអភិបាលក្រុង ស្រុក ខណ្ឌ មានចំនួនពីប្រាំ (៥)រូបទៅប្រាំពីរ (៧) រូប។ ចំនួនជាក់ស្តែងនៃគណៈអភិបាលសម្រាប់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើ របស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។[7]

យោងតាមឧបសម្ព័ន្ធទី១នៃអនុក្រឹត្យលេខ១៨៣ អនក្រ.បក ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរបស់រដ្ឋបាលខណ្ឌនៃរាជធានីភ្នំពេញ បានកំណត់ពីអង្គការលេខរបស់រដ្ឋបាលខណ្ឌដូចខាងក្រោមៈ




[6] មាត្រា១៤០ នៃព្រះរាជក្រមលេខនស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

[7] ច្បាប់ស្តីពីវិសោធនកម្មមាត្រា១៤០ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌដែលត្រូវប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខនស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨

### ១.២.១.ក្រុមប្រឹក្សា

ការរៀបចំការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក និងក្រុមប្រឹក្សាខណ្ឌ ក្នុងអាណត្តិទី៤ នៅប្រទេសកម្ពុជា ត្រូវបានធ្វើឡើងនៅថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២៤។ មានគណបក្សនយោបាយចំនួន៥ ចូលរួមការបោះឆ្នោតនេះ។

ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក និងក្រុមប្រឹក្សាខណ្ឌ ត្រូវធ្វើឡើងជាអសកល មិនចំពោះ ដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ តាមវិធីជ្រើសរើសឆ្នោតជាសម្ងាត់។ អ្នកដែលមានសិទ្ធិបោះឆ្នោតនេះ មិនមែនជាប្រជាពលរដ្ឋទូទៅទេ ប៉ុន្តែគឺជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ដែលបានបោះឆ្នោតជ្រើសរើសដោយប្រជាពលរដ្ឋ ក្នុងអាណត្តិតែម្តង។

ជាគោលការណ៍ច្បាប់, រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវមានក្រុមប្រឹក្សារបស់ខ្លួន ត្រូវបានបង្កើតឡើងដោយការបោះឆ្នោតជាអសកល ស្របតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើស រើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ដែលហៅកាត់ថា «**ក្រុមប្រឹក្សា**» ដែលជាតំណាងសាធារណៈ ជាអ្នកការពារ និង ជាអ្នកបម្រើឱ្យផលប្រយោជន៍របស់ប្រជាពលរដ្ឋទាំងអស់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ក្រុមប្រឹក្សាមានអាណត្តិ៥ឆ្នាំ និង ត្រូវផុតកំណត់នៅពេលក្រុមប្រឹក្សាថ្មីចូលកាន់តំណែង ហើយអាណត្តិរបស់ក្រុមប្រឹក្សាត្រូវគិតចាប់ពីថ្ងៃបោះឆ្នោ ត ជ្រើសរើសក្រុមប្រឹក្សា និងផុតកំណត់នៅថ្ងៃបោះឆ្នោតបន្ទាប់។[8] លើសពីនេះទៅទៀតក្នុងពេល រងចាំក្រុមប្រឹក្សាថ្មីចូលកាន់តំណែង ក្រុមប្រឹក្សាដែលចប់អាណត្តិនេះមានសិទ្ធិអនុវត្តតែកិច្ចការរដ្ឋបាលប្រចាំថ្ងៃប៉ុណ្ណោះ។[9] ក្រុមប្រឹក្សាគឺជាតំណាងសាធារណៈជាអ្នកការពារ និងជាអ្នកបម្រើផលប្រយោជន៍ដល់ ប្រជាពលរដ្ឋទាំងអស់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។[10]

ក្រុមប្រឹក្សារាជធានីភ្នំពេញ និងក្រុមប្រឹក្សាខេត្ត ក្រុង ស្រុក ខណ្ឌ មានសមាជិកក្រុមប្រឹក្សា ដែលត្រូវបោះឆ្នោតជ្រើសរើសជាអសកលដោយសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ។ ចំនួនសមាជិក ក្រុមប្រឹក្សាសម្រាប់ក្រុមប្រឹក្សានីមួយៗ ត្រូវកំណត់ដោយអនុក្រឹត្យផ្អែកលើកត្តា ប្រជាសាស្ត្រ និង ភូមិសាស្ត្រ។ យោងតាមច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រង់មាត្រា ១៨ថ្មី បានកំណត់ចំនួនសមាជិកក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាខណ្ឌ ដែលសមាជិកក្រុមប្រឹក្សារាជធានីភ្នំពេញត្រូវបានបង្កើន២១រូប ទៅដល់ ២៧រូប សមាជិកក្រុមប្រឹក្សាខេត្តត្រូវបង្កើនចន្លោះពី១៥ ដល់ ២៧រូប សមាជិកក្រុមប្រឹក្សាក្រុងត្រូវបង្កើនចន្លោះពី ១១រូប ដល់២១រូប និងសមាជិកក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ត្រូវបានបង្កើនចន្លោះពី ១១ ដល់ ២១រូប។[11]

ក្រុមប្រឹក្សានីមួយៗ ត្រូវមានប្រធានម្នាក់ ដោយប្រធានគឺជាបេក្ខជនដែលស្ថិតនៅលំដាប់លេខរៀងលើគេ នៃបញ្ជីបេក្ខជនដែលមានអាសនៈច្រើនជាងគេនៅក្នុងក្រុមប្រឹក្សា។ ក្នុងករណីដែលបញ្ជីបេក្ខជនមានអាសនៈ

[8] ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ, មាត្រា២

[9] ច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ, មាត្រា១៦

[10] មាត្រា៦ នៃអនុក្រឹត្យលេខ ២១៦ អនក្រ.បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក

[11] https://www.information.gov.kh/articles/26180 សេចក្តីស្នើវិសោធនកម្មមាត្រា១៨ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

ស្មើគ្នានៅក្នុងក្រុមប្រឹក្សា ប្រធានក្រុមប្រឹក្សា ត្រូវជ្រើសរើសយកបេក្ខជន ដែលមានលេខរៀងលើគេនៃបញ្ជីបេក្ខជន ដែលមានសំឡេងឆ្នោតបានការច្រើនជាងគេ។

ចំនួនជាក់ស្តែងនៃសមាជិកក្រុមប្រឹក្សានីមួយៗ ត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ក្នុងរយៈពេលយ៉ាងតិច១២០ថ្ងៃ មុនពេលផុតកំណត់អាណត្តិរបស់ក្រុមប្រឹក្សា។ ក្នុងករណីគ្មានអនុក្រឹត្យចែងអំពីចំនួនសមាជិកក្រុមប្រឹក្សាអាណត្តិបន្ទាប់ទេនោះ ចំនួនសមាជិកសរុបរបស់ក្រុមប្រឹក្សា សម្រាប់ក្រុមប្រឹក្សានីមួយៗ ត្រូវយកតាមចំនួនសរុបចុងក្រោយ នៃក្រុមប្រឹក្សាអាណត្តិចាស់។

**១.២.១.១. សមាសភាពក្រុមប្រឹក្សាខណ្ឌ**

ដោយអនុលោមតាមមាត្រា១៨ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌសម្រាប់អាណត្តិទី៤ ខណ្ឌមានជ័យមានចំនួនសមាជិកក្រុមប្រឹក្សា២១នាក់។[12] សមាសភាពក្រុមប្រឹក្សា នីតិកាលទី៤ មានរាយនាមដូចខាងក្រោម[13]៖

| ល.រ | គោត្តនាម និងនាម | ភេទ | តួនាទី |
|---|---|---|---|
| ១ | ប្រាំង សុផល | ប្រុស | ប្រធានក្រុមប្រឹក្សា |
| ២ | អ៊ុន ចំណាប់ | ប្រុស | សមាជិកក្រុមប្រឹក្សា |
| ៣ | អែម សុខលាង | ប្រុស | សមាជិកក្រុមប្រឹក្សា |
| ៤ | តេង ស៊ីណូ | ប្រុស | សមាជិកក្រុមប្រឹក្សា |
| ៥ | លឹម បែន | ប្រុស | សមាជិកក្រុមប្រឹក្សា |
| ៦ | មុំ វៃ | ប្រុស | សមាជិកក្រុមប្រឹក្សា |
| ៧ | ហេង គុច | ប្រុស | សមាជិកក្រុមប្រឹក្សា |
| ៨ | នៅ សុនីតា | ស្រី | សមាជិកក្រុមប្រឹក្សា |
| ៩ | កៅ សុខាដាលី | ស្រី | សមាជិកក្រុមប្រឹក្សា |
| ១០ | ខេង គឹមសាន | ប្រុស | សមាជិកក្រុមប្រឹក្សា |
| ១១ | ជា ណេន | ស្រី | សមាជិកក្រុមប្រឹក្សា |
| ១២ | ច័ន្ទ សុភាព | ស្រី | សមាជិកក្រុមប្រឹក្សា |
| ១៣ | ខែម ចាន់នី | ស្រី | សមាជិកក្រុមប្រឹក្សា |
| ១៤ | ទឹង សុចិត្រា | ប្រុស | សមាជិកក្រុមប្រឹក្សា |
| ១៥ | វឿន សុខឿន | ស្រី | សមាជិកក្រុមប្រឹក្សា |
| ១៦ | ហុក ភីរ័ក្ស | ប្រុស | សមាជិកក្រុមប្រឹក្សា |

[12] មាត្រា២ នៃអនុក្រឹត្យលេខ១០អនក្រ.បក ស្តីពីការកំណត់ចំនួនសមាជិកក្រុមប្រឹក្សារាជធានីភ្នំពេញ ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ក្រុមប្រឹក្សាខណ្ឌនីមួយៗសម្រាប់ អាណត្តិទី៤

[13] https://electresult.nec.gov.kh/Council/CandidateResult/2024 យោងតាមគេហទំព័ររបស់ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អាណត្តិទី៤ ឆ្នាំ២០២៤

| | | | |
|---|---|---|---|
| ១៧ | យ៉ែម សុវណ្ណារ៉ា | ប្រុស | សមាជិកក្រុមប្រឹក្សា |
| ១៨ | វុន ស្រីម៉ៅ | ស្រី | សមាជិកក្រុមប្រឹក្សា |
| ១៩ | សន ណារ៉ាត់ | ប្រុស | សមាជិកក្រុមប្រឹក្សា |
| ២០ | អៀង ម៉ាលី | ស្រី | សមាជិកក្រុមប្រឹក្សា |
| ២១ | អៀប សារ៉ាក់ | ប្រុស | សមាជិកក្រុមប្រឹក្សា |

### ១.២.១.២. តួនាទីក្រុមប្រឹក្សាខណ្ឌ

ក្រុមប្រឹក្សាមានសិទ្ធិអំណាចធ្វើសេចក្ដីសម្រេចខាងបញ្ញត្តិ និងសេចក្ដីសម្រេចខាងប្រតិបត្តិ។ ក្រុមប្រឹក្សា ប្រើប្រាស់អំណាចបញ្ញត្តិរបស់ខ្លួនតាមរយៈការធ្វើដីកា និងប្រើប្រាស់អំណាចប្រតិបត្តិតាមរយៈការធ្វើសេចក្ដីសម្រេចនៅក្នុងអង្គប្រជុំរបស់ក្រុមប្រឹក្សា ស្របតាមក្របខ័ណ្ឌដែលកំណត់ដោយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា។

ទន្ទឹមនេះ ក្រុមប្រឹក្សាអាចស្នើជាលាយលក្ខណ៍អក្សរទៅរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដើម្បីដកហូត អភិបាល អភិបាលរងចេញពីមុខតំណែង ក្នុងករណីអភិបាល អភិបាលរងនោះមានករណីណាមួយដូច ខាងក្រោម៖

- បាត់បង់លក្ខណសម្បត្តិជាអភិបាល ឬ អភិបាលរង
- អសមត្ថភាព
- បំពេញការងារមិនបានល្អ
- មានបញ្ហាសុខភាព ឬបាត់បង់សម្បទាវិជ្ជាជីវៈ ដោយមានលិខិតបញ្ជាក់ពីស្ថាប័នមាន សមត្ថកិច្ច
- បោះបង់ចោលការងារ
- ប្រព្រឹត្តខុសឆ្គងពីក្រមសីលធម៌វិជ្ជាជីវៈ។

ក្រុមប្រឹក្សាមានតួនាទីចាត់ចែងកិច្ចការចាំបាច់នានា ដើម្បីសម្រេចនូវគោលបំណងក្នុងការបង្កើត ជំរុញ និងធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ព្រមទាំងដើម្បីបំពេញមុខងារ ដែលបាន ប្រគល់ និង/ឬ ដែលបានធ្វើប្រតិភូកម្ម ដោយមានភារកិច្ចសំខាន់ៗដូចខាងក្រោម ៖

**ក.ការងាររៀបចំកិច្ចប្រជុំក្រុមប្រឹក្សា**

ក្រុមប្រឹក្សាត្រូវប្រជុំសាមញ្ញយ៉ាងតិចចំនួន១២ដងក្នុងមួយឆ្នាំ ទៅតាមប្រតិទិនដែលបានអនុម័តដោយក្រុមប្រឹក្សា។ ក្រៅពីកិច្ចប្រជុំសាមញ្ញ ក្រុមប្រឹក្សាអាចប្រជុំវិសាមញ្ញ នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនបាន តាមការចាំបាច់។

**ខ.ការងាររៀបចំបទបញ្ជាផ្ទៃក្នុង**

ក្រោយប្រកាសចូលកាន់តំណែងក្រុមប្រឹក្សាត្រូវរៀបចំបទបញ្ជាផ្ទៃក្នុង ដើម្បីកំណត់វិធានទាំងឡាយសម្រាប់កិច្ចប្រជុំ និងរបៀបរបបធ្វើការងាររបស់ខ្លួន។ បទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សា ត្រូវធ្វើឡើងតាមទម្រង់ជាដីកា និងត្រូវអនុម័តក្នុងកិច្ចប្រជុំសាមញ្ញលើកទី២ ដែលប្រព្រឹត្តទៅមិនឱ្យមុន២៥ថ្ងៃ ឬលើសពី ៣៥ថ្ងៃ បន្ទាប់ពីកិច្ចប្រជុំសាមញ្ញលើកទី១។

**គ.ការងាររៀបចំវិធានគ្រប់គ្រងផ្ទៃក្នុង**

ក្រុមប្រឹក្សានៃអាណត្តិនីមួយៗ ត្រូវរៀបចំ និងអនុម័តដីកាស្តីពីវិធានគ្រប់គ្រងផ្ទៃក្នុង ដើម្បីធានានូវការលើកកម្ពស់ការគ្រប់គ្រងរដ្ឋបាលរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពស្របតាមគោលការណ៍ នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ។

**ឃ.ការងារដាក់ចេញដីកា និងសេចក្តីសម្រេច**

ក្រុមប្រឹក្សាអាចដាក់ចេញដីកា ដើម្បីកំណត់ ហាមឃាត់ ឬត្រួតពិនិត្យលើសកម្មភាព នីតិវិធី ឬកិច្ចការណាមួយដែលស្ថិតនៅក្នុងវិសាលភាពនៃមុខងារ និងធនធានរបស់ខ្លួន ដោយផ្អែកតាមតម្រូវការនៃច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាជាធរមាន និងឬតម្រូវការក្នុងមូលដ្ឋាន។ ទន្ទឹមនេះ ក្រុមប្រឹក្សាក៏អាច ដាក់ចេញសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាមានពីរប្រភេទ គឺ**សេចក្តីសម្រេចជាលាយលក្ខណ៍អក្សរ** និង/ឬ **ដោយផ្ទាល់មាត់** ក្នុងអង្គប្រជុំក្រុមប្រឹក្សាដោយត្រូវកត់ត្រានៅក្នុងកំណត់ហេតុនៃកិច្ចប្រជុំក្រុមប្រឹក្សា។

**ង.ការងាររៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់**

ក្រុមប្រឹក្សាត្រូវរៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់របស់ខ្លួន ក្នុងអំឡុងខែមិថុនានៃឆ្នាំនីមួយៗ ដោយត្រូវធ្វើឡើងនៅតាមសង្កាត់នានាក្នុងខណ្ឌ ក្នុងគោលបំណងផ្តល់ឱកាសឱ្យក្រុមប្រឹក្សាដើម្បីៈ

- **ផ្តល់នូវព័ត៌មាន**៖ ក្រុមប្រឹក្សារាយការណ៍អំពីសកម្មភាពរបស់ខ្លួននៅក្នុងឆ្នាំកន្លងមក និង បង្ហាញពីផែនការសម្រាប់ឆ្នាំខាងមុខ
- **ផ្តល់ប្រឹក្សា**៖ អ្នកចូលរួមពិភាក្សាអំពីលទ្ធផល ផ្តល់ព័ត៌មានត្រឡប់ដល់ក្រុមប្រឹក្សាអំពីការងារ នៅក្នុងឆ្នាំកន្លងមក និងលើកជាសំណើសម្រាប់ឆ្នាំបន្ទាប់
- **ជំរុញឱ្យមានការចូលរួម**៖ អ្នកចូលរួមអាចរួមចំណែកនៅក្នុងដំណើរការនៃការធ្វើសេចក្តី សម្រេចចិត្តដែលក្នុងនោះសំណើ និងការព្រួយបារម្ភរបស់ប្រជាពលរដ្ឋត្រូវបានលើកយកមក ពិចារណានៅក្នុងការសម្រេចចុងក្រោយរបស់ក្រុមប្រឹក្សា
- **លើកកម្ពស់ការសហការ**៖ ក្រុមប្រឹក្សាទទួលបានព័ត៌មានប្រសើរជាងមុនអំពីតម្រូវការរបស់ ប្រជាពលរដ្ឋ ហើយប្រជាពលរដ្ឋយល់ដឹងកាន់តែច្បាស់អំពីការអភិវឌ្ឍនៅមូលដ្ឋាន។ វេទិកា របស់ក្រុមប្រឹក្សាជំរុញ និងលើកកម្ពស់កិច្ចសហការគ្នារវាង ក្រុមប្រឹក្សា និងប្រជាពលរដ្ឋ។ វេទិកានេះ ចូលរួមចំណែកក្នុងការបង្កើតនូវដំណោះស្រាយ ដែលផ្តល់ផលប្រយោជន៍ ដល់ប្រជាពលរដ្ឋ។

**ច.ការងារផែនការអភិវឌ្ឍន៍ប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល**

ក្រោយប្រកាសចូលកាន់តំណែង ក្រុមប្រឹក្សាត្រូវរៀបចំ និងអនុម័តផែនការអភិវឌ្ឍន៍រយៈពេលប្រាំ (៥) ឆ្នាំ យ៉ាងយូរត្រឹមឆ្នាំទី២ នៃអាណត្តិរបស់ក្រុមប្រឹក្សា។ ផែនការអភិវឌ្ឍន៍រយៈពេលប្រាំ (៥)ឆ្នាំត្រូវធ្វើ បច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ តាមរយៈការរៀបចំកម្មវិធីវិនិយោគបី(៣)ឆ្នាំរំកិលប្រចាំឆ្នាំ។ ក្នុងការរៀបចំ ផែនការអភិវឌ្ឍន៍រយៈពេលប្រាំ (៥)ឆ្នាំ និងកម្មវិធីវិនិយោគបី(៣)ឆ្នាំរំកិលប្រចាំឆ្នាំ ក្រុមប្រឹក្សាត្រូវពិគ្រោះ យោបល់ជាមួយប្រជាពលរដ្ឋ ប្រភេទក្រុមប្រឹក្សាផ្សេង និងអ្នកពាក់ព័ន្ធនានាដោយត្រូវគោរពតាមគោល ការណ៍ដូចខាងក្រោម៖

- ការចែករំលែកព័ត៌មាន
- តម្លាភាព

- សង្គតិភាព និងសុខដុមនីយកម្ម
- ការចូលរួមពិគ្រោះយោបល់ជាទូទៅ
- ការឆ្លើយតបនឹងតម្រូវការ
- គណនេយ្យភាពតាមបែបប្រជាធិបតេយ្យ
- ប្រសិទ្ធភាព និងសុក្រឹតភាពសេដ្ឋកិច្ច និងសង្គម
- ការធានាចីរភាពធនធានធម្មជាតិ និងបរិស្ថាន
- ការធានាសមធម៌។

**ឆ.ការអនុវត្តមុខងារ**

ក្រុមប្រឹក្សាត្រូវចាត់វិធានការចាំបាច់នានាដើម្បីធានាថា រាល់មុខងារដែលផ្ទេរទៅឱ្យក្រុមប្រឹក្សារួម ទាំងមុខងារជាអាណត្តិទូទៅដែលក្រុមប្រឹក្សាបានសម្រេចជ្រើសរើសយកមកអនុវត្ត ត្រូវបានយកទៅអនុវត្ត យ៉ាងពេញលេញប្រកបដោយប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងបរិយាប័ន្ន។ ទន្ទឹមនេះ ក្រុមប្រឹក្សា ក៏ត្រូវធ្វើការតាមដានត្រួតពិនិត្យ និងផ្តល់យោបល់ការអនុវត្តមុខងារទាំងនោះ តាមរយៈការពិនិត្យ ពិភាក្សា នៅក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សា ដោយមានគណៈអភិបាលជាអ្នកធ្វើសេចក្តីរាយការណ៍ពីវឌ្ឍនភាព និង បញ្ហាប្រឈមនានាក្នុងការអនុវត្តមុខងារទាំងនោះ។

**ជ.ការងារគ្រប់គ្រងបុគ្គលិក**

ក្នុងការគ្រប់គ្រងបុគ្គលិករបស់ខ្លួននៅរដ្ឋបាលខណ្ឌ ក្រុមប្រឹក្សាត្រូវពិនិត្យ និងអនុម័តលើការងារសំខាន់ៗមួយចំនួន ដូចខាងក្រោម៖

- ការរៀបចំផែនការបុគ្គលិក
- ការតែងតាំង និងការបញ្ចប់មុខតំណែងនាយករងរដ្ឋបាល និងប្រធានការិយាល័យ ឬ ប្រធានអង្គភាពដែលមានថ្នាក់ប្រហាក់ប្រហែល និង
- ការកំណត់ប្រាក់ឧបត្ថម្ភរបស់បុគ្គលិក។

**ឈ.ការងារគ្រប់គ្រងហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិ**

ក្រុមប្រឹក្សាត្រូវគ្រប់គ្រងហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាពចំពោះប្រជាពលរដ្ឋ និងចំពោះរាជរដ្ឋាភិបាល ដោយក្នុងនោះការងារសំខាន់ៗរួមមាន៖

- ការពិនិត្យ និងអនុម័តក្របខ័ណ្ឌចំណាយរយៈមធ្យម
- ការពិនិត្យ និងអនុម័តគម្រោងថវិកាប្រចាំឆ្នាំ
- តាមដានត្រួតពិនិត្យការអនុវត្តថវិកាដោយគណៈអភិបាល
- ការពិនិត្យ និង អនុម័តរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ
- ការពិនិត្យ និង អនុម័តការជម្រះបញ្ជីទ្រព្យសម្បត្តិជាដើម។

## ១.២.២. គណៈអភិបាលខណ្ឌ

នៅតាមបណ្ដាសាលាខណ្ឌនីមួយៗ ត្រូវតែមានគណៈអភិបាលខណ្ឌ ដែលក្នុងនោះរួមមាន អភិបាលខណ្ឌមួយរូប និងអភិបាលរងខណ្ឌមួយចំនួន ដែលត្រូវបានតែងតាំង ដោយស្របតាមលក្ខខណ្ឌ នៃច្បាប់ស្ដីពីការ គ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

ផ្អែកលើមូលដ្ឋាននៃវិសោធនកម្មមាត្រា១៤០ នៃច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ រាជរដ្ឋាភិបាលបានសម្រេចដាក់ចេញអនុក្រឹត្យលេខ ១១៩ អនក្រ.បក ស្ដីពីការកំណត់ចំនួន គណៈអភិបាលរាជធានី គណៈអភិបាលខេត្ត គណៈអភិបាលក្រុង គណៈអភិបាលស្រុក គណៈអភិបាលខណ្ឌ ដែលតាមស្មារតីនៃអនុក្រឹត្យនេះ គណៈអភិបាលរាជធានីភ្នំពេញមានចំនួន ១១រូប និងគណៈអភិបាលខណ្ឌ នីមួយៗនៃរាជធានីភ្នំពេញ មានចំនួន ៧រូប ។ អភិបាល និងអភិបាលរង មានអាណត្តិការងារមិនលើសពីបួន(៤)ឆ្នាំនិងអាចត្រូវបានតែងតាំងបានបួន(៤)ឆ្នាំទៀតសម្រាប់អាណត្តិទី២របស់ខ្លួននៅក្នុងដែនសមត្ថកិច្ចដដែល។

អភិបាល ត្រូវតែងតាំងដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដោយត្រូវជ្រើសរើស ពីក្នុងចំណោមមន្ត្រីរាជការស៊ីវិលទាំងពីរភេទដែលស្ថិតក្នុងក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ ឬ ក្រៅក្របខ័ណ្ឌក្រសួងមហាផ្ទៃ និងត្រូវមានលក្ខណសម្បត្តិដូចខាងក្រោម៖

- មានឋានន្តរសក្តិចាប់ពីអនុមន្ត្រីឡើង
- មានអាយុចាប់ពីសាមសិប (៣០) ឆ្នាំឡើង គិតដល់ថ្ងៃតែងតាំង
- មានបទពិសោធន៍ការងារផ្នែករដ្ឋបាលសាធារណៈយ៉ាងតិចប្រាំ (៥)ឆ្នាំ ឬ/និងមានសញ្ញាបត្របរិញ្ញាបត្រ ដែលទទួលស្គាល់ដោយក្រសួងអប់រំ យុវជន និងកីឡា
- មានឈ្មោះក្នុងបញ្ជីឈ្មោះបោះឆ្នោតផ្លូវការក្នុងរយៈពេលនៃការតែងតាំង
- មិនធ្លាប់មានទោសឧក្រិដ្ឋ ឬ មជ្ឈិមណាមួយ។

ដោយឡែក អភិបាលរង ត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដោយត្រូវជ្រើស រើសពីក្នុងចំណោមមន្ត្រីរាជការស៊ីវិលទាំងពីរភេទ ដែលស្ថិតក្នុងក្របខ័ណ្ឌមន្ត្រីក្រមការក្រសួងមហាផ្ទៃ ឬ ក្រៅក្របខ័ណ្ឌក្រសួងមហាផ្ទៃ និងត្រូវមានលក្ខណសម្បត្តិដូចខាងក្រោម៖

- មានឋានន្តរសក្តិចាប់ពីនាយក្រមការឡើង
- មានអាយុចាប់ពីម្ភៃប្រាំ (២៥) ឆ្នាំឡើង គិតដល់ថ្ងៃតែងតាំង
- មានបទពិសោជធន៍ការងារផ្នែករដ្ឋបាលសាធារណៈយ៉ាងតិចបី(៣)ឆ្នាំ ឬ/និងមានសញ្ញាបត្រ បរិញ្ញបត្ររង ដែលទទួលស្គាល់ដោយក្រសួងអប់រំ យុវជន និងកីឡា
- មានឈ្មោះក្នុងបញ្ជីឈ្មោះបោះឆ្នោតផ្លូវការក្នុងរយៈពេលនៃការតែងតាំង
- មិនធ្លាប់មានទោសឧក្រិដ្ឋ ឬ មជ្ឈិមណាមួយ។

❖ គណៈអភិបាលមានសិទ្ធិអំណាចដូចខាងក្រោម៖

- បញ្ចេញមតិយោបល់ក្នុងកិច្ចប្រជុំក្រុមប្រឹក្សា ប៉ុន្តែមិនអាចធ្វើការបោះឆ្នោតបានឡើយ

- ចុះហត្ថលេខាលើលិខិតបទដ្ឋាន និងលិខិតរដ្ឋបាលនានាសម្រាប់ចាត់ចែងការងារប្រចាំថ្ងៃ និងការងារចាំបាច់ផ្សេងៗទៀត ដើម្បីអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា លើកលែងតែ លិខិតបទដ្ឋានទាំងឡាយណាដែលតម្រូវឱ្យប្រធានក្រុមប្រឹក្សាចុះហត្ថលេខាក្នុងនាមក្រុមប្រឹក្សា
- ផ្តួចផ្តើមលើកសំណើ សំណូមពរជូនក្រុមប្រឹក្សារបស់ខ្លួន ដើម្បីដាក់ចេញនូវសេចក្តីសម្រេច ខាងបញ្ញត្តិ ឬសេចក្តីសម្រេចខាងប្រតិបត្តិ
- លើកសំណើបង្កើតគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារនានា
- សិទ្ធិអំណាចមួយចំនួនពាក់ព័ន្ធការងារគ្រប់គ្រងបុគ្គលិកដែលមិនតម្រូវឱ្យមានការអនុម័ត ដោយក្រុមប្រឹក្សា។

ការសម្រេច ឬការអនុវត្តកិច្ចការណាមួយរបស់គណៈអភិបាល ដែលស្ថិតនៅក្នុងសមត្ថកិច្ចរបស់ ក្រុមប្រឹក្សា ហើយពុំទទួលបានការសម្រេចពីក្រុមប្រឹក្សា ការសម្រេច ឬការអនុវត្តកិច្ចការនោះពុំមានសុពល ភាពឡើយ។ ក្នុងករណីនេះ គណៈអភិបាល ឬ អភិបាល ឬ អភិបាលរងត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ អំពីការសម្រេច ឬសកម្មភាពទាំងនោះ។

គណៈអភិបាលអាចសម្រេច ឬអនុវត្តកិច្ចការណាមួយដែលស្ថិតនៅក្នុងសមត្ថកិច្ចរបស់ក្រុមប្រឹក្សា ដោយពុំចាំបាច់មានការអនុញ្ញាតជាមុនពីក្រុមប្រឹក្សាបាន ក្នុងក្របខ័ណ្ឌនៃអំណាចដែលខ្លួនទទួលបានពី ការធ្វើប្រតិភូកម្មពីក្រុមប្រឹក្សា ឬ ក្នុងករណីប្រធានស័ក្តិ។ ក្នុងករណីនេះ គណៈអភិបាលត្រូវធ្វើ សេចក្តី រាយការណ៍ជូនក្រុមប្រឹក្សាអំពីកិច្ចការទាំងនោះ។

**១.២.២.១ សមាសភាពអភិបាលនៃគណៈអភិបាលខណ្ឌ**

តាមមាត្រា ១៤០ថ្មី ស្តីពីការកំណត់សមាសភាពគណៈអភិបាល។ រាជធានីភ្នំពេញមានចំនួនយ៉ាងច្រើន១១រូបសម្រាប់គណៈអភិបាលរាជធានី រីឯគណៈអភិបាលខេត្តមានចំនួនពី ៧រូប ទៅ១១រូប។ ចំពោះគណៈអភិបាលក្រុង ស្រុក ខណ្ឌ មានចំនួនពី៥រូប ទៅ៧រូប។ ចំនួនជាក់ស្តែងនៃគណៈអភិបាលសម្រាប់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។[14]

ជាក់ស្តែងគណៈអភិបាលខណ្ឌមានជ័យរួមមាន អភិបាល០១រូប និងអភិបាលរងចំនួន០៤រូប។ លោក សេង គន្ធ ជាអភិបាលខណ្ឌមានជ័យ។[15] ឯអភិបាលរងខណ្ឌមានរួមមាន លោកស្រី ហួត ឃីម លោក ឌី សុខខែម លោក គៀង ចក់[16] និង លោក ឡុង ង៉ែត។[17]

**១.២.២.២. តួនាទីគណៈអភិបាលខណ្ឌ**

គណៈអភិបាលមានតួនាទីជាអ្នកអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា។ ក្រៅពីនេះ អភិបាលក៏ មានតួនាទីជាតំណាងរាជរដ្ឋាភិបាល និងក្រសួង ស្ថាប័នក្នុងដែនសមត្ថកិច្ចរបស់ខណ្ឌផងដែរ។

[14] https://thmeythmey.com/event/?page=detail&id=118526

[15] https://m.freshnewsasia.com/index.php/en/localnews/321896-2023-12-19-06-00-33.html

[16] https://eacnews.asia/home/details/14849 រដ្ឋមន្ត្រីមហាផ្ទៃផ្ទេរភារកិច្ច និងតែងតាំងអភិបាលរងខណ្ឌនានាក្នុងរាជធានីភ្នំពេញជាង៤០នាក់

[17] https://ams.com.kh/central/detail/522702

ក្នុងនាមជាអ្នកអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា គណៈអភិបាលមានភារកិច្ចសំខាន់ៗដូចជា៖

- អនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា
- លើកយោបល់ជូនក្រុមប្រឹក្សា ពាក់ព័ន្ធកិច្ចការនានាដែលក្រុមប្រឹក្សាត្រូវពិនិត្យ និងអនុម័ត
- ផ្តួចផ្តើម រៀបចំ និងដាក់ជូនក្រុមប្រឹក្សានូវសេចក្តីព្រាងដីកា សេចក្តីសម្រេច និង/ឬ បទបញ្ជា
- នានា ដើម្បីក្រុមប្រឹក្សាពិនិត្យ និងអនុម័ត
- ធ្វើរបាយការណ៍ជូនក្រុមប្រឹក្សាអំពីការអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាការអនុវត្តផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ កម្មវិធីវិនិយោគបីឆ្នាំរំកិល ថវិកា និងសកម្មភាពផ្តល់សេវា កម្មនានារបស់រដ្ឋបាលខណ្ឌ ព្រមទាំងការអនុវត្តគម្រោង ឬកម្មវិធីនានា។

❖ ក្នុងតួនាទីជាតំណាងរាជរដ្ឋាភិបាល តំណាងក្រសួង ស្ថាប័ននៃរាជរដ្ឋាភិបាលនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន អភិបាលត្រូវ៖

- មានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាល ក្រសួងមហាផ្ទៃ និងក្រសួង ស្ថាប័ននានា និង ធ្វើសេចក្តីរាយការណ៍ជូនរាជរដ្ឋាភិបាល និងក្រសួង ស្ថាប័ននានា
- ដឹកនាំ សម្របសម្រួលការិយាល័យ អង្គភាពពាក់ព័ន្ធ និងរដ្ឋបាលសង្កាត់ ដើម្បីធានារក្សា សន្តិសុខ សណ្តាប់ធ្នាប់ និងរបៀបរៀបរយសាធារណៈ ការអនុវត្តច្បាប់ និងការការពារសិទ្ធិមនុស្ស ក្នុងនាមជាប្រធានគណៈបញ្ជាការឯកភាព
- ណែនាំ សម្របសម្រួល តម្រង់ទិសដល់ការិយាល័យ អង្គភាព និងទីភ្នាក់ងារនានារបស់ ក្រសួង ស្ថាប័នដែលប្រតិបត្តិការនៅក្នុងខណ្ឌ ក្នុងការអនុវត្តតួនាទី ភារកិច្ចរបស់ខ្លួន ដើម្បី ឆ្លើយតបទៅនឹងតម្រូវការជាអាទិភាពនៅមូលដ្ឋាន
- ការតែងតាំង ផ្លាស់ប្តូរ និងបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលនៅក្នុងរដ្ឋបាលខណ្ឌ។

ពាក់ព័ន្ធនឹងការកែសម្រួលចំនួនគណៈអភិបាលរាជធានី និងគណៈអភិបាលខណ្ឌខាងលើ និងផ្អែកលើការកែសម្រួលរចនាសម្ព័ន្ធ ប្រព័ន្ធអភិបាលកិច្ច និងមុខងាររបស់រដ្ឋបាលរាជធានីភ្នំពេញ និងរដ្ឋបាលខណ្ឌនៃរាជធានីភ្នំពេញ ព្រមទាំងដើម្បីធានាឱ្យការបំពេញតួនាទី ភារកិច្ចរបស់អភិបាល និងអភិបាលរងនៃគណៈអភិបាល រាជធានីភ្នំពេញ និងគណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ ប្រកបដោយប្រសិទ្ធភាព មានសាមគ្គីភាពផ្ទៃក្នុង និងមានស្មារតីទទួលខុសត្រូវក្នុងការបំពេញការងារ ស្របតាមគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ពាក់ព័ន្ធនឹងកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ក្រសួងមហាផ្ទៃសូមធ្វើការណែនាំ អំពីការបែងចែកតួនាទី ភារកិច្ច និងរបៀបរបបធ្វើការងារជូនគណៈអភិបាលរាជធានីភ្នំពេញ និងគណៈអភិបាលខណ្ឌ នៃរាជធានីភ្នំពេញ ដូចខាងក្រោម ៖

**ក-ការបែងចែកតួនាទី ភារកិច្ចក្នុងជួរគណៈអភិបាលខណ្ឌ**

ផ្អែកលើរចនាសម្ព័ន្ធ និងមុខងាររបស់រដ្ឋបាលខណ្ឌ គណៈអភិបាលខណ្ឌត្រូវប្រជុំពិនិត្យ ពិភាក្សាដើម្បីធ្វើការបែងចែកភារកិច្ចដល់អភិបាល និងអភិបាលរង នៃគណៈអភិបាលខណ្ឌ ដើម្បីទទួលខុសត្រូវជួយទៅលើការងារនៅតាមការិយាល័យ អង្គភាព និងកិច្ចការនានាដែលពាក់ព័ន្ធនឹងដែនសមត្ថកិច្ចរបស់រដ្ឋបាលខណ្ឌ។

អភិបាលរងខណ្ឌដែលបានទទួលការបែងចែកភារកិច្ចនេះ ត្រូវទទួលខុសត្រូវចំពោះមុខអភិបាលខណ្ឌលើភារកិច្ចនានាដែលបានប្រគល់ ហើយត្រូវរួមគ្នាជាមួយអភិបាលខណ្ឌ ដើម្បីទទួលខុសត្រូវអំពីការធ្វើ សេចក្ដីសម្រេច និងសកម្មភាពក្នុងគណៈអភិបាលរបស់ខ្លួន។

ការបែងចែកភារកិច្ចក្នុងជួរគណៈអភិបាលខណ្ឌ ត្រូវបានអនុវត្តដូចខាងក្រោម៖

- អភិបាលខណ្ឌ ទទួលបន្ទុកដឹកនាំការងាររួម និងដឹកនាំផ្ទាល់លើការងាររដ្ឋបាលទូទៅ ការងារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន ការងារប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស និង ការងារគ្រប់គ្រងគ្រោះមហន្តរាយ។
- អភិបាលរងមួយរូប ទទួលជួយអភិបាលខណ្ឌ លើការងាររដ្ឋបាល ការងារគ្រប់គ្រងបុគ្គលិក ការងារអភិវឌ្ឍសមត្ថភាព ការងារអត្រានុកូលដ្ឋាន ការងារលេខាធិការក្រុមប្រឹក្សា ការងារផ្តល់សេវារដ្ឋបាល និងការងារ ទំនាក់ទំនងសាធារណៈ។
- អភិបាលរងមួយរូប ទទួលជួយអភិបាលខណ្ឌ លើការងារពាណិជ្ជកម្ម ឧស្សាហកម្ម សិប្បកម្ម ការងាររ៉ែនិងថាមពល ការងារកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ការងារធនធានទឹក ការងារប្រៃសណីយ៍ និងទូរគមនាគមន៍ ការងារសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ការងារសុខាភិបាល កិច្ចការនារី ការងារ ធម្មការនិងសាសនា ការងារវប្បធម៌និងវិចិត្រសិល្បៈ និងការងារអភិវឌ្ឍន៍សហគមន៍។
- អភិបាលរងមួយរូប ទទួលជួយអភិបាលខណ្ឌ លើការងារហិរញ្ញវត្ថុ ការងារថវិកា ការងារផែនការ និងកម្មវិធីវិនិយោគ ការងារស្ថិតិប្រជាជន ការងារលទ្ធកម្មសាធារណៈ និងការងារគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ។
- អភិបាលរងមួយរូប ទទួលជួយអភិបាលខណ្ឌ លើការងារគ្រប់គ្រង និងអភិរក្សសំណង់បេតិកភ័ណ្ឌ ការងារគ្រប់គ្រងការសាងសង់សំណង់គ្រប់ប្រភេទ ការងារចុះបញ្ជីដីធ្លី និងការងារលំនៅដ្ឋាន។
- អភិបាលរងមួយរូប ទទួលជួយអភិបាលខណ្ឌ លើការងារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ការងារសាធារណការនិងដឹកជញ្ជូន ការងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ការគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ ការងារបំភ្លឺសាធារណៈ ការងារដាំដើមឈើ និងសួនច្បារសាធារណៈ។
- អភិបាលរងមួយរូប ទទួលជួយអភិបាលខណ្ឌ លើការងារទេសចរណ៍ ការងារអប់រំ យុវជន និងកីឡា ការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ការងារនីតិកម្ម ការងារទទួលពាក្យបណ្តឹងនិងសម្រុះសម្រួលវិវាទនៅមូលដ្ឋាន និងការងារវេទិកាសាធារណៈ។[18]

ផ្អែកតាមការបែងចែកតួនាទី ភារកិច្ចខាងលើ អភិបាលខណ្ឌត្រូវពិភាក្សាដើម្បីចាត់អភិបាលរងខណ្ឌទៅក្នុងគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សាខ្លួន ឱ្យបានសមស្របតាមសមត្ថភាព បទពិសោធន៍ ជំនាញ និងការបែងចែកភារកិច្ចដូចបានកំណត់ខាងលើផងដែរ។

## ១.៣. កត្តាដែលជំរុញឱ្យមានការរៀបចំខណ្ឌ

បុព្វហេតុនៃការរៀបចំខណ្ឌមួយចាំបាច់ត្រូវធ្វើឡើងប្រកបដោយសនិទានកម្ម ពោលគឺមានការគិតគូរហ្មត់ចត់សព្វគ្រប់ជ្រុងជ្រោយ។ ទន្ទឹមនឹងនេះ មុននឹងឈានដល់ការរៀបចំ ឬអភិវឌ្ឍអ្វីមួយ គឺវាបណ្តាលមកពី

[18] សេចក្តីណែនាំ របស់ក្រសួងមហាផ្ទៃ លេខ ០៤៦ សណន ស្តីពី សៀវភៅណែនាំ ស្តីពី សេចក្តីណែនាំបែងចែកតួនាទី ភារកិច្ច និងរបៀបរបបការងារជូនគណៈអភិបាលរាជធានីភ្នំពេញ និងអភិបាលនៃគណៈខណ្ឌនៃរាជធានីភ្នំពេញ ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២២

ភាពខ្វះចន្លោះដែលជាហេតុនាំកើតមានឡើងនូវបញ្ហាផ្សេងៗផងដែរ។ យ៉ាងណាមិញយើងក្រឡែកមើលទៅតាម បណ្តាតំបន់នានាដូចជា៖ ភូមិ ឃុំ/សង្កាត់ ស្រុក/ខណ្ឌ ខេត្ត/ក្រុង ក្នុងប្រទេសនានាក៏ដូចជាប្រទេសកម្ពុជារបស់ យើងតែងមានការរៀបចំនូវគម្រោង ឬដាក់ផែនការសកម្មភាពអភិវឌ្ឍនៅតាមតំបន់នានាដែលកំពុងជួបនូវបញ្ហា ខ្វះខាតដែលត្រូវមានការរៀបចំឱ្យកាន់តែប្រសើរឡើងជាងមុន។ ជារួមការរៀបចំទីក្រុងដើម្បីឱ្យមានសណ្តាប់ធ្នាប់ សំដៅដល់ការរៀបចំក្រុងឱ្យមានសកម្មភាពល្អ សន្តិសុខភាពស្ងប់ស្ងាត់ និងអនាម័យ។

ដូចនេះហើយ ទើបការរៀបចំក្រុងនីមួយៗត្រូវធ្វើដោយការផ្ចិតផ្ចង់ ពុំមែនធ្វើឡើងដោយភាពចៃដន្យនោះទេពោល គឺកើតឡើង ដោយសារតែមានការជំរុញពីកត្តាផ្សេងៗជាច្រើនដូចជា ៖ កំណើនប្រជាជន ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ និង ភាពក្រីក្រ ដែលត្រូវបកស្រាយតាមចំណុចមួយៗនៅខាងក្រោមនេះ ៖

**១.៣.១. កំណើនប្រជាជន**

បញ្ហាកំណើនប្រជាជន គឺជាបញ្ហាមួយចម្បង និងអាចចាត់ទុកជាបញ្ហាស្នូលដែលបង្កើតឲ្យមាន បញ្ហាផ្សេងៗ ជាច្រើនទៀត។ ការកើនឡើងនៃចំនួនប្រជាជននៅតាមតំបន់ ឬ ទីក្រុងតែងតែកើតមានឡើងពីមួយឆ្នាំទៅមួយឆ្នាំ ហើយវាក៏ជាមូលហេតុមួយដ៏សំខាន់ដែលចាំបាច់តម្រូវឱ្យមានការរៀបចំក្រុងសារជាថ្មីម្តងទៀត ។

ជាទូទៅសមាសភាព នៃកំណើនប្រជាជន ក្នុងក្រុងមានកត្តា៣ សំខាន់ៗដូចជា កំណើនប្រជាជនតាមលក្ខណៈធម្មជាតិ កំណើនប្រជាជនដោយការធ្វើចំណាកស្រុកនៃប្រជាពលរដ្ឋដែលរស់នៅតាមទីជនបទ និងកំណើនដោយសារតែមានការ បែងចែកប្រភេទសណ្ឋានដីនៃក្រុងថ្មី ដែលពីមុនតំបន់នោះជាទីជនបទ។[19] កំណើនប្រជាជនក្នុងក្រុងជាលក្ខណៈធម្មជាតិ គឺមួយឆ្នាំទៅមួយឆ្នាំមនុស្សចេះតែកើនឡើង ស្ថិតនៅតាមកាលៈទេសៈ ពេលវេលាចេះតែរំកិលទៅមុខ អត្រាកើតប្រជាពលរដ្ឋថ្មីនៅក្នុងទីក្រុងច្រើនឡើងៗ ឯអត្រាមរណភាពបានថយចុះ ដូច្នេះនេះហើយ ចំនួនកំណើនប្រជាជន ហើយអត្រាកើតក៏ចេះតែកើនឡើង ផងដែរ។ កំណើនដោយសារ ចំណាកស្រុកពីជនបទ គឺដោយសារខណ្ឌមានជ័យ សម្បូរហាងលក់ទំនិញ កន្លែងកំសាន្ត ផ្សារទំនើប រោងចក្រ ហាងតូចធំជាច្រើន ហេតុនេះខណ្ឌមានជ័យ គឺជាទីផ្សារការងារដ៏ធំទូលាយដែលធ្វើឱ្យប្រជាពលរដ្ឋនៅតាមស្រុកជនបទដែលមាន បញ្ហាហិរញ្ញវត្ថុ ការខ្វះខាតនូវការងារជាហេតុនាំឱ្យពួកគេសម្រេចចិត្តចាកចេញពីលំនៅដ្ឋានរបស់ពួកគេរៀងៗខ្លួនមកកាន់ទីក្រុង ដើម្បីស្វែងរកការងារធ្វើនិងដើម្បីផ្គត់ផ្គង់ជីវភាពផងដែរ។ កំណើនដោយសារការបែងចែកប្រភេទសណ្ឋាននៃក្រុង ថ្មីដែលពីមុនមកតំបន់នេះជាទីជនបទ គឺកើតឡើងដោយសារសណ្ឋានដីទីក្រុងថ្មីដែលពីមុនជាខេត្ត ឬជនបទ។ កំណើនប្រជាជនបានបង្កឱ្យមានបញ្ហាមួយចំនួនដូចជា ៖

**បញ្ហាកកស្ទះចរាចរណ៍** ៖ គឺជាបញ្ហាដ៏ធំមួយដោយសារចំនួនប្រជាជនមានការកើនឡើងច្រើន ដូចនេះតម្រូវការ ប្រើប្រាស់យានយន្តគ្រប់ប្រភេទ ក៏ត្រូវមានការកើនឡើង ដែលជាមូលហេតុបង្កឱ្យមានការស្ទះចរាចរណ៍ ព្រោះតម្រូវការនៃការប្រើប្រាស់ផ្លូវមានចំនួនច្រើន និងអ្នកប្រើប្រាស់ផ្លូវមួយចំនួនក៏មិនបានគោរពច្បាប់ចរាចរណ៍ ដោយពួកគាត់បើកប្រជែងគ្នាដើម្បីបានទៅមុខរៀងៗខ្លួន ដោយមិនខ្វល់ពីអ្នករួមដំណើរជាមួយនោះទេ។ ផ្លូវដែល មានការកកស្ទះភាគច្រើន ជាតំបន់ផ្សារ ឬ រោងចក្រជាដើម ដែលបង្កមកពីអាជីវកម្មមួយចំនួនគាត់បានប្រើប្រាស់ ចិញ្ចើមផ្លូវធ្វើជាការលក់ដូរ។ តួយ៉ាងការកកស្ទះចរាចរណ៍ ជាបញ្ហាដ៏ធំមួយដែលជះឥទ្ធិពលយ៉ាង

[19] សៀវភៅនីតិនគរូបនីយវិទ្យា, បណ្ឌិត អ៊ុន សកក្កដា បោះពុម្ពឆ្នាំ (២០២៣-២០២៤) ទំព័រទី១៩

ខ្លាំងដល់សុខភាពផ្លូវចិត្តខាតពេលវេលា និងខាតបង់លុយកាក់ ដោយសារនៅពេលស្ទះចរាចរណ៍ម្តងៗអ្នកបើកបរលើដងផ្លូវត្រូវការបញ្ឆេះឡាន ម៉ូតូ កង់បីទុកចោលទម្រាំតែបានចេញដំណើរដែលនោះធ្វើឱ្យមានការខាតបង់ក្នុងការ ចំណាយទៅលើប្រេងសាំង ឬ ម៉ាសូត ដែលពួកគាត់បានបញ្ឆេះចោលនៅពេលស្ទះចរាចរណ៍ ហើយវាក៏បង្កឱ្យមានការបំពុលបរិស្ថានបន្ថែមទៀតផងដែរតាមរយៈផ្សែងដែលកើតចេញពីចំហេះម៉ាស៊ីន។

**ការរីករាលដាលនៃសំណង់អនាធិបតេយ្យ៖** មានប្រជាជនភាគច្រើនរស់នៅ លំនៅដ្ឋាន ដែលមិនមានគុណភាព និង សាងសង់នៅតំបន់ខុសច្បាប់ ដូចជា នៅលើប្រឡាយ ឬ ចិញ្ចើមផ្លូវដើម ដែលភាគច្រើនរស់នៅដោយប្រជាជនក្រីក្រ ឬ ប្រជាជនដែលចំណាកស្រុកពីជនបទ។ មួយវិញទៀតការកើនឡើងនៅសំណង់អនាធិបតេយ្យនេះក៏ធ្វើឱ្យមានផលប៉ះពាល់ដល់ សោភ័ណភាពទីក្រុងផងដែរ។

**កង្វះខាតអគ្គិសនី៖** ដោយសារតែប្រជាជនមានចំនួនកើនឡើងជាលំដាប់ តម្រូវការនៃការប្រើប្រាស់ថាមពលអគ្គិសនី ក៏ត្រូវមានការកើនឡើងដូចគ្នាជាលំដាប់នឹងបញ្ហា ឬ តម្រូវការផ្សេងៗជាច្រើនទៀត។

### ១.៣.២. គមនាគមន៍

គមនាគមន៍ គឺជាបញ្ហាមួយសំខាន់ដែលជម្រុញឲ្យមានការអភិវឌ្ឍ ដែលវាបានធ្វើការផ្តោត សំខាន់ទៅលើការអភិវឌ្ឍផ្លូវ។ ផ្លូវជាបញ្ហាចោទមួយសម្រាប់ទីក្រុង ដែលគួរគប្បីធ្វើការយកចិត្តទុកដាក់ ក្នុងការអភិវឌ្ឍ ដែលធ្វើឲ្យទីក្រុងមានសណ្តាប់ធ្នាប់ល្អ តាមរយៈការធ្វើដំណើរទៅមកប្រកបដោយសន្តិសុខ និងសុវត្ថិភាពសម្រាប់ប្រជាពលរដ្ឋនៅក្នុងប្រទេស។ កាលណាមានផ្លូវល្អគ្មានខូចខាត ដែលបង្កលក្ខណៈងាយស្រួលដល់ប្រជាពលរដ្ឋក្នុងការធ្វើដំណើរឆាប់រហ័ស និងប្រកបរបរចិញ្ចឹមជីវិត នោះសេដ្ឋកិច្ចជាតិកាន់តែរីកចម្រើនផងដែរ។

ការលូតលាស់ផ្នែក កសិកម្ម ឧស្សាហកម្ម ពាណិជ្ជកម្ម និងទេសចរណ៍ ទាក់ទងយ៉ាងជិតស្និទ្ធ ទៅនឹងការរីកចម្រើនខាងផ្លូវគមនាគមន៍។ ផ្លូវគមនាគមន៍នៅកម្ពុជាយើងសព្វថ្ងៃមានដូចជា ផ្លូវគោក ផ្លូវ ដែក ផ្លូវទឹក ផ្លូវអាកាស ដែលមានសក្តានុពលយ៉ាងខ្លាំងសម្រាប់ធ្វើដំណើរនិងធ្វើពាណិជ្ជកម្មដែលធ្វើការដឹកជញ្ជូនទំនិញនានាឆ្លងដែនទៅក្រៅប្រទេស ដែលមានលក្ខណៈជាអន្តរជាតិ។[20]

ដូចនេះ វិស័យគមនាគមន៍ជាមធ្យោបាយមួយដ៏សំខាន់ ដែលជាសរសៃឈាមនៃសេដ្ឋកិច្ចជាតិ សម្រាប់ដឹកជញ្ជូនទំនិញចេញចូលក្នុងនិងក្រៅប្រទេស ព្រមទាំងសម្រាប់ធ្វើដំណើរដែលមិនអាចខ្វះបាន។ កាលណាគមនាគមន៍រីកចម្រើន ជួយសម្រួលដល់ការដឹកជញ្ជូនភ្ញៀវទេសចរណ៍ ផលិតផល កសិកម្ម និងឧស្សាហកម្ម វត្ថុធាតុដើម ទំនិញនាំចេញនាំចូលរហ័សទាន់ពេលវេលា ចំណាយសោហ៊ុយតិចនិងប្រកបដោយជាសុខភាព សុវត្ថិភាព។

### ១.៣.៣. ភាពក្រីក្រ

ការកំណត់អំពីស្ថានភាពក្រីក្រ មានការលំបាកនៅក្នុង ការកំណត់ណាស់តែជាទូទៅភាពក្រីក្រសំដៅដល់ ការដែលជាតម្រូវការរបស់មនុស្សមិនត្រូវបានបំពេញ។ ជារួមប្រទេសភាគច្រើនបានកំណត់ពីភាពក្រីក្រតាមរយៈប្រាក់ចំណូលទាប និងមិនអាចចាយវាយគ្រប់គ្រាន់ក្នុងជីវភាពប្រចាំថ្ងៃឡើយ។ តម្រូវការរូបកាយ ចំណីអាហារ លំនៅដ្ឋានការងារធនធានទឹក អគ្គិសនី អនាម័យសុខភាពសង្គមមានការខ្វះខាត។ លើសពីនេះសិទ្ធិសេរី

[20] សៀវភៅភូមិវិទ្យា សេដ្ឋកិច្ច និងមនុស្ស នៃប្រទេសកម្ពុជា ដែលរៀបរៀងដោយ គណៈកម្មការរៀបរៀង គឺលោក-លោកស្រី សាស្ត្រាចារ្យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំ២០១៣-២០១៤

ភាពផ្នែកស្មារតី និយាយរួមសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយក៏នៅមានកម្រិតដែរ។ ការសម្គាល់ពីភាពក្រីក្រត្រូវបានសង្កត់ធ្ងន់លើចំណូលទាបបុគ្គលមួយរូបៗ ពីព្រោះតែបញ្ហាផ្សេងៗដូចជា៖ ចំនួននៃករណីឧក្រិដ្ឋកម្ម អំពើហិង្សា ឬអាយុសង្ឃឹមរស់ជាមធ្យមគឺមិនអាចយកមកជំនួសដោយការវាស់ស្ទង់តាមរយៈប្រាក់ចំណូលនេះឡើងដែលជា ធម្មតាអ្នកដែលទទួលប្រាក់ចំណូលក្រោមកម្រិតមធ្យមត្រូវបានគេសម្មតថាជនក្រីក្រ។[21] បើយើងប្រៀបធៀបភាពក្រីក្រនៅតាមជនបទ និង ភាពក្រីក្រនៅ ទីក្រុងឃើញថាមានលក្ខណៈខុសគ្នា ដោយហេតុថានៅទីក្រុងត្រូវមានការចំណាយខ្ពស់ជាងនៅតាមជនបទ ហើយអ្នករស់នៅតាមជនបទ អាចមានឱកាសស្វែងរកការចិញ្ចឹមជីវិតតាមរយៈការទទួលអំណោយសប្បុរសជន ភោគផលពីធម្មជាតិច្រើនជាងអ្នកនៅទីក្រុង។ មួយវិញទៀតភាពក្រីក្រនេះបាន ធ្វើឱ្យមានបញ្ហាជាច្រើនទាក់ទង នឹងសណ្តាប់ធ្នាប់ និងសោភ័ណភាពផងដែរ ដោយសារតែប្រជាជនក្រីក្រភាគច្រើន គ្មានទីលំនៅស្នាក់នៅសមរម្យ ដែលអ្នកខ្លះត្រូវស្នាក់ឬសម្រាកនៅតាមចិញ្ចើមផ្លូវ ឬ សួនច្បារជាដើម។

[21] សៀវភៅនីតិនគរូបនីយវិទ្យា, បណ្ឌិត អ៊ុន សកក្កដា បោះពុម្ពឆ្នាំ (២០២៣-២០២៤) ទំព័រទី២០

# ជំពូកទី២
# ការរៀបចំសោភ័ណភាព
# និង សណ្ដាប់ធ្នាប់
# ខណ្ឌមានជ័យ

# ជំពូកទី២
# ការរៀបចំសោភ័ណភាព និងសណ្តាប់ធ្នាប់ខណ្ឌមានជ័យ

## ២.១. ការរៀបចំសោភ័ណភាពខណ្ឌមានជ័យ

ខណ្ឌមានជ័យស្ថិតនៅភាគអាគ្នេយ៍នៃរាជធានីភ្នំពេញប្រទេសកម្ពុជា។ ខណ្ឌនេះបានបែងចែកទៅជា ៧សង្កាត់។ នៅក្នុងខណ្ឌមានជ័យយើងក៏អាចមើលឃើញយ៉ាងច្បាស់ពីការរៀបចំបានយ៉ាងល្អដែលមានដោយ អគារតូចធំ ផ្សារ ភោជនីយដ្ឋាន សណ្ឋាគារ ផ្ទះសំណាក់ និង កន្លែងលំហែរ ជាច្រើនកន្លែង ផ្សេងៗ ទៀតដ៏មាន សកម្មភាពខ្លាំងក្លា សម្រាប់វិស័យសេដ្ឋកិច្ចនិងលំនៅដ្ឋាននៅក្នុងខណ្ឌ។ ខណ្ឌមានជ័យក៏ត្រូវបានចាត់ទុកជា ខណ្ឌដ៏មានសក្តានុពលស្ទើគ្រប់វិស័យដែលកំពុងទាក់ទាញអ្នកវិនិយោគទុនទាំងជាតិ និងអន្តរជាតិ ឲ្យមកបោះ ទុនអភិវឌ្ឍ និង កំពុងទាក់ទាញភ្ញៀវទេសចរណ៍ជាច្រើនផងដែរ ។ ជាងនេះទៅទៀតខណ្ឌមានជ័យក៏ជាកន្លែង ដែលបានឆក់យកនូវ កំណើនវិនិយោគជារៀងរាល់ឆ្នាំដោយបានមើលឃើញថាខណ្ឌមានជ័យគឺស្ថិតនៅភាគខាង ត្បូងនៃទីក្រុងភ្នំពេញនាពេលបច្ចុប្បន្ននេះ បាននឹងកំពុងមានសក្តានុពលនិងរីកចម្រើនខ្លាំងលើវិស័យ សំណង់ និងអចលនទ្រព្យបើធៀបជាមួយនឹងបណ្តាទិសផ្សេងៗទៀត។

តំបន់ដែលមានសក្តានុពលខ្លាំង នាពេលបច្ចុប្បន្ននេះយើងឃើញនៅតំបន់ភាគខាងត្បូងមានសន្ទុះខ្លាំង ជាពិសេសនៅខាង ខណ្ឌមានជ័យ ក៏ដូចជានៅខាងខណ្ឌខណ្ឌដង្កោរ នៅតំបន់គម្រោងផ្សារទំនើបអ៊ីអន៣ (តំបន់ផ្លូវ៦០ម៉ែត្រ) ដែលអ្នកអភិវឌ្ឍន៍មួយចំនួនកំពុងអនុវត្តគម្រោងធំៗរបស់ខ្លួន។ នៅតំបន់នេះ មានគម្រោង អភិវឌ្ឍន៍ធំៗជាច្រើន ដែលបាននិងកំពុងដុះឡើង និងកំពុងអភិវឌ្ឍន៍ ដែលនឹងជួយឱ្យវិស័យអចលនទ្រព្យ កាន់តែមានសន្ទុះរីកចំរើនកាន់តែខ្លាំង តែយ៉ាងណានៅតំបន់ផ្សេងៗ ទៀតក៏មានការរីកចំរើនផងដែរ។

តំបន់ភាគខាងត្បូងនៃរាជធានីភ្នំពេញបាន និងកំពុងរីកចំរើនខ្លាំង លើវិស័យអចលនទ្រព្យច្រើន ជាង បណ្តាតំបន់ជាយក្រុងនានា ជាពិសេសតំបន់ផ្លូវ៦០ម៉ែត្រ ឬមហាវិថីសម្តេចតេជោហ៊ុនសែន ដោយសារមាន គម្រោងធំៗជាច្រើនទៅកាន់ទីនោះ។

តំបន់ផ្លូវ៦០ម៉ែត្រ ហាក់មានសកម្មភាពរស់រវើកខ្លាំងជាង ដោយ សារតែតំបន់នេះ មានគម្រោងធំៗជា ច្រើន កំពុងរីកដុះដាល់នៅតំបន់នេះ ជាពិសេសមានគម្រោងផ្សារទំនើប AEON Mall ៣ ដោយពេលខ្លះ អ្នក វិយោគស្វែងរកទិញនៅតំបន់នេះមិនបាន ព្រោះវាមានតម្លៃខ្ពស់។

ការរីកចម្រើនភាគខាងត្បូងក្រុងភ្នំពេញ មិនមែនជារឿងចៃដន្យនោះទេ ប៉ុន្តែវាកើតឡើងដោយលក្ខខ័ណ្ឌ មួយចំនួនដូចជា ការរីកចម្រើននៃនគរូបនីយកម្ម ការកើនឡើងនូវចំនួនប្រជាពលរដ្ឋចូលមករស់នៅក្រុងភ្នំពេញ (កត្តាប្រជាសាស្ត្រ) ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធធំៗរបស់រដ្ឋាភិបាល ដូចជា ព្រលានយន្តហោះអន្តរជាតិ ភ្នំពេញថ្មី ផ្លូវក្រវ៉ាត់ក្រុងទី៣ ជាពិសេសតំបន់ភាគខាងត្បូងទីក្រុងភ្នំពេញ មានហេដ្ឋារចនាសម្ព័ន្ធតភ្ជាប់ទៅ កាន់ បណ្តាញផ្លូវជាតិធំៗជាច្រើន ដូចជាផ្លូវជាតិលេខ២ ផ្លូវជាតិលេខ៣ ផ្លូវជាតិលេខ៤ជាដើម។ ការរីកចម្រើននៃ សេដ្ឋកិច្ចជាតិ ដោយសារកត្តាសុខសន្តិភាព ពិតជាតម្លៃស្មួលមិនអាចខ្វះបាន ដែលជំរុញឲ្យប្រទេស កម្ពុជាមាន ការរីកចម្រើនយ៉ាងឆាប់រហ័ស និងឈានទៅកាន់លំដាប់ថ្មីមួយទៀត។

### ២.១.១.សោភ័ណភាពពេលថ្ងៃ

សោភ័ណភាពពេលថ្ងៃ គឺសម្តៅទៅលើការកសាងហេដ្ឋារចនាសម្ព័ន្ធរួមមាន ផ្លូវថ្នល់ ស្ពាន ប្រព័ន្ធលូចិញ្ចើមផ្លូវ សំណង់អគារតូចធំទាំងអស់របស់រដ្ឋ និងឯកជន សួនច្បារសាធារណៈ និងប្រព័ន្ធសុវត្ថិភាពចរាចរណ៍រួម មាន ភ្លើងសញ្ញា ស្លាកសញ្ញា និងគំនូសសញ្ញាចរាចរណ៍ រួមទាំងការធ្វើដំណើរតាមដងផ្លូវនៃយានយន្ត គ្រប់ប្រភេទ និងទាំងថ្មើរជើងផងដែរ ប្រកបទៅដោយសណ្តាប់ធ្នាប់ និងមានរបៀបរៀបរយល្អថែមទៀត។ បើយើងក្រឡេកមកមើលអំពីសោភ័ណភាពពេលថ្ងៃនៅក្នុងខណ្ឌមានជ័យ ជាក់ស្តែងឃើញថាតាមផ្លូវបានបំពាក់នៅផ្លាកសញ្ញាចរាចរណ៍ គំនូសសញ្ញាចរាចរណ៍ ហើយនៅតាមបណ្តោយផ្លូវមាននូវអគារតូចធំ សាលារៀន មន្ទីរពេទ្យ រង្វង់មូល រួមមានការដាំដើមឈើនៅតាមសងខាងផ្លូវដែរគួរជាទីគយគន់ និងសួនច្បារដែរងាយស្រួលដល់ប្រជាជនសម្រាប់ ធ្វើលំហាត់ប្រាណ ឬមកកម្សាន្ត ព្រមទាំងសួនសម្រាប់កុមារដែលអាចមកលេងកម្សាន្តបានរៀងរាល់ថ្ងៃបន្ទាប់ពី ឈប់សម្រាកពីការសិក្សា និងនៅចុងសប្តាហ៍ទៀតផង។

ចំពោះការរៀបចំហេដ្ឋារចនាសម្ព័ន្ធវិញ អភិបាលនៃគណៈអភិបាលខណ្ឌត្រូវរៀបចំ ដោយគោរពទៅតាមស្តង់ដា និងលិខិតបទដ្ឋានគតិយុត្ត ដែលរួមមានការរៀបចំប្រព័ន្ធលូ ត្រួតពិនិត្យចំពោះការសាងសង់សំណង់នានា ដូចជា អគារពាណិជ្ជកម្ម សហគ្រាស រោងចក្រ ស្ថានីយប្រេងឥន្ធនៈ ឃ្លាំងទំនិញ សំណង់លំនៅឋាន ផ្ទះល្វែង មន្ទីរពេទ្យ និងសាលារៀន ដើម្បីជៀសវាងការបង្កនៅគ្រោះថ្នាក់ផ្សេងៗ។ ការរៀបចំឱ្យមានសោភ័ណភាពហេដ្ឋារចនាសម្ព័ន្ធក៏ជាចំណែកមួយ ដើម្បីជាការប្រកួតប្រជែងជាមួយនឹងបណ្តាខណ្ឌដ៏ទៃផងដែរ។ បន្ថែមពីនេះការរៀបចំចរាចរណ៍ក៏ជាផ្នែកមួយយ៉ាងសំខាន់ ដើម្បីឱ្យសោភ័ណភាពក្នុងខណ្ឌមានជ័យកាន់តែមានភាពល្អប្រសើរ ឡើងដូច្នេះត្រូវពង្រឹង និងសម្រួលចរាចរណ៍ឱ្យមានរបៀបរៀបរយ ថ្វីត្បិតតែខណ្ឌមានជ័យ មាននូវបញ្ហាកកស្ទះ ប៉ុន្តែនៅតែទទួលបានការយកចិត្តទុកដាក់ពីសមត្ថកិច្ច ជាពិសេសនៅក្នុងឱកាសបុណ្យចូលឆ្នាំប្រពៃណីជាតិឬថ្ងៃឈប់សម្រាកដែលបណ្តាលឱ្យបញ្ហាកកស្ទះ និងគ្រោះថ្នាក់ចរាចរណ៍អាចនឹងកើតមានឡើង ជាការពិតណាស់ កម្លាំងសមត្ថកិច្ច គឺមិនអាចទប់ស្កាត់បានរាល់បញ្ហាចរាចរណ៍នេះបានឡើយ ចាំបាច់ទាមទារត្រូវតែមានការចូល រួមចំណែកយ៉ាងសំខាន់ពីសំណាក់ប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់។

### ២.១.២. ការរៀបចំសោភ័ណភាពពេលយប់

សោភ័ណភាពពេលថ្ងៃ គឺពិតជាបានឱ្យយើងមើល ឃើញនូវទិដ្ឋភាពយ៉ាងស្រស់ត្រកាលនៃខណ្ឌមានជ័យ និងជាតម្រូវការចាំបាច់ដែរមិនអាចខ្វះបានសម្រាប់ជីវិតរស់នៅប្រចាំថ្ងៃ។ ជាមួយគ្នានេះការអភិវឌ្ឍសោភ័ណភាពពេលថ្ងៃតែមួយមុខក៏មិនអាចទាក់ទាញបេះដូងប្រជាជន និងការមកចូលទស្សនាកម្សាន្តរបស់ភ្ញៀវទេសចរណ៍បានទេ ដូច្នេះសោភ័ណភាពពេលយប់ និងពេលថ្ងៃ គឺចាំបាច់ត្រូវដើរទន្ទឹមគ្នា និងមិនអាចខ្វះមួយណាបានឡើយ បើនិយាយពីសោភ័ណភាពពេលយប់វិញយើងនឹងនឹកឃើញទៅដល់ភ្លើងបំភ្លឺនៅតាមដងផ្លូវ ដូចគ្នានេះដែរ នៅលើ ដងវិថី និងតាមបណ្តាសង្កាត់ ក្នុងខណ្ឌមានជ័យ យើងឃើញមានភ្លើងបំពាក់នៅលើអគារនានារំលេច ឡើងនៅភ្លើងចម្រុះពណ៌ដែលគួរជាទីចាប់អារម្មណ៍ និងប្លែកម៉្យាងពីសោភ័ណភាពពេលថ្ងៃ។ ទិដ្ឋភាពនាពេលរាត្រីនៅក្នុងខណ្ឌមានជ័យក៏បានទាក់ទាញនូវចំណាប់អារម្មណ៍របស់មហាជនជាច្រើនមិនថាភ្ញៀវជាតិ ឬអន្តរជាតិ ឡើយព្រោះមានការបំពាក់ភ្លើងនៅតាមដងផ្លូវបានគ្រប់គ្រាន់ជាពិសេសនោះនៅតាមបង្កាន់ដៃស្ពានអាកាសក្បាលថ្នល់នឹងជួយបង្កើននូវសោភ័ណភាពមួយចំណែកផងដែរ។

## ២.២. ការរៀបចំសណ្តាប់ធ្នាប់

បើយើងគិតពីទីកន្លែងដែលមាននូវភាពស្ងប់ស្ងៀម សន្តិសុខ និងគ្មានការបំពុលទាំង០៥ ដូច្នេះយើងនឹងគិតទៅដល់ទិដ្ឋភាពមួយដែលមាននូវសណ្តាប់ធ្នាប់ និងមានសុភមង្គលក្នុងការស់នៅ។ ជាងនេះទៅទៀត សន្តិភាព ស្ថិរភាព សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈត្រូវបានថែរក្សាការពារយ៉ាងរឹងមាំ ជាការពិតណាស់ គណៈអភិបាលខណ្ឌមានជ័យ ចាំបាច់ត្រូវយកចិត្តទុកដាក់រៀបចំសន្តិសុខ និងសណ្តាប់ធ្នាប់ជាចម្បង រួមមាន តំបន់ទេចរណ៍ តំបន់ប្រកបអាជីវកម្ម ផ្សារ និងក្នុងឱកាសបុណ្យប្រពៃណីជាតិផ្សេងៗ។ យ៉ាងណាមិញនៅជុំវិញផ្សារក្នុងខណ្ឌមានជ័យ បានឱ្យដឹងថាកន្លងមកអាជ្ញាធរខណ្ឌ បានចុះរៀបចំសណ្តាប់ធ្នាប់ ហើយបានដាក់ ចេញសេចក្តីជូនដំណឹង និងសម្របសម្រួលជាមួយបងប្អូនអាជីវករដែលប្រកបអាជីវកម្មនៅលើចំណីផ្លូវដែល បានបង្កមានការកកស្ទះចរាចរណ៍ ដោយគណៈបញ្ជាការឯកភាពរដ្ឋបាលក្រុងបានដាក់វិធានការមួយចំនួនដើម្បី ឱ្យប្រជាពលរដ្ឋទាំងអស់ ចូលរួមសហការអនុវត្ត។

### ២.២.១. សន្តិសុខ

ជាការពិតណាស់មិនថានៅក្នុង រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ណាមួយនោះទេ ពាក្យថាសន្តិសុខវាពិតជាមានសារៈសំខាន់ណាស់ ព្រោះបើមានសន្តិសុខនៅក្នុងសង្គមនោះប្រទេសនីមួយៗក៏ទទួលបាននូវការរស់នៅបែបប្រកបដោយសុខសន្តិភាព មិនមាន ភាពភ័យខ្លាចមានសណ្តាប់ធ្នាប់ល្អក្នុងសហគមន៍រស់នៅផងដែរ។ ម្យ៉ាងវិញទៀតដើម្បីឱ្យខណ្ឌមួយមានសណ្តាប់ធ្នាប់ គឺត្រូវធ្វើ យ៉ាងណាធានាឱ្យបាននូវ សន្តិភាព សុវត្ថិភាពដែលជាសេចក្តីសុខសាន្ត និងគ្មានភាពចលាចលផ្សេងៗកើត មានឡើង។ ដើម្បីចូលរួមចំណែកជាមួយរាជរដ្ឋាភិបាលលើការងារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ស្របតាមគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព ជូនប្រជាពលរដ្ឋឱ្យរស់នៅប្រកប ដោយសុវត្ថិភាព និងសន្តិភាព នោះក្រុមប្រឹក្សា និងគណៈអភិបាលខណ្ឌ ដោយមានការជួយជ្រោមជ្រែង ពីស្ថាប័នជំនាញពាក់ព័ន្ធនានាជាពិសេស ដោយមានការចង្អុលបង្ហាញពីគណៈបញ្ជាការឯកភាពរដ្ឋបាលខណ្ឌ បានបង្ក្រាបសកម្មភាពបទល្មើសផ្សេងៗដូច ជាការចែកចាយ និងសេពគ្រឿងញៀន ក្មេងទំនើង ចោរលួច ឆក់ ប្លន់ អំពើហិង្សា ការល្មើសច្បាប់ចរាចរណ៍ផ្លូវ គោកនិងបទល្មើសដទៃទៀត ហើយព្រមទាំងបានរៀបចំសណ្តាប់ធ្នាប់ក្នុងឱកាសពិធីបុណ្យផ្សេងៗទៀត។

លើសពីនេះរាជរដ្ឋាភិបាល បានដាក់ចេញនូវគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព ក្នុងគោលបំណងធានាការពារសុខសុវត្ថិភាពជូនប្រជាពលរដ្ឋតាមខណ្ឌ ឃុំ សង្កាត់ ភូមិ នីមួយៗ មិនត្រឹមតែរក្សាការពារសុវត្ថិភាពរូបរាងកាយរបស់បុគ្គល ម្នាក់ៗនោះទេ ថែមទាំងទប់ស្កាត់មិនឱ្យកើតមាននូវអំពើអសន្តិសុខលើរបស់របរទ្រព្យសម្បត្តិដែលជាកម្លាំងញើសឈាមរបស់ ប្រជាពលរដ្ឋ និងមួយវិញទៀតគិតគូរលើសុខភាពអនាម័យរបស់ប្រជាជនថែមទៀតផង។ ជាការពិតណាស់ការការពារសន្តិសុខមិនបានសំដៅត្រឹមតែបរិបទសង្គមនោះទេប៉ុន្តែសន្តិសុខបានផ្តោតទៅលើសុវត្ថិភាព បីសំខាន់ៗ ដែលរួមមាន៖

**សុវត្ថិភាពបុគ្គល** គឺសំដៅដល់សុវត្ថិភាពរបស់បុគ្គលគ្រប់រូប និងសេរីភាពរបស់បុគ្គលម្នាក់ៗដែលគ្មានការបំពានពីសំណាក់បុគ្គលណាមួយឡើយ ដែលជាហេតុនាំមិនបណ្តាលឱ្យមានការបង្កបញ្ហានានាពេលគឺមានសុវត្ថិភាព និងមានការការពារជូនដល់ប្រជាពលរដ្ឋគ្រប់លំដាប់ថ្នាក់។ ម្យ៉ាងទៀតយើងអាចឱ្យនិយមន័យថា ការពារសុវត្ថិភាពបុគ្គល គឺសំដៅទៅលើទីកន្លែងដែលជាមជ្ឈមណ្ឌលមួយមានមនុស្សរស់នៅប្រកបដោយសេចក្តី

សុខទាំងផ្លូវកាយ ទាំងផ្លូវចិត្ត ឬសុវត្ថិភាពរូបរាងកាយរបស់បុគ្គលម្នាក់ៗត្រូវបានការពារ។ ដោយបញ្ចៀសមិនឱ្យមានការប៉ះពាល់ដល់រូបរាងកាយរបស់ប្រជាពលរដ្ឋដោយកត្តាមួយចំនួនដូចជាក្មេងទំនើងអំពើហិង្សាគ្រប់រូបភាព។ ជាមួយគ្នានេះផងដែរ ការជំរុញឱ្យមានការពង្រឹងខណ្ឌមានសុវត្ថិភាពនាំមកនូវ៖

១. គ្មានសកម្មភាពលួច ឆក់ប្លន់ គ្រប់ប្រភេទ
២. គ្មានការដាំដុះ ការផលិត ការចរាចរ ការជួញដូរ ការចែកចាយ និងការប្រើប្រាស់គ្រឿងញៀនខុសច្បាប់គ្រប់ប្រភេទ
៣. គ្មានអំពើអាណាចារ្យ ការជួញដូរស្ត្រី និងកុមារ និងអំពើហិង្សាក្នុងគ្រួសារ
៤. គ្មានក្មេងទំនើង
៥. គ្មានការលេងល្បែងស៊ីសងខុសច្បាប់គ្រប់ប្រភេទ ការប្រើប្រាស់អាវុធខុសច្បាប់គ្រប់ប្រភេទ និងបទល្មើស គ្រប់ប្រភេទ
៦. គ្មានគ្រោះថ្នាក់ចរាចរណ៍
៧. គ្មានគ្រោះថ្នាក់ដោយគ្រាប់យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ
៨. មានវិធានការណ៍ទប់ស្កាត់គ្រប់គ្រង និងការឆ្លើយតបចំពោះគ្រោះមហន្តរាយប្រកបដោយប្រសិទ្ធភាព
៩. មានការត្រួតពិនិត្យស្របតាមច្បាប់។

ក្នុងនោះបានជំរុញឱ្យមានការពង្រឹងនូវការអនុវត្ត ជាពិសេសផ្តោត សំខាន់លើការ គោរពច្បាប់ចរាចរណ៍ ព្រមទាំងរៀបចំនូវដំណោះស្រាយដោយធ្វើយ៉ាងណាឱ្យ គ្រោះថ្នាក់ចរាចរណ៍មានការថយចុះដោយមានការបែងចែកជាពីរផ្នែករួមមាន៖

- ប្រជាពលរដ្ឋគោរពច្បាប់ចរាចរណ៍
- ផ្សព្វផ្សាយច្បាប់ចរាចរណ៍ ឱ្យបានទូលំទូលាយដល់ប្រជាពលរដ្ឋ
- ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋពីផលប៉ះពាល់នៃការបើកបរមានជាតិស្រវឹង
- ជាកពិន័យតាមច្បាប់ ដែលបានកំណត់ដោយមិនមានការយោគយល់នូវគ្រឿងយន្តគ្មានគុណភាព
- ពន្យល់ប្រជាពលរដ្ឋឱ្យមានការយល់ដឹងពីផលប៉ះពាល់នៃការប្រើប្រាស់រថយន្តចាស់
- អនុវត្តច្បាប់ចំពោះប្រជាពលរដ្ឋដែលប្រើប្រាស់រថយន្តកែច្នៃមិនត្រឹមត្រូវតាមបច្ចេកទេស
- ផ្សព្វផ្សាយពីបច្ចេកទេសត្រួតពិនិត្យគ្រឿងយន្តដល់ប្រជាពលរដ្ឋ។ ព្រោះតែបញ្ហានេះតែងតែបង្កការឈឺចាប់ដល់រូបរាងកាយរបស់បុគ្គល ដែលទទួលរងគ្រោះក្នុងហេតុ ការណ៍ខ្លះប៉ះពាល់ ដល់អាយុជីវិតមនុស្សថែមទៀតទើបបានជំរុញឱ្យអាជ្ញាធរខណ្ឌមានជ័យមានការយកចិត្ត ទុកដាក់ជាសំខាន់។

**សុវត្ថិភាពចំណីអាហារ** ការបរិភោគអាហារវាពិតជាមានសារៈសំខាន់ណាស់សម្រាប់មនុស្សដើម្បីទ្រទ្រង់ រូបរាង្គកាយ ក៏ប៉ុន្តែប្រសិនបើទទួលទានអាហារដែលគ្មានគុណភាព ឬប្រើប្រាស់បច្ចេកទេសផលិតមិនត្រឹមត្រូវតាមស្តង់ដា វានឹងជះផលអាក្រក់ដល់សុខភាពជាទម្ងន់ ដូច្នេះរាល់អាហារដែលដាក់លក់នៅលើទីផ្សារត្រូវមានការត្រួត ពិនិត្យគុណភាព ក៏ដូចជាសុពលភាពរបស់មុខទំនិញនីមួយៗឱ្យបានជាក់លាក់។ ម៉្យាងវិញទៀតក្នុងនាមជា ប្រជាជនធម្មតា គឺមិនអាចមើលដឹងពីសមាសភាពផ្សំ ដែលប៉ះពាល់ដល់សុខភាពនោះទេ ដូចនេះវាបានក្លាយ ជាតួនាទីរបស់មន្ត្រីជំនាញក្នុងការពិនិត្យមើលលើអនាម័យចំណីអាហារដែលវាជាកិច្ចការពាក់

ព័ន្ធនឹងសមត្ថកិច្ច របស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អាចស្នើសុំសហការពីស្ថាប័នឯកទេសផ្សេងៗ។ ក្នុងនោះដែរមានដូច ជាក្រសួងសុខាភិបាល គឺនាយកដ្ឋានឱសថ គ្រឿងសំអាង ក្រសួងឧស្សាហកម្ម ក្រសួងបរិស្ថាន ក្រសួង កសិកម្ម គឺខាងនាយកដ្ឋានសេដ្ឋសាស្ត្រ ដែលគ្រប់គ្រងការនាំចេញថ្នាំសម្លាប់សត្វ និងការចាក់ថ្នាំបង្ការសត្វផង ដែរ និងក្រសួងជាច្រើនទៀត ដើម្បីការពារសុវត្ថិភាពខាងចំណីអាហារក៏ត្រូវការមន្ត្រីជំនាញពាក់ព័ន្ធដទៃទៀតផងដែរ។ បន្ថែមលើសពីនេះទៅទៀត កន្លងមក រាជរដ្ឋាភិបាលកម្ពុជា បានយកចិត្តទុកដាក់ចេញនូវអនុក្រឹត្យ និងលិខិតបទដ្ឋានមួយចំនួនដែលពាក់ព័ន្ធនឹង ការគ្រប់គ្រងគុណភាព សុវត្ថិភាព លើផលិតផលទំនិញ និងសេវា ជាពិសេសផលិតផលចំណីអាហារដែលនាំចូលពីបរទេស និងផលិតក្នុងស្រុកមួយចំនួន ដែលមានប្រើសារជាតិគីមី ដើម្បីក្លែងបន្លំគុណភាព។[22]

**សុវត្ថិភាពសម្ភារៈ** សុវត្ថិភាពសម្ភារៈនៅពេលនេះ គឺចង់បានន័យថាមិនត្រឹមតែមិនមានការ លួច ឆក់ប្លន់នោះទេ ពោល គឺមានសុវត្ថិភាពដល់សម្ភារៈដែលបម្រើដល់ការរស់នៅរបស់ប្រជាជនរួមមានដូចជាមិនមាននូវការគាស់ ផ្ទះ ផ្លោះរបង ឬការគាស់ទូរធនាគារ (ATM) ក្មេងទំនើង ល្បែងស៊ីសងតូចធំគ្រប់ប្រភេទ ឬសកម្មភាពផ្សេងទៀតដែលបង្កឱ្យមាន ភាពអសន្តិសុខ ដែលធ្វើឱ្យមានភាពភ័យខ្លាចដល់ការរស់នៅរបស់ប្រជាពលរដ្ឋផងដែរ។ ជាមួយគ្នា នេះក៏ត្រូវមានសន្តិសុខ សុវត្ថិភាព ដោយមានការឃាមល្បាតពីសំណាក់មន្ត្រីជំនាញប្រដាប់អាវុធឬមន្ត្រីជំនាញដែលពាក់ព័ន្ធបន្ថែមទៀត សម្រាប់ភាពកក់ក្តៅរបស់ប្រជាពលរដ្ឋជាមួយនឹងការការពារដោយការយកចិត្តទុកដាក់ខ្ពស់ជាមួយ និងបញ្ហា សន្តិសុខ។ ការគិតគូរបែបនេះ មិនត្រឹមតែធ្វើឱ្យប្រជាជនមានទំនុកចិត្តនោះទេ ថែមទាំងធ្វើឱ្យជនជាតិបរទេសក៏ មានការទុកចិត្តសម្រាប់ទៅសម្រាកលំហែរឬទស្សនាផងដែរ ជាពិសេសជាមួយផ្នែកទេសចរណ៍ដែលធ្វើឱ្យមានទំនុកចិត្តជាមួយ ដំណើរកម្សាន្ត។ លើសពីនេះទៅទៀតកាលណាពួកគាត់មាននូវសុវត្ថិភាពពេលចូលមកដល់ប្រទេសកម្ពុជា ចូល មកដល់ដែនដីខណ្ឌ នោះធ្វើឱ្យមានចំណាប់អារម្មណ៍កាន់តែខ្លាំងសម្រាប់ការងារ រកស៊ីបណ្តាក់ទុន ព្រោះជាប្រទេសមួយដែលមាន សុវត្ថិភាពដូច្នេះការរកស៊ីក៏មានសុវត្ថិភាពផងដែរ។ បើស្ថិតនៅក្នុងបរិបទ បែបនេះការវិនិយោគកាន់តែកើនឡើង ជាហេតុបណ្តាលឱ្យសេដ្ឋកិច្ចជាតិកាន់តែមានការរីកចម្រើន និងសង្គមជាតិមានការអភិវឌ្ឍ ជួយបង្កើនឱកាសការងារដល់ប្រជាពលរដ្ឋផងដែរតាមរយៈទេសចរណ៍ក៏ដូចជាការវិនិយោគទុនផ្សេងៗ។ ជាក់ស្តែងដើម្បីធានាឱ្យបាននូវសុវត្ថិភាពខាងផ្នែកសម្ភារៈលុះត្រាតែនៅក្នុងមូលដ្ឋាននោះគ្មានសកម្មភាពនៃការប្រព្រឹត្តបទល្មើសផ្សេងៗដូចជាៈ

- គ្មានសកម្មភាពភាពនៃការប្រព្រឹត្តអំពើជួញដូរ និងប្រើប្រាស់គ្រឿងញៀន ករណីគ្រឿងញៀនវាជាបញ្ហាដែល បង្កឲ្យភាពចលាចលដល់សង្គម ជាការពិតបុគ្គលដែលពាក់ព័ន្ធនឹងបញ្ហាគ្រឿងញៀននេះតែងតែមាននូវតម្រូវការថវិកា ច្រើនក្នុងការទិញ និងលក់នូវសារធាតុញៀននោះ។ ដោយសារមិនមានប្រាក់គ្រប់គ្រាន់ជាហេតុធ្វើឱ្យបុគ្គលទាំង នោះព្យាយាមរិះរកវិធីយ៉ាងណាដើម្បីទទួលប្រាក់ដែលខ្លួនត្រូវការពេលខ្លះឈានដល់ ការប្រើប្រាស់អំពើរអបាយមុខគំរាមគំហែងយកទ្រព្យរបស់អ្នកដទៃទៀតផង។

[22] សារាចរស្តីពី ការគ្រប់គ្រងគុណភាពនិងវិធានការត្រួតពិនិត្យគុណភាព សុវត្ថិភាព លើផលិតផល ទំនិញ និងចំណីអាហារ ដែលមានប្រើសារជាតិគីមី

- គ្មានអំពើលួច ឆក់ ប្លន់ និងការចាប់ជំរិតគ្រប់ប្រភេទ សំដៅក្នុងមូលដ្ឋានគ្មានការកំហែងយកទ្រព្យរបស់អ្នក ដទៃមកធ្វើជារបស់ខ្លួនដោយពុំមានការអនុញ្ញាតពីម្ចាស់នៃទ្រព្យនោះទេ ឬអំពើដែលអាចបណ្តាឱ្យម្ចាស់ទ្រព្យត្រូវ ទទួលរងនូវសកម្មភាពនៃអំពើរលោភបំពានផ្សេងៗថែមទៀតផង។
- គ្មានការលេងល្បែងស៊ីសងខុសច្បាប់ ការប្រព្រឹត្តល្បែងស៊ីសងតែងតែមានការភ្នាល់ដោយប្រើប្រាស់ប្រាក់ហើយគ្រប់ល្បែងស៊ីសងទាំងអស់តែងមានចាញ់ និងឈ្នះ។ ដូច្នេះជាធម្មតានៅពេលដែលមានការចាញ់ល្បែងបុគ្គលដែលប្រព្រឹត្តតែងតែចង់ស្រង់ដើមមកវិញ ដែលសកម្មភាពនេះអាចធ្វើឱ្យឈានដល់ការខាតបង់ទ្រព្យទាំងអស់ ហើយខណៈដែលមកដល់ផ្លូវទាល់ច្រក បុគ្គលមួយចំនួនច្បាស់ជាសម្លឹងឃើញទ្រព្យអ្នកដទៃ និងមានគំនិតចង់បានរបស់ទ្រព្យនោះរហូតដល់អាចប្រព្រឹត្តបទល្មើសផ្សេងៗផងដែរ។

### ២.២.២. ភាពស្ងប់ស្ងាត់

ភាពស្ងប់ស្ងាត់គឺសំដៅទៅលើទីកន្លែងទាំងឡាយណា ដែលមិនអនុញ្ញាតមិនឲ្យមានការរំខានដោយសំឡេងតាមរយៈការហាមឃាត់មិនឲ្យសាងសង់សំណង់រោងចក្រ សហគ្រាស នៅជិតជាមួយលំនៅដ្ឋានរបស់ប្រជាពលរដ្ឋ សាលារៀន មន្ទីរពេទ្យ ជាដើម ពីព្រោះវាបង្កការរំខានដោយសម្លេងដល់បងប្អូនប្រជាពលរដ្ឋ ។

### ២.២.៣. ផាសុកភាព

ផាសុកភាពសំដៅទៅលើភាពដែលមានសេចក្តីសុខ សេចក្តីសប្បាយគ្មានមន្ទិលសង្ស័យ ស្រស់ស្រាយ សុខកាយ សប្បាយចិត្ត ល្អស្អាតបរិសុទ្ធ មិនធុញថប់ មិនរសាប់រសល់ ។ ដោយយោងតាមវចនានុក្រមសម្តេចព្រះសង្ឃរាជ ជួន ណាត ផាសុកភាពសំដៅលើសេចក្តីសុខ សេចក្តីសម្រាន្ត សេចក្តី សប្បាយ។ ដូច្នេះពាក្យ ផាសុកភាពនេះជារួមមានន័យថា ភាពប្រកបដោយសេចក្តីសុខ និងសប្បាយ។ ដើម្បីទទួលបាននូវផាសុកភាពមួយដែលជាទីគាប់ចិត្តលុះត្រាតែ អនាម័យ បរិស្ថាន មានភាពល្អ ប្រសើរផងដែរ។ ម៉្យាងវិញទៀតបញ្ហាប្រឈមនេះពាក់ព័ន្ធនឹងការរៀបចំទីក្រុងដែលវាមានសារៈសំខាន់ណាស់ ក្នុងការផ្តល់ នូវផាសុកភាពដល់ប្រជាពលរដ្ឋ តាមរយៈការផ្តល់សេវាសុខភាពសាធារណៈ និងការគ្រប់គ្រងស្ថានភាពបរិស្ថានផង ដែរ។

ជាទូទៅទីក្រុងជាទីប្រជុំជន ដែលមានការប្រមូលផ្តុំនូវចំនួនប្រជាជនច្រើនជាងតាមជនបទ ជាពិសេសមានដំណើរការសកម្មភាពផ្សេងៗជាច្រើន ដែលបណ្តាលឱ្យក្រុងងាយ ទទួលរងនូវផលប៉ះពាល់ពីការបំពុល

បរិស្ថាន កើតចេញពីរោងចក្រសិប្បកម្ម ឧស្សាហ៍កម្ម សហគ្រាសដោយបានបញ្ចេញនូវ កាកសំណល់រឹងរាវផ្សេងៗ។ ដូចបានរៀបរាប់ដើម្បីទទួលបាននូវ ផាសុកភាព លុះណាតែមានការយកចិត្តទុកដាក់ និងផ្តោតសំខាន់ទៅលើអនាម័យដែលសម្តៅទៅលើបរិស្ថាន ស្អាត ដោយគ្មានការបំពុលទាំង៥ ។

### ២.២.៤. ផ្លូវគមនាគមន៍

ផ្លូវ គឺជាអាទិភាពគន្លឹះទី២ នៅក្នុងអាទិភាពគន្លឹះទាំង៥ "មនុស្ស ផ្លូវ ទឹក ភ្លើង និងបច្ចេកវិទ្យា" នៃយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី ៧ ដោយកិច្ចការអាទិភាពទី២ ក្នុងបញ្ចកោណទី២ គឺការលើកកម្ពស់ការតភ្ជាប់ និងការបង្កើនប្រសិទ្ធភាពនៃវិស័យដឹកជញ្ជូន បានផ្តោតគោលដៅយុទ្ធសាស្ត្រលើការបង្កើនប្រសិទ្ធភាពហេដ្ឋារចនាសម្ព័ន្ធគាំទ្រ, ការកសាង និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធថ្មី ។ សមិទ្ធផលនេះ ក៏នឹងជួយកាត់បន្ថយចំណាយលើឥន្ទនៈដោយសារការកកស្ទះ ចំណេញពេលវេលា និងសម្រួល

ដល់ការធ្វើដំណើរប្រកបការងារ ជាពិសេស ការជួយលើកកម្ពស់ការកសាងសេដ្ឋកិច្ចមូលដ្ឋានរបស់ប្រជាពលរដ្ឋផងដែរ។[23]

ការកសាងគមនាគមន៍ គឺជាការបង្កើតសរសៃឈាមនៃសេដ្ឋកិច្ចជាតិ វិស័យគមនាគមន៍ គឺជាសរសៃឈាមសេដ្ឋកិច្ចជាតិ ដ៏សំខាន់មិនអាចខ្វះបាន សម្រាប់បម្រើដល់មធ្យោបាយសេវាដឹកជញ្ជូន និងការធ្វើដំណើររបស់ប្រជាពលរដ្ឋ[24]។

ហេដ្ឋារចនាសម្ព័ន្ធត្រូវតែពង្រឹងនិងលើកកម្ពស់ឱ្យដល់កម្រិតសម្រាប់បម្រើវិស័យ វប្បធម៌ សាសនា សេដ្ឋកិច្ច សង្គម ទេសចរណ៍ ពាណិជ្ជកម្ម និងបរិស្ថានក្នុងខណ្ឌមានជ័យរួមមាន៖

**ផ្លូវថ្នល់**

- បន្តការកសាងផ្លូវ តាមបណ្តោយច្រាំងទន្លេបាសាក់ចាប់ពីព្រំប្រទល់ទីរួមខេត្តកណ្តាលរហូតដល់គល់ស្ពានព្រះមុនីវង្សដើម្បីចូលរួមអភិវឌ្ឍវិស័យទេសចរណ៍ សុខុមាលភាព និងសោភ័ណភាពរាជធានីភ្នំពេញ
- បន្តរៀបចំផ្លូវឱ្យល្អប្រណីត អមដោយដើមផ្កាអមសងខាងផ្លូវនិងសួនពុះចែកទ្រូងផ្លូវ ចិញ្ចើមផ្លូវ ផ្លូវថ្មើរជើង ផ្លូវសម្រាប់ជនមានពិការភាព គន្លងផ្លូវទោចក្រយាន បរិក្ខារផ្លូវថ្នល់ដែលមានបរិស្ថាន ធម្មជាតិស្រស់បំព្រង បង្គោលភ្លើងបំភ្លឺផ្លូវ និងភ្លើងលម្អប្រកបដោយក្បូរក្បាច់រចនាបថខ្មែរនិងធម្មជាតិ សក្តានុពលទាក់ទាញភ្ញៀវទេសចរនិងអ្នកដំណើរឆ្លងកាត់
- សាងសង់ស្ពានរំលងវិថីសំខាន់ៗនិងផ្លូវដែលមានចរាចរណ៍មមាញឹកដើម្បីសម្រួលនិងបញ្ចៀស គ្រោះថ្នាក់ចរាចរណ៍
- សិក្សាការបើកផ្លូវ ផ្លូវត្រឡប់ក្រោយច្រកផ្លូវ និងពង្រីកទ្រូងផ្លូវបន្ថែមដើម្បីងាយស្រួលដល់ចរាចរណ៍សាធារណៈ ការធ្វើអភិបាលកិច្ចល្អនិងនគរូបនីយកម្មល្អ
- បន្តកែលម្អបណ្តាញផ្លូវមេសំខាន់ៗ ជាផ្លូវឯកទិសដោយសាងសង់ស្ពានអាកាសនៅចំណុចប្រសព្វផ្លូវឆ្លងកាត់ស្របតាមការវិវឌ្ឍនៃចរាចរណ៍ក្នុងរាជធានីភ្នំពេញ ដើម្បីសម្រួលចរាចរណ៍ រៀបចំគន្លងផ្លូវរថយន្តសាធារណៈនៅតាមផ្លូវសំខាន់ៗ និងតំបន់ទីប្រជុំជនដើម្បីសម្រួលដល់ការធ្វើ ចរាចរណ៍នៃរថយន្តសាធារណៈក៏ដូចជាលើកទឹកចិត្តប្រជាជនឱ្យប្រើប្រាស់សេវារថយន្តសាធារណៈ
- សិក្សារៀបចំទីតាំងចំណតរថយន្តក្រោមដីដើម្បីបញ្ចៀសការកកស្ទះចរាចរណ៍

---

[23] https://www.ppreporter.com/article/376919 ទំព័រចុះផ្សាយក្នុង Phnom Penh Reporter

[24] https://www.mpwt.gov.kh/kh/press/8021 គេហទំព័រ ក្រសួងសាធារណការ និង ដឹកជញ្ជូន ដកស្រង់ថ្ងៃទី ០១ ខែមិថុនា ឆ្នាំ ២០២៤

- ជំរុញអនុវត្តសេចក្តីសម្រេចលេខ០៣៩ សសរ ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីការដាក់ឱ្យប្រើប្រាស់ប្លង់ស្តាបត្យកម្មចិញ្ចើមផ្លូវ ផ្លូវថ្មើរជើង និងគន្លងផ្លូវទោចក្រយានសម្រាប់សាធារណជននិង ជនមានពិការភាព ដើម្បីធានាសោភ័ណភាពសាធារណៈនិង ការធ្វើចរាចរណ៍ប្រកបដោយសុវត្ថិភាព សុខុមាលភាពនិងភាពងាយស្រួលដល់សាធារណជននិងជនមានពិការភាព
- រៀបចំកំណត់កម្ពស់ផ្លូវនិងចិញ្ចើមផ្លូវដោយមានកម្ពស់ ០,២ម៉ែត្រធៀបជាមួយនឹងកម្រិតកម្ពស់ទ្រូង ផ្លូវមានមុំជម្រាល ០,១% និងមានបទដ្ឋានបច្ចេកទេសតែមួយដើម្បីមានភាពងាយស្រួលសម្រាប់ អ្នកថ្មើរជើងនិងធានាបាននូវសុវត្ថិភាព។

**ផ្លូវទឹក**

- ការពារដីចំណីទន្លេ និងការពារថែរក្សាផ្ទៃទឹកទន្លេពីការសាងសង់សំណង់ផ្សេងៗដែលប៉ះពាល់ដល់ ការធ្វើចរាចរណ៍ផ្លូវទឹក
- សិក្សាការចាក់ដីបំពេញដីឡូត៍នៅតាមតំបន់ងាយលិចលង់ ដែលតម្រូវឱ្យម្ចាស់ស្នើសុំលិខិតអនុញ្ញាតអភិវឌ្ឍដីជាមុនសិន
- សិក្សាសំណង់ច្រាំងទន្លេដើម្បីការពារការបាក់ស្រុតដីច្រាំង ចូលក្នុងទឹកទន្លេដែលធ្វើឱ្យជម្រៅទឹកកាន់តែរាក់ដែលនឹងប៉ះពាល់ដល់ការធ្វើចរាចរណ៍ផ្លូវទឹក
- សិក្សាប្រព័ន្ធចរាចរណ៍ផ្លូវទឹកនិងរៀបចំផ្លូវទឹកតាមដងទន្លេមេគង្គនិង ទន្លេបាសាក់ដោយរៀបចំឱ្យមានប្រព័ន្ធដឹកជញ្ជូនតាមផ្លូវទឹក និងសិក្សាការបូមដីពីបាតទន្លេដែលធ្វើឱ្យរាំងស្ទះដល់ការធ្វើចរាចរណ៍ តាមផ្លូវទឹកស្របតាមបទដ្ឋានបច្ចេកទេសនិងកិច្ចការពារបរិស្ថានបាតទន្លេ
- សិក្សារៀបចំភ្លើងបំភ្លឺតាមបណ្តោយច្រាំងទន្លេដែលស្ថិតក្នុង ខណ្ឌមានជ័យដើម្បីសម្រួលដល់ការធ្វើចរាចរណ៍ផ្លូវទឹកនិងបម្រើដល់វិស័យទេសចរណ៍
- សិក្សាគម្រោងប្លង់ដែលមានសោភ័ណភាពល្អប្រពៃ ទាក់ទាញសម្រាប់ការអភិវឌ្ឍនិង ការសាងសង់កំពង់ផែ និងចំណតសម្រាប់ការធ្វើដំណើរ ទេសចរណ៍ និងការលើកដាក់ទំនិញតាមច្រាំងទន្លេ។

**ផ្លូវអាកាស**

- រក្សាលម្ហអាកាសពីការសាងសង់សំណង់ផ្សេងៗដោយកំណត់ កម្ពស់សំណង់ក្នុងតំបន់គ្រប់គ្រងកម្ពស់ឧបសគ្គនៃអាកាសយានដ្ឋានអន្តរជាតិភ្នំពេញស្របតាមព្រះរាជក្រមលេខ នស/រកម/០១០៨/០០៣ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីអាកាសចរស៊ីវិលនៃព្រះរាជាណាចក្រ កម្ពុជា
- ពិនិត្យលទ្ធភាពអនុញ្ញាតឱ្យមន្ទីរពេទ្យដែលត្រូវរៀបចំឱ្យមានចំណតឧទ្ធម្ភាគចក្រ និងនិមិត្តសញ្ញាពេទ្យនៅលើដំបូលអគារដើម្បីជួយសង្គ្រោះបន្ទាន់
- បំពាក់ភ្លើងសញ្ញាពណ៌ក្រហមនៅតាមជ្រុងនៃអគារ ដែលមានកម្ពស់ខ្ពស់ តាមបទដ្ឋានបច្ចេកទេសរបស់អាកាសចរស៊ីវិល។

### ២.២.៥. សំណង់

អនុលោមតាមអនុក្រឹត្យលេខ៨២ អនក្រ.បក ចុះថ្ងៃទី៣ ខែមេសា ឆ្នាំ២០១៥ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន អនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ និង អនុក្រឹត្យលេខ១៨១ អនក្រ.បក ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីការដាក់ឱ្យអនុវត្តប្លង់គោលប្រើប្រាស់ដីរាជធានីភ្នំពេញ ចក្ខុវិស័យឆ្នាំ២០៣៥ ខណ្ឌមានជ័យត្រូវបានកំណត់ការប្រើប្រាស់ដីជាពីរប្រភេទគឺប្រភេទដីអាចសាងសង់ បាននិងប្រភេទដីកម្រិតការសាងសង់។

**-ប្រភេទដីអាចសាងសង់បាន**

ខណ្ឌមានជ័យមានផ្ទៃដីសរុបប្រមាណ២ ៤៩០,៤៤ហិកតា ក្នុងនោះប្រភេទដីអាចសាងសង់បានមានផ្ទៃដី ប្រមាណ២ ២២៥,៩៤ហិកតាស្មើនឹង៨៩,៣៨%នៃផ្ទៃដីសរុប។ ប្រភេទដីអាចសាងសង់បាន ត្រូវបានរៀបចំ និង បែងចែកជាតំបន់ដូចមានក្នុងផែនទីប្លង់គោលឧបសម្ព័ន្ធ ដូចខាងក្រោម៖

១) តំបន់លំនៅឋានមានផ្ទៃដីប្រមាណ១ ១៣៧,១៨ហិកតាស្មើនឹង៥១, ០៩%នៃផ្ទៃដីអាចសាងសង់បាន។ តំបន់លំនៅឋានត្រូវបានបែងចែកបន្តដូចខាងក្រោម៖

- តំបន់លំនៅឋានដាច់ពីគ្នាដែលមានកម្ពស់ទាប (ត្រឹមជាន់ទី២) ស្ថិតនៅផ្នែកខាងលិចទល់ភូមិ ក្បាលទំនប់ ខាងជើងទល់មហាវិថីយោធពលខេមរភូមិន្ទ (លេខ២៧១) ខាងកើតទល់រួមប្រឡាយ ជើងឯក ខាងត្បូងទល់មហាវិថីអ្នកឧកញ៉ាមហាភក្តីសប្បុរសភោគធិបតី ហ៊ុន នាង វិមានសុភមង្គល ភូមិឫស្សី១ បុរីប៉េងហួតដីស្ការអិតធីណល (អតីតស្ថានីយទូរទស្សន៍ជាតិស្ទឹងមានជ័យ) ភូមិដំណាក់ធំ១ និងបុរីនានាក្នុងភូមិដំណាក់ធំ៣ មានផ្ទៃដីប្រមាណ៣៥៥, ៥៣ហិកតាស្មើនឹង១៥, ៩៧% នៃ ផ្ទៃដីអាចសាងសង់បាន ត្រូវមានសន្ទស្សន៍ប្រើប្រាស់ដីអតិបរមា១, ៥ និងផលធៀបផ្ទៃក្រឡាបាត សំណង់ធៀបនឹងផ្ទៃដីឡូត៍អតិបរមា៥0%
- តំបន់លំនៅឋានដែលមានកម្ពស់មធ្យមប្រភេទទី២ (ត្រឹមជាន់ទី១១) ស្ថិតនៅផ្នែកខ្លះក្នុងសង្កាត់ ស្ទឹងមានជ័យទី៣ ភូមិទ្រា៤ និងសង្កាត់ស្ទឹងមានជ័យទី១ ភូមិទ្រា៣ ភូមិទ្រា២ និងភូមិត្រា១ មាន ផ្ទៃដីប្រមាណ១៤៨, ៧៧ហិកតាស្មើនឹង៦,៦៨% នៃផ្ទៃដីអាចសាងសង់បាន ត្រូវមានសន្ទស្សន៍ ប្រើប្រាស់ដីអតិបរមា៣,0 និងផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍អតិបរមា៦0%
- តំបន់លំនៅឋានដែលមានកម្ពស់ខ្ពស់ប្រភេទទី១ (ត្រឹមជាន់ទី១៨) ស្ថិតនៅផ្នែកខ្លះក្នុងសង្កាត់ ស្ទឹងមានជ័យទី១ ភូមិទ្រា ភូមិថ្មី ភូមិមានជ័យ១ និងភូមិមានជ័យ២ សង្កាត់ស្ទឹងមានជ័យទី៣ ភូមិ ឫស្សី១ ភូមិឫស្សី២ និងភូមិដំណាក់ធំ៥ និងសង្កាត់ស្ទឹងមានជ័យទី២ ភូមិត្នោត ភូមិដំណាក់ធំ៤ និងចំហៀងខាងលិចនៃភូមិដំណាក់ធំមានផ្ទៃដីប្រមាណ១៤១, ៩២ហិកតាស្មើនឹង៦, ៣៨%នៃផ្ទៃដី អាចសាងសង់បាន ត្រូវមានសន្ទស្សន៍ប្រើប្រាស់ដីអតិបរមា៥,0 និងផលធៀបផ្ទៃក្រឡាបាតសំណង់ ធៀបនឹងផ្ទៃដីឡូត៍អតិបរមា៦0%
- តំបន់លំនៅឋានចម្រុះស្ថិតនៅផ្នែកខ្លះក្នុងសង្កាត់ស្ទឹងមានជ័យទី២ ចំហៀងខាងកើតនៃភូមិ ដំណាក់ធំ ភូមិព្រែកទាល់១ ភូមិព្រែកទាល់ មួយចំណែកខាងកើតនៃភូមិត្នោត សង្កាត់ស្ទឹងមានជ័យទី២ភូមិ

ដំណាក់ធំ១ ភូមិឫស្សី៣ ភូមិឫស្សី សង្កាត់បឹងទំពុនទី១ ភូមិចំរើនផល ភូមិចំរើនផល១ ភូមិ ចំរើនផល២ ភូមិចំរើនផល៣និងសង្កាត់បឹងទំពុនទី១ ភូមិចំរើនផល៤ ភូមិសន្សំកុសល៦ ភូមិ សន្សំកុសល៥ ភូមិសន្សំកុសល៤ ភូមិសន្សំកុសល៣ ភូមិសន្សំកុសល២ ភូមិសន្សំកុសល១ និង សង្កាត់បឹងទំពុនទី២ ភូមិត្នោតជ្រុំ ភូមិត្នោតជ្រុំ១ ភូមិត្នោតជ្រុំ២ ភូមិត្នោតជ្រុំ៣ ភូមិត្នោតជ្រុំ៤ ភូមិត្នោតជ្រុំ៥ ភូមិត្នោតជ្រុំ៦ ភូមិក្បាលទំនប់ ភូមិក្បាលទំនប់១ ភូមិក្បាលទំនប់២ និងភូមិក្បាល ទំនប់៣មានផ្ទៃដីប្រមាណ៤៩០, ៩៦ ហិកតាស្មើនឹង២២, ០៦% នៃផ្ទៃដីអាចសាងសង់បាន ត្រូវមាន សន្ទស្សន៍ប្រើប្រាស់ដីអតិបរមា៥,0 និង ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍អតិបរមា៦៥% ។

២) តំបន់ពាណិជ្ជកម្មចម្រុះស្ថិតនៅជុំវិញផ្សារស្ទឹងមានជ័យតាមបណ្តោយផ្លូវលេខ២៧១-២០ មានផ្ទៃដីប្រមាណ៧២, ២៨ហិកតាស្មើនឹង៣, ២៥%នៃផ្ទៃដីអាចសាងសង់បាន ត្រូវមានសន្ទស្សន៍ប្រើប្រាស់ដី អតិបរមា ១០,0 និងផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍អតិបរមា៧0%។

៣) តំបន់ឧស្សាហកម្មមានផ្ទៃដីប្រមាណ២៧៣, ៣៥ហិកតាស្មើនឹង១២,២៨%នៃផ្ទៃដីអាចសាងសង់បាន។ តំបន់ឧស្សាហកម្មត្រូវបានបែងចែកបន្តដូចខាងក្រោម៖

- តំបន់ឧស្សាហកម្មស្ថិតនៅតាមបណ្តោយផ្លូវជាតិលេខ២ផ្នែកខាងលិចចាប់ពីមហាវិថីយោធពល ខេមរភូមិន្ទ (លេខ២៧១) ខាងកើតទល់ប្រឡាយជើងឯក ខាងត្បូងទល់មហាវិថីអ្នកឧកញ៉ាមហា ភក្តីសប្បុរសភោគធិបតី ហ៊ុន នាង ទល់ព្រំប្រទល់រដ្ឋបាលរវាងរាជធានីភ្នំពេញនិងខេត្តកណ្តាល មានផ្ទៃដីប្រមាណ៩០,៤៥ហិកតាស្មើនឹង៤, ០៦% នៃផ្ទៃដីអាចសាងសង់បាន ត្រូវមានសន្ទស្សន៍ ប្រើប្រាស់ដីអតិបរមា៣,0 និងផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍អតិបរមា៦0%
- តំបន់ឧស្សាហកម្មស្រាលស្ថិតនៅអតីតរោងចក្រភួយ សង្កាត់ស្ទឹងមានជ័យទី១ ភូមិថ្មី និងសង្កាត់ ស្ទឹងមានជ័យទី៣ ភូមិដំណាក់ធំ៣ និងភូមិដំណាក់ធំ២មានផ្ទៃដីប្រមាណ១៧៩,៥៣ហិកតា ស្មើនឹង ៨,0៧% នៃផ្ទៃដីអាចសាងសង់បាន ត្រូវមានសន្ទស្សន៍ប្រើប្រាស់ដីអតិបរមា៣,0 និង ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍អតិបរមា៦0%
- តំបន់ឧស្សាហកម្មចម្រុះស្ថិតនៅអតីតរោងចក្រភួយ សង្កាត់ស្ទឹងមានជ័យទី២ និងសង្កាត់ ស្ទឹងមានជ័យទី៣ មានផ្ទៃដីប្រមាណ៣, ៣៧ហិកតាស្មើនឹង0,១៥% នៃផ្ទៃដីអាចសាងសង់បាន ត្រូវមានសន្ទស្សន៍ប្រើប្រាស់ដីអតិបរមា៣,0 និងផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍ អតិបរមា៦0% ។

៤) តំបន់ចម្រុះស្ថិតនៅតាមបណ្តោយមហាវិថីខេមរភូមិន្ទ (លេខ២៧១) សង្កាត់ស្ទឹងមានជ័យទី១ ភូមិមានជ័យ១ ភូមិមានជ័យ២ តាមបណ្តោយផ្លូវជើងឯក (៨.១២០) ចម្ងាយ៣០0ម៉ែត្រឬមួយ ជម្រៅក្បាលដី តាមបណ្តោយផ្លូវ៩អឹមសេ (ពុំនូកសំរាមស្ទឹងមានជ័យ) ចម្ងាយ៣០0ម៉ែត្រឬមួយ ជម្រៅក្បាលដី តាមបណ្តោយមហាវិថីសម្តេចមុនីរ៉េត (លេខ២១៧) ចម្ងាយ៣០០ម៉ែត្រឬមួយ ជម្រៅក្បាលដី តាមបណ្តោយផ្លូវទំនប់ថ្មី (លេខ៣៧១) ចម្ងាយ៣០0ម៉ែត្រឬមួយជម្រៅក្បាលដី មានផ្ទៃដីប្រមាណ៤០៥, ៥២ហិកតាស្មើនឹង១៨, ២២% នៃផ្ទៃដីអាចសាងសង់បាន ត្រូវមានសន្ទស្សន៍ ប្រើប្រាស់ដីអតិបរមា១០,0 និងផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍អតិបរមា៧0%។

៥) តំបន់ទេសចរណ៍ស្ថិតនៅតាមបណ្ដោយទន្លេបាសាក់ ចាប់ពីស្ពានព្រះមុន្នីវង្សទល់ព្រំប្រទល់រដ្ឋបាលរវាង រាជធានីភ្នំពេញនិងខេត្តកណ្ដាលនិងតំបន់ជុំវិញបឹងជើងឯកមានផ្ទៃដីប្រមាណ១០៨,៥២ហិកតាស្មើនឹង៤, ៨៨% នៃផ្ទៃដីអាចសាងសង់បាន ត្រូវមានសន្ទស្សន៍ប្រើប្រាស់ដីអតិបរមា៥, ០ និង ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍អតិបរមា៥០%។

៦) តំបន់ដឹកជញ្ជូនមានបណ្ដាញផ្លូវ និងចំណតរថយន្តក្រុងមានផ្ទៃដីប្រមាណ១៨២,០៣ហិកតាស្មើនឹង ៨,១៨% នៃផ្ទៃដីអាចសាងសង់បាន ត្រូវមានសន្ទស្សន៍ប្រើប្រាស់ដីអតិបរមា៣,០ ផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍អតិបរមា៦០%។

៧) តំបន់រដ្ឋបាលនិងសេវាសាធារណៈមានវិទ្យាល័យជាស៊ីមសាមគ្គី អនុវិទ្យាល័យចំរើនផល សាលាបឋមសិក្សាស្ទឹងមានជ័យ និងអនុវិទ្យាល័យ ហ៊ុន សែន ចាក់អង្រែមានផ្ទៃដីប្រមាណ៣, ៣០ហិកតា ស្មើនឹង ០,១៥%នៃផ្ទៃដីអាចសាងសង់បាន ត្រូវមានសន្ទស្សន៍ប្រើប្រាស់ដីអតិបរមា៥,០ និងផលធៀប ផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍អតិបរមា៦០%។

៨)តំបន់លម្ហសាធារណៈនិងផ្ទៃបៃតងស្ថិតនៅតាមច្រាំងទន្លេបាសាក់ ចំណុចប្រសព្វមហាវិថីមហាឧបាសក-សិកា ឈុន គង់ និងមហាវិថីសម្ដេច ហ៊ុន សែន សួនក្បាលថ្នល់ ទទឹង៣០ម៉ែត្រជុំវិញ បឹងទំពុនខាងកើត និងទទឹង៣០ម៉ែត្រជុំវិញបឹងទំពុនខាងលិចមានផ្ទៃដីប្រមាណ៣០, ៧១ហិកតាស្មើ នឹង១,៣៨% នៃផ្ទៃដីអាចសាងសង់បាន។ ជំរុញរៀបចំនិងអភិវឌ្ឍសួនសាធារណនិងសួនក្នុងតំបន់ លំនៅឋានបន្ថែមឱ្យបានយ៉ាងតិច ១០% នៃផ្ទៃដីអាចសាងសង់បាននៅឆ្នាំ២០៣៥

៩) តំបន់វប្បធម៌និងសាសនាមានវត្តចង្រ្កានតាព្រហ្មស្ទឹងមានជ័យ វត្តនន្ទមុនី វត្តពោធិញាណ វត្តសន្សំកុសល វត្តដំបូកខ្ពស់ វត្តចាក់អង្រែលើ និងវត្តចាក់អង្រែក្រោមមានផ្ទៃដីប្រមាណ១៣,០៤ហិកតាស្មើនឹង ០,៥៩% នៃផ្ទៃដីអាចសាងសង់បាន ត្រូវមានសន្ទស្សន៍ប្រើប្រាស់ដីអតិបរមា២,០ និងផលធៀបផ្ទៃ ក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍អតិបរមា៥០%។

សន្ទស្សន៍ប្រើប្រាស់ដីអតិបរមា ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍ សួនច្បារជ្រាបទឹក ដាំ ដើមឈើ ជួរតម្រង់ ឆ្លាតម្លាត កម្ពស់សំណង់ ចំណតរថយន្ត អាងបង្គន់អនាម័យ អាងប្រព្រឹត្តិកម្មទឹកកខ្វក់ ពណ៌ អគារ សោភណភាព និងរចនាបថស្ថាបត្យកម្មខ្មែរនិង/ឬលក្ខណៈធម្មជាតិនៃតំបន់នីមួយៗដូចបានកំណត់ខាងលើ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវស្របតាមបទប្បញ្ញត្តិជាធរមាន។

**ប្រភេទដីកម្រិតការសាងសង់**

ប្រភេទដីកម្រិតការសាងសង់មានផ្ទៃដីប្រមាណ២៦៤, ៥០ហិកតាស្មើនឹង១០,៦២% នៃផ្ទៃដីសរុប។ ប្រភេទដី ការសាងសង់ ត្រូវបានរៀបចំនិងបែងចែកជាតំបន់ដូចមានក្នុងផែនទីប្លង់គោលឧបសម្ព័ន្ធ ដូចខាងក្រោម៖

១) តំបន់ធនធានទឹក៖ មានតំបន់ទន្លេបាសាក់មានផ្ទៃដីប្រមាណ៨០,០០ហិកតា តំបន់បឹងទំពុនខាងលិច មានផ្ទៃដីប្រមាណ២៥, ៣២ហិកតា តំបន់បឹងទំពុនខាងកើតមានផ្ទៃដីប្រមាណ៨, ៣១ហិកតា តំបន់ បឹង

ជើងឯកមានផ្ទៃដីប្រមាណ៩៩,៤២ហិកតា និងប្រឡាយបឹងទំពុនមានផ្ទៃដីប្រមាណ៣៣,០០ហិកតាមានផ្ទៃដីប្រមាណ២៤៥, ៨៨ហិកតាស្មើនឹង៩២, ៩៦%នៃផ្ទៃដីកម្រិតការសាងសង់។

២) ផ្ទៃដីកម្រិតការសាងសង់ផ្សេងទៀត៖ ជាតំបន់បំរុងសម្រាប់អភិវឌ្ឍនិងសាងសង់ស្ថានីយប្រព្រឹត្តិកម្មទឹកកខ្វក់ភាគខាងត្បូងនៃរាជធានីភ្នំពេញមានផ្ទៃដីប្រមាណ១៨,៦២ហិកតាស្មើនឹង៧, ០៤% នៃផ្ទៃដីកម្រិតការសាងសង់។

## ២.២.៦. ការរៀបចំបរិស្ថាននិងការគ្រប់គ្រងសំណល់ក្នុងខណ្ឌមានជ័យ

ដោយយោងតាម យុទ្ធសាស្ត្រការពារបរិស្ថាននិងគ្រប់គ្រងសំណល់ និង ការបែងចែកតំបន់ប្រើប្រាស់ដីសម្រាប់ការការពារបរិស្ថានកំណត់និងបែងចែកតំបន់ ប្រើប្រាស់ដីសម្រាប់ទុកដាក់សំណល់រឹងតាមគ្រប់ទីតាំងផ្សារ ទីតាំងបុរី តាមភូមិ តាមខ្នងផ្ទះ និងតាមគ្រឹះស្ថានសាធារណៈនិងឯកជនដោយមានការទុកដាក់បានត្រឹមត្រូវតាមបទដ្ឋានកំណត់និងតាមតំបន់ផ្សេងៗរួមមាន៖

- តំបន់សួនច្បារប្រសព្វមហាវិថីសម្តេច ហ៊ុន សែន និងមហាវិថីឧបាសក-សិកា ឈុន គង់
- តំបន់តាមដងផ្លូវសាធារណៈ
- តំបន់តាមដងទន្លេ ប្រឡាយ និងបឹង
- តំបន់សហគមន៍។

**វិធានការចាំបាច់ក្នុងការការពារតំបន់សំខាន់ៗ**

- ការពារនិងថែរក្សាតំបន់ច្រាំងទន្លេ បឹង ប្រឡាយ សួនជ្រាបទឹក និងដើមឈើតាមទីសាធារណៈ
- ការពារនិងថែរក្សាបណ្តាញទឹកស្អាតនិងបណ្តាញលូស្របតាមបទប្បញ្ញត្តិជាធរមាន
- ការពារនិងថែរក្សាទន្លេបាសាក់ដើម្បីធានាប្រព័ន្ធអេកូឡូស៊ីនិងជីវចម្រុះ
- កាត់បន្ថយការបំពុលខ្យល់ដោយសារម៉ាស៊ីនភ្លើងតាមរយៈ ការផ្គត់ផ្គង់អគ្គិសនីរដ្ឋ និងថាមពលពន្លឺព្រះអាទិត្យឱ្យបានច្រើន
- លើកកម្ពស់ការប្រើប្រាស់មធ្យោបាយដឹកជញ្ជូនដែលមិនបំពុលបរិស្ថាន
- បង្កើតគណៈកម្មាធិការត្រួតពិនិត្យបរិស្ថានមានប្រសិទ្ធភាពមួយ នៅថ្នាក់ខណ្ឌនិងលើកកម្ពស់ចំណេះដឹងរបស់ប្រជាជនអំពីបរិស្ថាន
- រៀបចំឱ្យមានមូលនិធិសម្រាប់ថែទាំបរិស្ថាននិងជំរុញការវិនិយោគរបស់រដ្ឋនិងវិស័យឯកជន។

**ការគ្រប់គ្រងសំណល់រឹង**

- ពង្រឹងយន្តការនិងហេដ្ឋារចនាសម្ព័ន្ធក្នុងការគ្រប់គ្រងសំណល់រឹង
- រៀបចំទីតាំងសម្រាប់ទុកដាក់សំណល់រឹង តាមទីសាធារណៈ និងតាមលំនៅឋានរបស់ប្រជាពលរដ្ឋស្របតាមបទដ្ឋានបច្ចេកទេសនិងស្តង់ដាទីក្រុងស្អាត
- ជំរុញឱ្យមានការអនុវត្ត គោលការណ៍កាត់បន្ថយការប្រើប្រាស់ ការប្រើប្រាស់ឡើងវិញ និងការកែច្នៃប្រើប្រាស់ឡើងវិញ

- ជំរុញកំណត់តំបន់គ្មានសំរាមតាមទីតាំងសំខាន់ៗ ដើម្បីលើកកម្ពស់សោភណភាពទីក្រុងនិងសុខភាពសាធារណៈ។

**ការគ្រប់គ្រងសំណល់រាវនិងទឹកកខ្វក់**

- រៀបចំកែលម្អនិងពង្រីកបន្ថែមប្រព័ន្ធលូទឹកភ្លៀង និងលូទឹកកខ្វក់ឱ្យដាច់ពីគ្នាដោយតភ្ជាប់ទៅនឹង អាងប្រព្រឹត្តិកម្មទឹកកខ្វក់ស្របតាមស្ថានភាពទីតាំងភូមិសាស្ត្រដើម្បីចម្រោះឱ្យបានស្អាតស្របតាម បទដ្ឋានបច្ចេកទេសអនាម័យមុននឹងបង្ហូរចូលប្រព័ន្ធលូសាធារណៈ
- ណែនាំគ្រប់ម្ចាស់សំណង់លំនៅឋាន ឧស្សាហកម្ម ពាណិជ្ជកម្ម សេវាកម្ម និងសំណង់សាធារណៈត្រូវមានអាងប្រព្រឹត្តិកម្មទឹកកខ្វក់ និងអាងបង្គន់អនាម័យត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេសមុនបង្ហូរចូលប្រព័ន្ធលូសាធារណៈ
- មន្ត្រីមានសមត្ថកិច្ចជំនាញ សហការជាមួយអាជ្ញាធរមូលដ្ឋាន ត្រូវត្រួតពិនិត្យជាប្រចាំរាល់ការដ្ឋានសំណង់ក្នុងការធ្វើអាងប្រព្រឹត្តិកម្មទឹកកខ្វក់និងអាងបង្គន់អនាម័យ
- រៀបចំអណ្តូងលូឱ្យមានប្រព័ន្ធចម្រោះជាមុននូវសំណល់ភក់មុននឹងបង្ហូរចូលលូសាធារណៈឱ្យស្រប តាមបទដ្ឋានបច្ចេកទេស
- សិក្សានិងរៀបចំឱ្យមានប្រព័ន្ធប្រព្រឹត្តិកម្មទឹកកខ្វក់ឱ្យបានត្រឹមត្រូវតាមអនុក្រឹត្យលេខ២៣៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៧ ស្តីពីការគ្រប់គ្រងប្រព័ន្ធលូនិងប្រព័ន្ធប្រព្រឹត្តិកម្មទឹកកខ្វក់
- ផ្សព្វផ្សាយពីគោលការណ៍បរិស្ថាននិងអនាម័យដើម្បី ធានាបាននិរន្តរភាព ជាតំបន់លំនៅឋានប្រកបដោយសុខុមាលភាព
- ទប់ស្កាត់ការបង្ហូរទឹកកខ្វក់ដែលមានការបំពុលបរិស្ថាន ឱ្យខានតែបានដែលបណ្តាលមកពីសហគ្រាសនិងអាជីវកម្មផ្សេងៗ។

# ជំពូកទី៣
# បញ្ហាប្រឈម
# និង ដំណោះស្រាយ

# ជំពូកទី៣
# បញ្ហាប្រឈម និងដំណោះស្រាយ

## ៣.១.បញ្ហាប្រឈម

ជាការពិតណាស់នៅក្នុងខណ្ឌនីមួយៗ ការរៀបចំខណ្ឌឱ្យមានសោភ័ណភាពនិងសណ្តាប់ធ្នាប់ សន្តិសុខសុវត្ថិភាព គឺរមែងតែងតែមានភាពលំបាកជាច្រើនដែលតែងតែជួបព្រោះត្រូវការធនធានមនុស្សសម្រាប់ការ ជួយរៀបចំខណ្ឌដើម្បីឱ្យមានភាពស្រស់ស្អាត និងមានភ្ញៀវទេសចរមកទស្សនា។ ម្យ៉ាងវិញទៀតរាល់ការរៀបចំ ខណ្ឌនីមួយៗតែងតែជួបប្រទះនឹងបញ្ហាជាច្រើនដូចជា តម្រូវការខ្ពស់ទាំងសម្ភារៈ និងប្រភពធនធានដទៃទៀត។ ឧទាហរណ៍ ជាក់ស្តែងដើម្បីសាងសង់ស្ពានអាកាសមួយបានគេត្រូវការឧបករណ៍ និងសម្ភារៈសំណង់ជាច្រើនព្រោះការ ធ្វើស្ពានមានទំហំធំជាពិសេសវាទាមទារនូវទំហំពលកម្មច្រើនក៏ដូចជាប្រាក់ឈ្នួលសម្រាប់កម្មករដូចគ្នា។ លើសពីនេះទៅទៀតដើម្បីឱ្យសំណង់ស្ពានអាចទ្រទ្រង់បានល្អលុះត្រាតែការគណនាបានច្បាស់លាស់ និងការសាងសង់ត្រូវទៅ តាមមាត្រដ្ឋានត្រឹមត្រូវព្យាយាម កាត់បន្ថយនូវចំណាយសាធារណៈដែលមិនចាំបាច់។ ជាការពិតណាស់សម្រាប់ការរៀបចំសណ្តាប់ធ្នាប់ សោភ័ណភាពខណ្ឌដូចគ្នា ដែរតែងតែប្រឈមមុខនឹងបញ្ហាទាំងនេះ ហើយកត្តាដែលជាបញ្ហាទាំងនោះរួមមាន៖

### ៣.១.១.ធនធានមនុស្ស

ធនធានមនុស្សជាកត្តាចម្បងដែលមិនអាចខ្វះបានទោះបីជាសម័យបច្ចុប្បន្នកាន់តែទំនើប ដោយមានការប្រើប្រាស់គ្រឿងយន្ត ឬ បច្ចេកវិទ្យាជំនួសកម្លាំងមនុស្សបានច្រើនក៏ពិតមែន តែនៅតែត្រូវការគ្រប់គ្រងពីមនុស្សដូចគ្នា។ ម៉្យាងវិញទៀតធនធានមនុស្សនៅក្នុងខណ្ឌមានជ័យ កាន់តែមានការកើនឡើងជាលំដាប់ដោយសារតែការផ្លាស់ប្តូរទីលំនៅមកកាន់ទីក្រុងនិងការចាកចេញមកធ្វើការនៅទីក្រុងដែលជាកន្លែងមានការងារសំបូរបែប មានអ្នកក្រៅចូលមកក្នុងខណ្ឌកាន់តែ មានចំនួនច្រើនទ្វេដង។ ដោយហេតុថាកត្តាជីវភាពមានការរាំងស្ទះដល់ការរស់នៅរបស់ប្រជាជន ដែលជាមូលហេតុនាំឱ្យពួកគាត់ព្យាយាមស្វែងរកលំនៅថ្មីដែលអាចទទួលយកបាន។ ចំពោះបញ្ហានេះជាកត្តា ប្រឈមនៅទូទាំងប្រទេសមិនត្រឹមតែនៅក្នុងខណ្ឌមានជ័យនោះទេ។ ម៉្យាងវិញទៀត អត្រាកំណើនប្រជាជនក៏មានភាពល្អប្រសើរដែរ បើយើងផ្អែកលើតួលេខបណ្តោះអាសន្ននៃជំរឿនទូទៅប្រជាជនកម្ពុជាឆ្នាំ២០១៩ បានបង្ហាញឱ្យឃើញថាអត្រាកំណើនប្រជាជនកម្ពុជាមានការស្រុតចុះជាលំដាប់បើធៀបនឹងការធ្វើជំរឿននៅ ឆ្នាំចាស់ដោយអត្រាកំណើនប្រជាជនមានការធ្លាក់ចុះរហូតដល់៣.៣ភាគរយ។ ខណៈដែលកម្លាំងពលកម្មមានការថមថយក៏នៅមានបញ្ហាដែលបង្កផលលំបាកដល់គម្រោង ការអភិវឌ្ឍមួយកម្រិតទៀតនោះគឺ សមត្ថភាព ចំណេះ ជំនាញ គឺនៅមិនទាន់ពេញលេញតាមតម្រូវការជាក់ស្តែងនោះទេ។ ដូច្នេះហើយបានជា បញ្ហាធនធានមនុស្សជាកត្តាដែលធ្វើឱ្យប៉ះពាល់ដល់ការរៀបចំសោភ័ណភាព សណ្តាប់ធ្នាប់។[25]

### ៣.១.២.គម្រោងថវិការ

ប្រទេសកម្ពុជា ស្ថិតនៅក្នុងដំណាក់កាល កំពុងអភិវឌ្ឍន៍ការរីកចម្រើននៅមានកម្រិតដោយហេតុថាប្រទេសកម្ពុជាបានឆ្លងកាត់នូវសង្គ្រាមជាច្រើន ជាពិសេសសង្គ្រាមស៊ីវិលផ្ទៃក្នុងដែលអូសបន្លាយអស់រយៈពេល

[25] ដកស្រង់ ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា២០១៩

៣ឆ្នាំ ៨ខែ ២០ថ្ងៃ។ ថ្ងៃរំដោះរាជរដ្ឋាភិបាលបានព្យាយាមអភិវឌ្ឍន៍រហូតបានដល់បច្ចុប្បន្ន។ បើយើងងាកមកមើល គម្រោងអភិវឌ្ឍន៍នីមួយៗវិញ គឺត្រូវការចំណាយទុនវិនិយោគច្រើន ហើយជាញឹកញាប់ប្រទេសកម្ពុជាតែងតែទទួលនូវ ជំនួយមានសំណង និងជំនួយឥតសំណងជាច្រើនពីបណ្តាប្រទេសផ្សេងៗ។ ខណ្ឌមួយនេះក៏មានសក្តានុពលខ្លាំងដោយសារតែមានការពង្រីកជានបន្តបន្ទាប់របស់រាជធានីភ្នំពេញ ក្នុងរយះពេលប៉ុន្មានឆ្នាំចុងក្រោយនេះបានប្រែក្លាយជាតំបន់ក្នុងទីក្រុងមួយដែលកំពុងមាននូវភាពលេចធ្លោ និង កាន់តែមានប្រជាប្រិយភាពដែលស្ថិតនៅភាគខាងត្បូងនៃរាជធានីភ្នំពេញនិងបានផ្តល់ឱកាសជាច្រើនទៅលើការវិនិយោគក្នុងវិស័យសំណង់លំនៅដ្ឋានបុរី ផ្សារទំនើប និងទេសចរណ៍ច្រើនជាងក្នុងការវិនិយោគ ក្នុងវិស័យកសិកម្ម កាលពីពេលកន្លងទៅថ្មីៗនេះខណ្ឌមានជ័យកំពុងទទួលបាន គម្រោងវិនិយោគ រោងចក្រ និងគម្រោងអភិវឌ្ឍអចនទ្រព្យ។ ពេលបច្ចុប្បន្ននេះ ខណ្ឌមានជ័យបានកំពុងប្រមូលផ្តុំ រោងចក្រឧស្សាហកម្មច្រើន ដែលតំណាងឲ្យរោងចក្រកាត់ដេរ។ ជាងនេះទៅទៀត ជាមួយនឹងការសាងសង់គម្រោង អាកាសយានដ្ឋានអន្តរជាតិភ្នំពេញថ្មី និងគម្រោងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗទៀត ក៏ដូចជាទីក្រុងរណប ING City បាន ទាក់ទាញគម្រោងអភិវឌ្ឍន៍ខ្នាតធំៗជាច្រើនទៀតផងដែរ ធ្វើឲ្យខណ្ឌមានជ័យក្លាយជាតំបន់សំខាន់សម្រាប់ការ វិនិយោគ និងការអភិវឌ្ឍន៍ផ្នែកវិស័យអចលនទ្រព្យដោយមានអគារលំនៅឋាន និងមជ្ឈមណ្ឌលពាណិជ្ជកម្មត្រូវ បានសាងសង់យ៉ាងកុះករ។

### ៣.១.៣.ភង្វះបច្ចេកទេស

ដោយសារបច្ចុប្បន្នប្រទេសកម្ពុជា ជាប្រទេសដែលកំពុងតែអភិវឌ្ឍន៍ដូច្នេះហើយទើបធ្វើឱ្យការរៀបចំខណ្ឌ មានផលវិបាកដោយមូលហេតុខ្វះបច្ចេកទេសមិនទាន់មានឧបករណ៍ទំនើបក្នុងការសាងសង់ ហេតុនេះហើយ ទើបធ្វើឱ្យការរៀបចំហេដ្ឋារចនាសម្ព័ន្ធកម្ពុជានៅមានកម្រិតនៅឡើយ។ អ្វីដែលគួរអោយកត់សម្គាល់មិនត្រឹមតែកង្វះនូវឧបករណ៍ប៉ុណ្ណោះទេតែខណៈដែលប្រទេសកម្ពុជាទើបតែងើបពីសង្គ្រាមប៉ុន្មានទសវត្សចុងក្រោយធ្វើឱ្យបាត់បង់នូវបុគ្គលឆ្នើមក៏ដូចជាអ្នកមានចំណេះដឹងជាច្រើនជាហេតុ បណ្តាលឱ្យបច្ចុប្បន្នទាមទារនូវបុគ្គលដែលមានជំនាញខ្ពស់ជាច្រើន ក្នុងការអភិវឌ្ឍហើយដោយសារ ជំនាញបច្ចេកទេសក្នុងស្រុកនៅមានកម្រិត ទើបបណ្តាលឱ្យមាននូវតម្រូវការអ្នកបច្ចេកទេសពីបរទេស។ ជាការពិតណាស់ក្នុងវិស័យសំណង់នាពេលបច្ចុប្បន្នមិនត្រឹម តែមានការរីកចម្រើននោះទេ គឺគម្រោងសាងសង់នីមួយៗកាន់តែប្រណិត និងទំនើប ដូច្នេះវិស្វករដែលទើបតែចាប់ផ្តើម ការងារមិនអាចកាន់កាប់ការងារសំខាន់ៗនោះទេលុះត្រាតែជាវិស្វករអាជីព ដែលមានបទពិសោធន៍ការងារច្រើនឆ្នាំទើបអាចទទួលឱកាសក្នុងការកាន់គ្រោងការនោះ។ នេះគឺជាបញ្ហាចោទដែលទាមទារឱ្យមានវិស្វករពីរគឺបរទេសដែលគេមានជំនាញ និងការយល់ដឹងខ្ពស់ជាង វិស្វករ ដែលទើបប្រឡូកក្នុងការងារដែលមិនមែនជាវិស្វករអាជីពនោះទេ ។

### ៣.១.៤.ការបន្តឱ្យមានការកកស្ទះចរាចរណ៍

ជាក់ស្តែងនៅពេលដែលប្រទេសកំពុងអភិវឌ្ឍន៍ ឬ មានការរៀបចំក្រុងរមែងតែមានការជួបប្រទះនូវបញ្ហាការកកស្ទះចរាចរណ៍ ពីព្រោះការធ្វើផ្លូវថ្នល់ ការកសាងហេដ្ឋារចនាសម្ព័ន្ធដូចជា ការកសាងស្ពាន ស្ពានអាកាសប្រព័ន្ធលូជាដើម តម្រូវឱ្យមានការបិទផ្លូវ ឬ បិទមួយជំហៀងផ្លូវដើម្បី ផ្តល់ភាពងាយស្រួលក្នុងការពន្លឿនការងារសាងសង់និងជៀសវាងគ្រោះថ្នាក់ផ្សេងៗ។ ដោយយោងទៅតាមមន្ត្រីនគរបាលចរាចរណ៍នៃអធិការដ្ឋាននគរបាលខណ្ឌមានជ័យ បានបង្ហើបប្រាប់សាធារណជនឱ្យដឹងថា មូលហេតុដែលបង្កឱ្យមានការកកស្ទះខ្លាំង នៅតាមផ្លូវ

មួយចំនួន ជាពិសេសនៅពេលព្រឹកនិងពេលល្ងាចនៅតាមទីប្រជុំជនក្នុងខណ្ឌមានជ័យ សព្វថ្ងៃនេះ គឺដោយសារកត្តាមួយចំនួនមានដូចជា៖ កត្តាយានយន្តកើនឡើងច្រើន, ការបើកបរមិនគោរពច្បាប់ ឬ ការមិនគោរពភ្លើងសញ្ញា ។ លើសពីនេះទៅទៀត មានការបើកបរវ៉ាដែងគ្មានសណ្តាប់ធ្នាប់, បើកបរគ្មានសុជីវធម៌ មិនមានការប្រុងប្រយ័ត្ន បើកបរមិនប្រកាន់គន្លងផ្លូវ, ការបត់យានយន្ត ឆ្លងកាត់ផ្លូវមិនមើលស្ថានភាពចរាចរណ៍, ការបើកបរមិនមានការ យោគយល់គ្នា និង ការចតយានយន្តនៅតាមចិញ្ចើមផ្លូវគ្មានសណ្តាប់ធ្នាប់ជាដើម គឺជាមូលហេតុចម្បងនាំឱ្យ ចរាចរណ៍កកស្ទះស្ទើររាល់ថ្ងៃ នៅទីប្រជុំជនក្នុងខណ្ឌមានជ័យ ។

## ៣.២.ដំណោះស្រាយ

ជាការពិតណាស់នៅក្នុងការរៀបចំខណ្ឌមួយ គឺតែងតែជួបប្រទះនូវបញ្ហាប្រឈមជាច្រើនដែលស្របពេលផែនការអភិវឌ្ឍន៍ ទាំងអស់នោះត្រូវការផ្នែកធនធានមនុស្ស ថវិការ និងបញ្ហាបច្ចេកទេសផ្សេងៗ ហើយនឹងត្រូវប្រើប្រាស់រយៈពេល វែងដែលមានន័យថាគម្រោងត្រូវតែចំណាយដើមទុន និងប្រើពេលវេលាយូរ។

*** ធនធានមនុស្ស**

ធនធានមនុស្ស គឺជាផ្នែកមួយយ៉ាងសំខាន់សម្រាប់ការអភិវឌ្ឍប្រទេសហើយបច្ចុប្បន្ននេះថ្នាក់ដឹកនាំប្រទេសកម្ពុជា បានកំពុងយកចិត្តទុកដាក់ជាខ្លាំង ក្នុងការជំរុញឱ្យមានការអភិវឌ្ឍធនធានមនុស្ស ដើម្បីធ្វើយ៉ាងណាឱ្យប្រទេស កម្ពុជាមានធនធានគ្រប់គ្រាន់សម្រាប់បំពេញតម្រូវការទៅតាមវិស័យនានា។ ដើម្បីដោះស្រាយរាល់បញ្ហាដែលកំពុងជួបប្រទះក្នុងការរៀបចំសោភ័ណភាព និងសណ្តាប់ធ្នាប់គណៈគ្រប់គ្រងគួរយកចិត្តទុកដាក់នូវចំណុចមួយចំនួន៖

- ការគិតគូរអំពីតម្រូវការនៃការអភិវឌ្ឍសមត្ថភាពមន្ត្រីដូចជា ការរៀបចំការបណ្តុះបណ្តាលទៅតាមមុខតំណែង កំណត់តម្រូវការនៃការបណ្តុះបណ្តាលការរៀបចំសម្រាប់ការបណ្តុះបណ្តាល។
- ការជ្រើសរើសមន្ត្រីដែលមានសមត្ថភាព និងស្របតាមតម្រូវការរបស់ក្រសួងស្ថាប័ន ការពង្រឹងមន្ត្រីតាមជំនាញ តាមទីកន្លែងការងារ និងការវាយតម្លៃគុណភាពរបស់មន្ត្រី ទាំងឥរិយាបថ និងផលិតភាពការងារ ។
- ការលើកទឹកចិត្តដល់មន្ត្រី ដូចជាបរិយាសការងារ ការឡើងថ្នាក់នឹងឋានន្តរសក្តិ ការឈប់សម្រាកប្រចាំ សប្តាហ៍ និងប្រាក់បៀវត្សរ៍នៅពេលមានបុណ្យទានជាដើម។

*** កង្វះបច្ចេកទេស**

បច្ចុប្បន្នប្រទេសកម្ពុជា មានការខ្វះខាតអ្នកជំនាញបច្ចេកទេស ហើយកង្វះខាតទាំងអស់នេះក៏ ព្រោះ តែប្រទេសកម្ពុជា ជាប្រទេសកំពុងអភិវឌ្ឍន៍ ទាំងវិស័យឧស្សាហកម្ម ទាំងវិស័យអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ នានា និងសេវាកម្មផ្សេងៗទៀត។ ការអភិវឌ្ឍទាំងអស់នេះ គឺចាំបាច់ត្រូវការអ្នកជំនាញបច្ចេកទេសដើម្បីជួយ គាំទ្រនៅក្នុងការអភិវឌ្ឍគ្រប់វិស័យទាំងអស់។ យោងតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការកែប្រែ ប្រទេសកម្ពុជាឱ្យក្លាយទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ ២០៣០ និងជាប្រទេសមានចំណូលកម្រិតខ្ពស់នៅឆ្នាំ២០៥០។ ដោយប្រមុខរាជរដ្ឋាភិបាលបានដាក់ចេញនូវយុទ្ធសាស្ត្រ ៤គឺ៖

- កៀងគរ និងទាក់ទាញវិនិយោគទុនផ្ទាល់ពីបរទេស និងវិនិយោគទុនឯកជននៅក្នុងស្រុកដោយផ្តោតលើឧស្សាហកម្មធំៗ ការអភិវឌ្ឍ និងការពង្រីកទីផ្សារ និងការអភិវឌ្ឍការផ្ទេរបច្ចេកវិទ្យា។

- អភិវឌ្ឍន៍ និងធ្វើទំនើបកម្មសហគ្រាសធុនតូច និងមធ្យម។
- ការកែលម្អបរិស្ថាននិយតកម្ម ដើម្បីពង្រឹងភាពប្រកួតប្រជែង។
- អភិវឌ្ឍន៍ ធនធានមនុស្សបណ្ដុះបណ្ដាលជំនាញការកែលម្អទំនាក់ទំនងវិជ្ជាជីវៈ និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគាំទ្រដូចជា ប្រព័ន្ធដឹកជញ្ជូន ឡូជីស្ទីក ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគមនាគមន៍ការផ្គត់ផ្គង់អគ្គិសនី ទឹកស្អាតសេវាសាធារណៈសេវាសង្គមកិច្ចនិងសេវាហិរញ្ញវត្ថុ។

### ៣.២.១ ការសហការពីប្រជាពលរដ្ឋ

ជាការពិតណាស់ប្រមុខរាជរដ្ឋាភិបាលបានព្យាយាមសម្រួលនូវ ភាពលំបាកចំពោះការរស់នៅប្រជាជនតាមរយៈ ការរៀបចំអភិវឌ្ឍន៍រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌទាំងអស់ ដោយធានាការអភិវឌ្ឍប្រកបដោយនិរន្តរភាព។ បើជាចាំបាច់ សកម្មភាពប្រជាជន និងការរួបរួម យោគយល់ អាឲ្យស្រ័យពីសំណាក់ប្រជាពលរដ្ឋជាកម្លាំងជំរុញដ៏ខ្លាំងក្លា ក្នុងការអភិវឌ្ឍ សង្គម និង សេដ្ឋកិច្ច។ ជាក់ស្ដែងប្រជាជនត្រូវសហការជាមួយអាជ្ញាធរមូលដ្ឋាន ក៏ដូចជាអាជ្ញាធរមានសមត្ថកិច្ច ផងដែរ ក្នុងប្រការផ្សេងៗទាក់ទងនឹងកិច្ចរៀបចំខណ្ឌ។ ឧទាហរណ៍ ប្រសិនបើមានការពង្រីកទំហំផ្លូវ ឬ សាងសង់ស្ពានអាកាស ដើម្បី សម្រួលចរាចរណ៍លើដងផ្លូវ ហើយច្បាស់ណាស់ថាការពង្រីកផ្លូវនេះ តែងតែប៉ះពាល់ដល់លំនៅដ្ឋានរបស់ ប្រជាពលរដ្ឋ នៅម្ដុំនោះជាក់ជាមិនខាន ដូច្នេះ អាជ្ញាធរត្រូវចុះសុំការសហការពីម្ចាស់លំនៅ ដោយមានការ ចរចាពីការខូចខាតផ្សេងៗ ដូចជាសំណងការខូចខាតផងដែរ។ ហើយក្នុងនាមជាម្ចាស់លំនៅដ្ឋានត្រូវយោគយល់ ដល់រដ្ឋាភិបាលដែលព្យាយាមផ្ដល់ប្រយោជន៍រួមក្នុងសហគមន៍នោះ។ ម្យ៉ាងវិញទៀតប្រជាពលរដ្ឋដែលមាន ផ្ទះអមសងខាងផ្លូវសូមឱ្យជួយថែរក្សា និងមានការយោគយល់ហាមដាច់ខាតយកចិញ្ចើមផ្លូវសាធារណៈ របស់រដ្ឋធ្វើអាជីវកម្មដែលនាំឱ្យប៉ះពាល់សណ្ដាប់ធ្នាប់បរិស្ថានក្នុងរាជធានីភ្នំពេញដើម្បីសោភ័ណភាពទាក់ ទាញភ្ញៀវទេសចរណ៍ ជាតិ និង អន្តរជាតិ មកកម្សាន្តច្រើនដូចជាចូលផ្សារទិញទំនិញផ្សេងៗ ដែលជួយជំរុញសេដ្ឋកិច្ចគ្រួសារ កើនឡើងមួយកម្រិតទៀត។ បន្ថែមលើនេះទៀតដើម្បីឱ្យរាជធានីភ្នំពេញ មានសោភ័ណភាពនោះរដ្ឋបាល រាជធានី និង ខណ្ឌ ក្នុងពេលឆាប់ៗខាងមុខនេះនឹងដាំដើមឈើ ។ ដោយអនុឡោមតាមព្រះរាជបន្ទូលព្រះមហាក្សត្រនៃកម្ពុជា ៖ឧទ្ទិសឲ្យពិធីរុក្ខទិវាស្ថិតក្នុងបេះដូងរបស់ប្រជាជនកម្ពុជាគ្រប់ៗរូប និង ក្លាយជាប្រពៃណីនៃការរួមសាមគ្គីគ្នា ដាំដើមឈើគ្រប់ប្រភេទ និង ការថែរក្សា ការពារ និង អភិវឌ្ឍធនធានព្រៃឈើ ។

### ៣.២.២.ការកាត់បន្ថយការកកស្ទះចរាចរណ៍

ពិតណាស់ ចរាចរណ៍ជាបញ្ហា មួយដ៏ចម្បង ដែលអ្នករស់នៅទីក្រុងតែងតែជួបប្រទះ ស្ទើរតែគ្រប់គ្នា និងគ្រប់ពេលវា នាពេលធ្វើដំណើរ។ ដើម្បីជួយសម្រួលដល់ការធ្វើដំណើររបស់ប្រជាពលរដ្ឋ រដ្ឋាភិបាលបាននឹងកំពុងតែមមាញឹក ក្នុងការកសាងផ្លូវថ្នល់ ស្ពាន បន្ថែមដូចជាៈ

មហាវិថី សម្ដេច ហ៊ុន សែន ឬផ្លូវ៦០ម៉ែត្រ មានទទឹង៦០ម៉ែត្រ និងបណ្ដោយជិត១០គីឡូម៉ែត្រ ដែលជាផ្លូវតភ្ជាប់ដ៏សំខាន់មួយនៅក្នុងរាជធានីភ្នំពេញ ដើម្បីជួយសម្រួលដល់ការកកស្ទះចរាចរនៅភាគខាងត្បូងនៃទីក្រុង។ ផ្លូវនេះបានភ្ជាប់គ្នារវាងផ្លូវលេខ២៧១ភាគខាងជើង ជាមួយផ្លូវជាតិលេខ២ភាគខាងត្បូង។ ផ្លូវ៦០ម៉ែត្របានលាត

សន្ទឹងដោយឆ្លងកាត់សង្កាត់ចំនួនបី គឺសង្កាត់ចាក់អង្រែលើ និងចាក់អង្រែក្រោមក្នុងខណ្ឌមានជ័យ និងសង្កាត់ជើងឯកក្នុងខណ្ឌដង្កោ។[26]

គម្រោងស្ពានអាកាសចំណុចប្រសព្វមហាវិថីសម្តេចតេជោ ហ៊ុន សែន មហាវិថីព្រះមុនីវង្ស ជាមួយវិថីកងយោធពលខេមរភូមិន្ទ(ផ្លូវលេខ២៧១) ដែលហៅថាស្ពានអាកាស «មរតកតេជោ» គម្រោងស្ពានអាកាស នេះ គឺមានសាងសង់ផ្លូវផ្ទាល់ដី ដែលមានរង្វង់មូលបែងចែកទិស និងផ្លូវតភ្ជាប់រវាងមហាវិថីព្រះមុនីវង្ស មហាវិថីសម្តេចតេជោ ហ៊ុន សែន វិថីកងយោធពលខេមរភូមិន្ទ ឆ្ពោះទៅស្ពានព្រះមុនីវង្ស និងផ្លូវជាតិលេខ២។ បន្ទាប់មកសាងសង់ស្ពានអាកាសចំនួនពីរជាន់។ ស្ពានអាកាសជាន់ទី១ ជាស្ពានរង្វង់មូល នៅត្រង់ចំណុចប្រសព្វ ដែលបំបែកខ្នែងជាបួនទិសផ្សេងគ្នា ទៅកាន់មហាវិថីសម្តេចតេជោ ហ៊ុន សែន ស្ពានព្រះមុនីវង្ស មហាវិថីព្រះមុនីវង្ស និងវិថីកងយោធពល ខេមរភូមិន្ទ។[27] ស្ពានអាកាស «មរតកតេជោ» ជាន់ទី២ ដែលតភ្ជាប់ពីមហាវិថីសម្តេចតេជោ ហ៊ុន សែន មកមហាវិថីព្រះមុនីវង្ស បានបើកឲ្យប្រើប្រាស់បណ្តោះអាសន្នហើយនៅព្រឹកថ្ងៃទី១ ខែមេសា ឆ្នាំ២០២៤ នេះដើម្បីចូលរួមចំណែក ក្នុងការកាត់បន្ថយការកកស្ទះចរាចរណ៍ និងបង្កលក្ខណៈងាយស្រួលក្នុងការធ្វើដំណើររបស់ប្រជាពលរដ្ឋ ជាពិសេស ជំរុញដល់ការបែងចែកផ្លែផ្កាសេដ្ឋកិច្ចប្រកបដោយសមធម៌ជូនប្រជាពលរដ្ឋ ។

គម្រោងស្ថាបនា ស្ពានចាក់អង្រែក្រោម-ព្រែកប្រា ត្រូវបានសាងសង់ឡើងដោយចាយថវិកា ប្រមាណ ៦០លានដុល្លារអាមេរិក និង ប្រើរយៈពេលសាងសង់៤២ខែ ដោយគណទានសម្បទានពី ប្រទេសចិន។ នេះបើអ្នកនាំពាក្យក្រសួងសាធារណការ និងដឹកជញ្ជូន លោក ផន រឹម ឱ្យដឹងកាលពីថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២៤ កន្លងមកនេះ។ ស្ពានចាក់អង្រែក្រោម-ព្រែកប្រា ត្រូវបានបើកការដ្ឋានសាងសង់កាល ពីថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២៤ ក្រោមអធិបតីភាពរបស់សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីកម្ពុជា។ ទីតាំងគម្រោង ស្ពានឆ្លងកាត់ទន្លេបាសាក់ ស្ថិតនៅក្នុងសង្កាត់ចាក់អង្រែ ក្រោម ខណ្ឌមានជ័យ និងសង្កាត់ព្រែកប្រា ខណ្ឌច្បារអំពៅ។ គួរបញ្ជាក់ថា៖ គម្រោងស្ថាបនាស្ពានឆ្លងកាត់ទន្លេបាសាក់ (ចាក់អង្រែក្រោម-ព្រែកប្រា) សម្រេចការសាងសង់បានជាង១០% ហើយ ដោយបច្ចុប្បន្ន នេះ សសរគ្រឹះចំនួន២៤ ដើម បានចាក់បេតុង រួចរាល់១០០% និងកំពុងបន្តរៀបចំដំឡើងពុម្ពជើងតាង ព្រមទាំងការងារសំខាន់ៗមួយចំនួនទៀត។ គម្រោងសាងសង់ស្ពានឆ្លងកាត់ទន្លេបាសាក់នេះ មានប្រវែងសរុប ១.៦៥០ម៉ែត្រ (ប្រវែងស្ពាន ៨៤៥, ៧០ម៉ែត្រ, ទទឹងផ្លូវ ២៧ម៉ែត្រ, ផ្លូវតភ្ជាប់ក្បាលស្ពានប្រវែង ៨០៤,៣០ម៉ែត្រ, ទទឹងផ្លូវ ២៧ម៉ែត្រ) សាងសង់ ដោយក្រុមហ៊ុន សំណង់សៀងហៃ និងទីប្រឹក្សាគម្រោងដោយក្រុមហ៊ុនក្វាងចូវវ៉ាន់អាន។[28]

បន្ថែមពីនេះទៅទៀត រដ្ឋបាលរាជធានីភ្នំពេញ បង្កើតផ្លូវមួយខ្សែទៀត តភ្ជាប់ពីផ្លូវជាតិលេខ១ កាត់តាម បុរី ប៉េង ហួត បឹងស្នោរ រហូតដល់គល់ស្ពានចាក់អង្រែក្រោម-ព្រែកប្រា។ យោងទៅតាមប្រសាសន៍ លោក ឃួង ស្រេង អភិបាលរាជធានីភ្នំពេញបានលើកឡើងថា ស្ពានឆ្លងកាត់ទន្លេបាសាក់ (ចាក់អង្រែក្រោម-ព្រែកប្រា) ក្រោយស្ថាបនារួច នឹងអាចដោះស្រាយការកកស្ទះចរាចរណ៍ លើកំណាត់ផ្លូវជាតិលេខ១ កាន់តែប្រសើរថែមទៀត ដោយសាររដ្ឋបាលរាជធានីភ្នំពេញ បានសម្រេចបង្កើតផ្លូវមួយខ្សែទៀត តភ្ជាប់ពីផ្លូវជាតិលេខ១ កាត់តាមបុរី ប៉េង

[26] https://thmeythmey.com/?page=detail&id=68581

[27] https://business-cambodia.com/articles/special-bridge

[28] https://www.mpwt.gov.kh/kh/press/38959 គេហទំព័រ ក្រសួងសាធារណការ និង ដឹកជញ្ជូន ដកស្រង់ថ្ងៃទី ០១ ខែមិថុនា ឆ្នាំ២០២៤

ហួត បឹងស្នោរ រហូតដល់គល់ស្ពាននេះតែម្តង។ ការលើកឡើងរបស់លោក ឃួង ស្រេង ធ្វើឡើងក្នុងឱកាសដឹកនាំមន្ត្រីជំនាញ និងតំណាងក្រសួងពាក់ព័ន្ធ ចុះពិនិត្យទីតាំងគម្រោងផ្លូវ និងស្ពានឆ្លងកាត់ទន្លេបាសាក់ ស្ថិតនៅក្នុងសង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ និងសង្កាត់ព្រែកប្រា ខណ្ឌច្បារអំពៅ នារសៀលថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២៤នេះ។ ក្នុងឱកាសនេះ លោក ឃួង ស្រេង បានលើកឡើងថា ស្ពានកោះនរាក្រោយស្ថាបនាហើយ ដោះស្រាយការកកស្ទះចរាចរណ៍ លើកំណាត់ផ្លូវជាតិលេខ១ ចូលមកភ្នំពេញ បានប្រមាណ៣០ភាគរយប៉ុណ្ណោះ ដោយវានៅតែ បង្កការកកស្ទះចរាចរណ៍ជៀសមិនរួច តែនៅពេលបើកផ្លូវថ្មី តភ្ជាប់ពីផ្លូវជាតិលេខ១ កាត់តាមបុរីប៉េង ហួត បឹងស្នោរ រហូតដល់គល់ស្ពានឆ្លងកាត់ទន្លេបាសាក់ (ចាក់អង្រែក្រោម-ព្រែកប្រា)នេះមួយខ្សែទៀតវានឹងដោះស្រាយការកកស្ទះចរាចរណ៍ លើកំណាត់ផ្លូវជាតិលេខ១ កាន់តែប្រសើរឡើងមួយកំរិតទៀត។ ផ្លូវថ្មីតភ្ជាប់ពីផ្លូវជាតិលេខ១ រហូតដល់គល់ស្ពានឆ្លងកាត់ទន្លេបាសាក់ (ចាក់អង្រែក្រោម-ព្រែកប្រា) គឺអាចដោះចរាចណ៍ពីផ្លូវជាតិលេខ១ ទៅផ្លូវ៦០ម៉ែត្រ ខណ្ឌមានជ័យ និងបន្តឆ្ពោះទៅ២១៧ (ផ្លូវចំការដូង) ។[29]

[29] https://www.mpwt.gov.kh/kh/press/38932 គេហទំព័រ ក្រសួងសាធារណការ និង ដឹកជញ្ជូន ដកស្រង់ថ្ងៃទី ០១ ខែមិថុនា ឆ្នាំ២០២៤

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ដោយយោងតាមការបកស្រាយខាងលើបានបញ្ជាក់បង្ហាញឲ្យឃើញថា ការរៀបចំសោភ័ណ និង សណ្តាប់ធ្នាប់ ពិតជាមានសារៈ សំខាន់ណាស់ ក្នុងគោលបំណងធ្វើឱ្យទីក្រុងមានរបៀបរៀបរយ និងមាន សោភ័ណភាពល្អ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ មានការកសាង និងការអភិវឌ្ឍក៏ពិតមែន ក៏នៅតែមានភាព ខ្វះចន្លោះមិនទាន់គ្រប់ជ្រុងជ្រោយនៅឡើយ។ ការរៀបចំសោភ័ណនិងសណ្តាប់ធ្នាប់ខណ្ឌមានជ័យកន្លងមកនេះ ក៏នៅតែមានការជួបប្រទះនឹងបញ្ហាប្រឈមមួយចំនួនដូចខណ្ឌដទៃៗផ្សេងទៀតដែរ មានន័យថាទោះបីជាខណ្ឌ នេះមានការរៀបចំឱ្យមាន ហេដ្ឋារចនាសម្ព័ន្ធស្ពានអាកាសផ្លូវថ្នល់ ប្រព័ន្ធលូទឹកស្អុយ សួនច្បារ ការដាក់បង្គោល ភ្លើងបំភ្លឺផ្លូវ បំពាក់ប្រព័ន្ធកាំមេរ៉ាសាធារណៈការរៀបចំចិញ្ចើមផ្លូវ សំណង់អគារ ក៏ដូចជាមានការសម្អាត អនាម័យ និងគ្រប់គ្រង សំរាមកាកសំណល់រឹងរាវ នៅតាមទីធ្លាសាធារណៈក៏ពិតមែន ប៉ុន្តែខណ្ឌនៅតែមានការជួបប្រទះនូវ បញ្ហាអសន្តិសុខ សណ្តាប់ធ្នាប់នៅតាម តំបន់មួយចំនួននៅឡើយ។ ម្យ៉ាងវិញទៀតទោះបីជាខណ្ឌមានការរៀបចំ និងការអភិវឌ្ឍយ៉ាងច្រើន ស្ទើរគ្រប់វិស័យក៏ពិតមែនក៏ប៉ុន្តែយើងសង្កេតឃើញថាការអភិវឌ្ឍរបស់ខណ្ឌ នៅតែមិន ទាន់ទទួលបានលទ្ធផលដូចជាការរំពឹងទុក ស្របទៅតាមផែនការអភិវឌ្ឍរបស់ខណ្ឌនៅឡើយទេ។ ជាក់ស្តែង ណាស់ បញ្ហាសោភ័ណនិងសណ្តាប់ធ្នាប់របស់ខណ្ឌគឺជាបញ្ហាចម្បងមួយដែលខណ្ឌបាននឹងកំពុងធ្វើការយក ចិត្តទុកដាក់ក្នុង ការកែប្រែរៀបចំកសាងហេដ្ឋារចនាសម្ព័ន្ធបន្ថែមទៀតព្រមទាំងមានការយកចិត្តទុកដាក់ទៅលើ ការរៀបចំ សោភ័ណភាពរបស់ខណ្ឌ ដើម្បីឱ្យខណ្ឌមានសោភ័ណនិង សណ្តាប់ធ្នាប់ របៀបរៀបរយ កាន់តែល្អ ប្រសើរជាងមុន។ ជាពិសេសសាលាខណ្ឌមានជ័យបានធ្វើការរៀបចំនូវសន្តិសុខក្នុងខណ្ឌបានយ៉ាងល្អដោយ មានការសហការជាមួយអាជ្ញាធរមូលដ្ឋាន ក្នុងការចុះត្រួតពិនិត្យនៅតាមតំបន់ដើម្បីការពារទប់ស្កាត់ និង បង្ក្រាប ក្មេងទំនើងដែលតែងតែបង្កនូវការវាយទាត់ធាក់ កាប់ចាក់ ការលួច ឆក់ ប្លន់ គ្រប់ប្រភេទ ការផលិត ការចែក ចាយ និង ប្រើប្រាស់គ្រឿងញៀន ការលេងល្បែងស៊ីសងខុសច្បាប់ ដែលទាំងនេះជាបញ្ហាប្រឈម ដែលធ្វើឱ្យប៉ះ ពាល់យ៉ាងខ្លាំងទៅដល់បញ្ហាសន្តិសុខសុវត្ថិភាព សោភ័ណភាព និងសណ្តាប់ធ្នាប់ខណ្ឌមានជ័យ ចំណែកឯការ រៀបចំសណ្តាប់ធ្នាប់តាមមូលដ្ឋានខណ្ឌ ក៏ដូចគ្នាដែរគឺមានដូចជាការរៀបចំគ្រប់គ្រងសណ្តាប់ធ្នាប់របស់អាជីវក ដែល ប្រកបអាជីវកម្មតាមទីផ្សារដែលបានយកចិញ្ចើមផ្លូវធ្វើជារបរអាជីវកម្មផ្ទាល់ខ្លួន ជាហេតុបណ្តាលឱ្យមាន ការកកស្ទះចរាចរណ៍ ការរុះរើសំយ៉ាបផ្ទះរបស់ ប្រជាពលរដ្ឋដែលប៉ះពាល់លើដីចំណីផ្លូវសាធារណៈ ការគ្រប់គ្រង សំណង់អគារ ផ្ទះល្វែងបុរីដែលធ្វើឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈរបស់ខណ្ឌ។ លើសពីនេះយើង សង្កេតឃើថាអភិបាលនៃគណៈអភិបាលរដ្ឋបាលរាជធានីភ្នំពេញ និងរដ្ឋបាលសាលាខណ្ឌមានជ័យបានធ្វើការ យកចិត្តទុកដាក់ ចុះត្រួតពិនិត្យដោយផ្ទាល់ លើបញ្ហាការរៀបចំស្ថាបនាប្រព័ន្ធបង្ហូរទឹកនិងស្តារនូវប្រព័ន្ធលូទឹក ស្អុយនៅក្នុងភូមិសាស្ត្រ ខណ្ឌមានជ័យ ដែលបង្កមកពីការកកស្ទះដោយសារកាកសំណល់សំរាមការកសាង និងជួសជុលផ្លូវដែលខូចខាតលិចលង់ ដោយប្រព័ន្ធលូតូចចង្អៀតហើយការរៀបចំ កសាងសួនច្បារការ ដាក់ភ្លើង បំភ្លឺតាមដងផ្លូវការដាក់កាមេរ៉ា ជាពិសេសទៅទៀតនោះការគ្រប់គ្រងសំរាមនៅតាមដងផ្លូវដែលបង្កឱ្យមានក្លិន មិនល្អព្រមទាំងការហូរចូល ប្រព័ន្ធលូមានការកកស្ទះហូរមិនទាន់ពេលមានភ្លៀងធ្លាក់ ដែលទាំងនេះជាបញ្ហា ប្រឈមដែលធ្វើឱ្យប៉ះពាល់ទៅដល់សោភ័ណភាពក្នុងខណ្ឌ ផងដែរ។

ទោះបីជាយ៉ាងណាក៏ដោយ ក្នុងការសិក្សាស្រាវជ្រាវទៅលើប្រធានបទ "ការរៀបចំសោភ័ណភាព និងសណ្តាប់ធ្នាប់ខណ្ឌមានជ័យ" នេះទៀតសោតបានធ្វើឱ្យក្រុមរបស់យើងខ្ញុំបាន យល់ដឹងកាន់តែច្បាស់ និងស៊ីជម្រៅពីផលប៉ះពាល់ នៃការរៀបចំសោភ័ណភាព និងសណ្តាប់ធ្នាប់របស់ខណ្ឌមានជ័យព្រមទាំងបានយល់ដឹងកាន់តែច្បាស់បន្ថែមទៀត ពីផលប្រយោជន៍នៃការរៀបចំសោភ័ណភាព និងសណ្តាប់ធ្នាប់ខណ្ឌមានជ័យនេះកាន់តែច្បាស់ជាងមុនផងដែរ។សារៈប្រយោជន៍ជាច្រើនដែលបានមកពីការរៀបចំនោះមិនត្រឹមតែធ្វើឱ្យខណ្ឌមានសោភ័ណភាពនិងសណ្តាប់ធ្នាប់ប៉ុណ្ណោះទេ គឺថែមទាំងធ្វើឱ្យទីក្រុងកាន់តែមាន ភាពទាក់ទាញដោយសារសោភ័ណភាពរបស់ខណ្ឌជាផ្នែកមួយនៃសោភ័ណភាព របស់ទីក្រុងផងដែរ។ ម្យ៉ាងវិញទៀត សារៈប្រយោជន៍នៃការរៀបចំនេះ បានធ្វើឱ្យខណ្ឌមានការអភិវឌ្ឍស្ទើរតែគ្រប់វិស័យទៀតផង។ លើសពីនេះទៅទៀតការរៀបចំនូវសោភ័ណភាពនិងសណ្តាប់ធ្នាប់បានធ្វើឱ្យខណ្ឌមានជ័យទាំងមូលមាននូវសោភ័ណ្ឌភាពនិងសណ្តាប់ធ្នាប់ និងរួមបញ្ចូលទាំងសន្តិសុខសុវត្ថិភាពពេញលេញ ដែលធ្វើឱ្យប្រជាពលរដ្ឋមានការរស់នៅប្រកបដោយសេចក្តីសុខសុវត្ថិភាព ពេញលេញ និងពោរពេញទៅដោយភាពស៊ីវិល័យទាន់សម័យទៅតាមសម័យកាលបច្ចុប្បន្ន។

សរុបមកយើងអាច សន្និដ្ឋានបានថាការរៀបចំសោភ័ណភាពនិងសណ្តាប់ធ្នាប់ខណ្ឌមានជ័យគឺពិតជាមានសារៈប្រយោជន៍យ៉ាងសំខាន់ណាស់ បើទោះបីជាក្នុងពេលនេះមិនទាន់នឹងទទួលបានជោគជ័យល្អឥតខ្ចោះទៅតាមផែនការដែលបានគ្រោងទុកក៏ពិតមែន ប៉ុន្តែនៅពេលខាងមុខប្រាកដជាអាចទទួលបាននូវភាពជោគជ័យយ៉ាងពេញលេញជាក់ជាមិនខាន ពីព្រោះថា បើកាលណាមានការចូលរួមសហការរវាងរាជរដ្ឋាភិបាលក៏ដូចជាអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ គ្រប់ក្រសួងស្ថាប័ននានាជាពិសេសទៀតនោះគឺប្រជាពលរដ្ឋមានការចូលរួមសហការក្នុងការជួយរៀបចំសោភ័ណភាពនិងសណ្តាប់ធ្នាប់ ក្នុងខណ្ឌមានជ័យនេះពិតប្រាកដណាស់ថានឹងទទួលបាននូវភាពជោគជ័យ ស្របតាមផែនការក៏ដូចជាទទួលបាននូវសមិទ្ធផលទីកន្លែងល្អស្រស់ស្អាតមានខ្យល់បរិសុទ្ធមានបរិយាកាសរស់នៅប្រកបដោយ ផាសុកភាពសុខ សុវត្ថិភាពទាំងផ្លូវកាយនិងផ្លូវចិត្តជាពិសេសនោះធ្វើឱ្យសោភ័ណភាពនិងសណ្តាប់ធ្នាប់ខណ្ឌមានជ័យ កាន់តែមានភាពល្អប្រសើរ តទៅមុខប្រកបទៅដោយចក្ខុវិស័យវែងឆ្ងាយក្នុងការបង្កើតមគ្គទេសក៍ដឹកនាំសង្គមជាតិជាក់ជាមិនខាន។

# ឯកសារយោង

# ឯកសារយោង

## បទដ្ឋានគតិយុត្ត

- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨
- ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើស ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨
- ច្បាប់ស្តីពីវិសោធនកម្មមាត្រា១៤០ នៃច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលត្រូវប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨
- ច្បាប់ ស្តីពីវិសោធនកម្មច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៩
- ច្បាប់ ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា រាជធានី ខេត្ត ក្រុង ខណ្ឌ ចុះថ្ងៃទី២៤ ខែមករាឆ្នាំ២០១៩
- អនុក្រឹត្យស្តីពី ការកំណត់ចំនួនគណៈអភិបាលរាជធានី គណៈអភិបាលខេត្ត គណៈអភិបាលក្រុង គណៈអភិបាលស្រុក អភិបាលខណ្ឌ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២២
- អនុក្រឹត្យលេខ១៨៣ អនក្រ.បក ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរបស់រដ្ឋបាលខណ្ឌនៃរាជធានីភ្នំពេញ
- អនុក្រឹត្យលេខ ១៤៥ អនក្រ.បក ស្តីពីការបំបែកសង្កាត់ស្ទឹងមានជ័យ នៃខណ្ឌមានជ័យ រាជធានីភ្នំពេញ ចុះថ្ងៃទី១៨ កក្កដា ឆ្នាំ២០១៦
- អនុក្រឹត្យលេខ ១០ អនក្រ.បក ស្តីពីការកំណត់ចំនួនសមាជិកក្រុមប្រឹក្សារាជធានីភ្នំពេញ ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ សម្រាប់អាណត្តិទី៤ ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០២៤
- អនុក្រឹត្យលេខ ៤២ អនក្រ.ប្រក ចុះថ្ងៃទី ០៣ ខែមេសា ឆ្នាំ ២០១៥ ស្តីពី នគរូបនីកម្ម រាជធានី ក្រុង និងទីប្រជុំជន
- អនុក្រឹត្យលេខ ២១៦ អនក្រ.បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩
- អនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- អនុក្រឹត្យលេខ១៨១ អនក្រ.បក ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីការដាក់ឱ្យអនុវត្តប្លង់គោលប្រើប្រាស់ដីរាជធានីភ្នំពេញ ចក្ខុវិស័យឆ្នាំ២០៣៥

## សេចក្តីសម្រេច/សេចក្តីព្រាង/សេចក្តីណែនាំ

- សេចក្តីណែនាំ ស្តីពី ការបែងចែកតួនាទី ភារកិច្ច និងរបៀបរបបការងារជូនគណៈអភិបាលរាជធានីភ្នំពេញ និងអភិបាលនៃគណខណ្ឌ នៃរាជធានីភ្នំពេញ
- សេចក្តីសម្រេចលេខ ០៨០សសរ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ ស្តីពីការដាក់ឱ្យអនុវត្តប្លង់គោលប្រើប្រាស់ដីខណ្ឌមានជ័យ ចក្ខុវិស័យឆ្នាំ ២០៣៥

- សេចក្ដីជូនព័ត៌មាន ស្ដីពីការដាក់មណ្ឌលសុខភាពចាក់អង្រែ ជាមន្ទីរពេទ្យសម្រាប់ពិនិត្យ ថែទាំ និងព្យាបាលអ្នកជំងឺកូវីដ ១៩
- សារាចរស្ដីពី ការគ្រប់គ្រងគុណភាពនិងវិធានការត្រួតពិនិត្យគុណភាព សុវត្ថិភាព លើផលិតផលទំនិញ និងចំណីអាហារ ដែលមានប្រើសារជាតិគីមី

**សៀវភៅ**

- សៀវភៅនីតិនិតគរុបនីយវិទ្យា, បណ្ឌិត អ៊ុន សកក្កដា បោះពុម្ពឆ្នាំ (២០២៣-២០២៤)
- សៀវភៅ ការគ្រប់គ្រងរដ្ឋបាលខណ្ឌ ចុះខែកុម្ភៈ ឆ្នាំ២០២០
- បញ្ជីមូលដ្ឋានសុខាភិបាលដែលបានចុះកិច្ចព្រមព្រៀងជាមួយបេឡាជាតិរបបសន្តិសុខសង្គម សម្រាប់ផ្នែកហានិភ័យការងារ (ដកស្រង់ថ្ងៃទី ០១ ខែមិថុនា ឆ្នាំ២០២៤)
- សៀវភៅភូមិវិទ្យា សេដ្ឋកិច្ច និងមនុស្ស នៃប្រទេសកម្ពុជា ដែលរៀបរៀងដោយ គណៈកម្មការរៀបរៀង គឺលោក-លោកស្រី សាស្ត្រាចារ្យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំ២០១៣-២០១៤
- វចនានុក្រមសម្ដេចព្រះសង្ឃរាជ ជួន ណាត

**គេហទំព័រ**

- គេហទំព័រ សាលារាជធានីភ្នំពេញ https://phnompenh.gov.kh (ដកស្រង់ថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០២៤)
- គេហទំព័រ កោះសន្តិភាព https://kohsantepheapdaily.com.kh/article/723237.html (ដកស្រង់ថ្ងៃទី ០៥ ខែមិថុនា ឆ្នាំ២០២៤)
- គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ស្ដីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អាណត្តិទី៤ ឆ្នាំ២០២៤ (ដកស្រង់ថ្ងៃទី ០១ ខែមិថុនា ឆ្នាំ២០២៤) https://electresult.nec.gov.kh/Council/CandidateResult/2024
- គេហទំព័រ ព័ត៌មាន https://m.freshnewsasia.com/index.php/en/localnews/321896-2023-12-19-06-00-33.html (ដកស្រង់ថ្ងៃទី ១០ ខែមិថុនា ឆ្នាំ២០២៤)
- ទំព័រចុះផ្សាយក្នុង Phnom Penh Reporter https://www.ppreporter.com/article/376919 (ដកស្រង់ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២៤)
- គេហទំព័រ ក្រសួងសាធារណការ និង ដឹកជញ្ជូន https://www.mpwt.gov.kh/kh/press/8021 (ដកស្រង់ថ្ងៃទី ០១ ខែមិថុនា ឆ្នាំ២០២៤)
- ទំព័រចុះផ្សាយក្នុងថ្មីៗ https://thmeythmey.com/?page=detail&id=68581 (ដកស្រង់ថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២៤)
- https://business-cambodia.com/articles/special-bridge (ដកស្រង់ថ្ងៃទី ១៩ ខែមិថុនា ឆ្នាំ២០២៤)
- គេហទំព័រ អង្គភាពព័ត៌មាន និងប្រតិកម្មរហ័ស https://pressocm.gov.kh/archives/90226 ( ដកស្រង់ ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២៤)

- គេហទំព័រ វីអូអេ https://khmer.voanews.com/a/cambodia-kicks-off-the-fourth-provincial-election/7627293.html (ដកស្រង់ថ្ងៃទី៧ ខែឧសភា ឆ្នាំ២០២៤)
- គេហទំព័រ ក្រសួងមុខងារសាធារណៈ https://www.mcs.gov.kh/?p=7242 (ដកស្រង់ថ្ងៃទី ០៦ ខែមិថុនា ឆ្នាំ២០២៤)
- ភាគខាងត្បូងនៃរាជធានីភ្នំពេញ នឹងរីកមុខមាត់កាត់តែខ្លាំង ដោយគម្រោងអភិវឌ្ឍន៍ធំៗទាំងនេះ https://boreypenghuoth.com/blog/property-news-13-01-22/ (ដកស្រង់ថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២៤)
- សេចក្តីស្នើវិសោធនកម្មមាត្រា១៨ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ (ដកស្រង់ចេញពីក្រសួងព័ត៌មាន) https://www.information.gov.kh/articles/26180 (ដកស្រង់ថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២៤)
- តំបន់ផ្លូវ៦០ម៉ែត្រ នៅតែមានសក្តានុពល និងទាក់ទាញការអភិវឌ្ឍ https://propertyarea.asia/archives/144899# (ដកស្រង់ថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២៤)
- សេចក្តីណែនាំស្តីពី ការបែងចែកតួនាទី ភារកិច្ច និងរបៀបរបបធ្វើការងារជូនគណៈអភិបាលរាជធានីភ្នំពេញ និងគណៈអភិបាលខណ្ឌ នៃរាជធានីភ្នំពេញ ដកស្រងចេញពី https://policypulse.org/kh/policy-inventory/%E1%9E%80%E1%9F%92%E1%9E%9A%E1%9E%9F%E1%9E%BD%E1%9E%84%E1%9E%98%E1%9E%A0%E1%9E%B6%E1%9E%95%E1%9F%92%E1%9E%91%E1%9F%83/%E1%9E%9F%E1%9F%81%E1%9E%85%E1%9E%80%E1%9F%92%E1%9E%8F%E1%9E%B8%E1%9E%8E%E1%9F%82%E1%9E%93%E1%9E%B6%E1%9F%86%E1%9F%92%E1%9E%8F%E1%9E%B8%E1%9E%96%E1%9E%B8-%E1%9E%80%E1%9E%B6%E1%9E%9A%E1%9E%94/ (ដកស្រង់ថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២៤)
- ច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីវិសោធនកម្មច្បាប់នៃច្បាប់នេះ និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា រាជធានី ខេត្ត ក្រុង ខណ្ឌ និងច្បាប់ស្តីពីវិសោធនកម្មច្បាប់នេះ https://www.nec.gov.kh/khmer/content/3932 (ដកស្រង់ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២៤)
- តើមកទល់ពេលនេះរាជធានីភ្នំពេញមានស្ពានអាកាសចំនួនប៉ុន្មានហើយ? https://www.kampucheathmey.com/local-news/540822 (ដកស្រង់ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២៤)
- ដង់ស៊ីតេប្រជាជនកម្ពុជាកើនឡើងពី៧៥នាក់ទៅ៨៧នាក់ក្នុងមួយគីឡូម៉ែត្រក្រឡា https://www.information.gov.kh/articles/32255) (ដកស្រង់ថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២៤)
- ខណ្ឌមានជ័យ ជាខណ្ឌមួយក្នុងចំណោមខណ្ឌទាំង១៤ ត្រូវបានកំណត់ជាតំបន់អភិវឌ្ឍនៃរាជធានីភ្នំពេញ https://www.khmerhome.com/article/202204 (ដកស្រង់ថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២៤)

- សម្តេចធិបតី ហ៊ុន ម៉ាណែត តែងតាំងលោក សេង គន្ធ ជាអភិបាលខណ្ឌមានជ័យ https://m.freshnewsasia.com/index.php/en/localnews/321896-2023-12-19-06-00-33.html (ដកស្រង់ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២៤)
- រដ្ឋមន្ត្រីមហាផ្ទៃផ្ទេរភារកិច្ច និងតែងតាំងអភិបាលរងខណ្ឌនានាក្នុងរាជធានីភ្នំពេញជាង៤០នាក់ https://eacnews.asia/home/details/14849 (ដកស្រង់ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២៤)

# ឧបសម្ព័ន្ធរូបភាព




រូបភាពទី១៖ សាលាខណ្ឌមានជ័យ



រូបភាពទី២៖ សោភ័ណភាពលើស្ពានអាកាសមរតក



រូបភាពទី៣៖ អគារពាណិជ្ជកម្ម




រូបភាពទី៤៖ អរសាទរទិវាបរិស្ថានជាតិ និងទិវាបរិស្ថានអន្តរជាតិ



រូបភាពទី៥៖ ការដ្ឋានសាងសង់ស្ពានអាកាសភ្លោះ



រូបភាពទី៦៖ ហេដ្ឋារចនាសម្ព័ន្ធ



រូបភាពទី៧៖ ស្ថានីយបូមទឹកបឹងទំពន់




រូបភាពទី៨៖ ការដ្ឋានសាងសង់ស្ពានឆ្លងកាត់ទន្លេបាសាក់




រូបភាពទី៩៖ ការចុះពិនិត្យការស្ថាបនាប្រព័ន្ធបង្ហូរទឹក



រូបភាពទី១០៖ ចុះត្រួតរដ្ឋបាល ដើម្បីរៀបចំ សន្តិសុខ សណ្តាប់ធ្នាប់



រូបភាពទី១១៖ ចុះពិនិត្យដាក់ប្រព័ន្ធលូថ្មីរំដោះជំនន់ទឹក



រូបភាពទី១២៖ ការបាញ់ថ្នាំសម្លាប់មូស នៅតាមមូលដ្ឋាន

រូបភាពទី១៣៖ ប្លង់គោលប្រើប្រាស់ដីរាជធានីភ្នំពេញ ២០៣៥



រូបភាពទី១៤៖ ប្លង់គោលប្រើប្រាស់ដីខណ្ឌមានជ័យនៃរាជធានីភ្នំពេញ ចក្ខុវិស័យឆ្នាំ ២០៣៥



# ឧបសម្ព័ន្ធគតិយុត្តិ

## បញ្ជីឧបសម្ព័ន្ធ

**ឧបសម្ព័ន្ធទី១** ៖ អនុក្រឹត្យលេខ ៤២ អនក្រ.ប្រក ចុះថ្ងៃទី ០៣ ខែមេសា ឆ្នាំ ២០១៥ ស្តីពី នគរូបនីកម្ម រាជធានី ក្រុង និងទីប្រជុំជន

**ឧបសម្ព័ន្ធទី២** ៖ អនុក្រឹត្យលេខ១៨៣ អនក្រ.បក ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារ និង រចនាសម្ព័ន្ធរបស់ រដ្ឋបាលខណ្ឌនៃរាជធានីភ្នំពេញ

**ឧបសម្ព័ន្ធទី៣** ៖ អនុក្រឹត្យលេខ១៨១ អនក្រ.បក ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីការដាក់ឱ្យអនុវត្តប្លង់គោល ប្រើប្រាស់ដីរាជធានីភ្នំពេញ ចក្ខុវិស័យឆ្នាំ២០៣៥

**ឧបសម្ព័ន្ធទី៤** ៖ អនុក្រឹត្យលេខ ១៤៥ អនក្រ.បក ស្តីពីការបំបែកសង្កាត់ស្ទឹងមានជ័យ នៃខណ្ឌមានជ័យ រាជធានីភ្នំពេញ

# ឧបសម្ព័ន្ធទី១ ៖

ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខ: ៤៧ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពី

## នគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០៤/នស/៩៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១២/៤៦៣ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣១៤/៣៧៣ ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៤ ស្តីពីការកែសម្រួលមាត្រា២និងមាត្រា៥នៃព្រះរាជក្រឹត្យលេខ នស/រកត/០៥១២/៤៦៣ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ
- បានឃើញអនុក្រឹត្យលេខ១៤ អនក្រ.បក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការនិងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់



- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ៧២ អនក្រ.បក ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០០៩ ស្តីពីនីតិវិធីនៃការធ្វើផែនការប្រើប្រាស់ដីនៅឃុំ សង្កាត់
- បានឃើញអនុក្រឹត្យលេខ១៩៧ អនក្រ.បក ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០៩ ស្តីពីការគ្រប់គ្រងដីចំណីតាមបណ្តាញផ្លូវជាតិនិងផ្លូវរថភ្លើងនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ៧៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៣ ស្តីពីបែបបទនិងនីតិវិធីនៃការដាក់ឈ្មោះផ្លូវឬលេខផ្លូវនិងការកែប្រែឈ្មោះផ្លូវឬលេខផ្លូវ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

### សម្រេច

### ជំពូកទី១

### បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះមានគោលបំណងធានា៖

- គុណភាព ប្រសិទ្ធភាព ចីរភាព និងសមធម៌នៃនគរូបនីយកម្ម
- ការការពារសិទ្ធិនិងផលប្រយោជន៍សាធារណៈនិងឯកជន ក្នុងការអភិវឌ្ឍ ការអភិរក្ស និងការសាងសង់
- ការលើកកម្ពស់តម្លៃវប្បធម៌ ការអភិវឌ្ឍបៃតង និងរួមចំណែកកាត់បន្ថយការប្រែប្រួលអាកាសធាតុសកល ព្រមទាំងបង្កើនការបង្ការនិងការទប់ស្កាត់គ្រោះមហន្តរាយ
- ការយកចិត្តទុកដាក់ដល់សុវត្ថិភាព សុខុមាលភាព និងភាពងាយស្រួល សម្រាប់មនុស្សទាំងអស់គ្នា រួមទាំងជនពិការ ជនចាស់ជរា និងកុមារ។

**មាត្រា២ .-**

អនុក្រឹត្យនេះមានគោលដៅកំណត់អំពីនគរូបនីយកម្មរាជធានី ក្រុង និងទីប្រជុំជន នៅព្រះរាជាណាចក្រកម្ពុជា ឱ្យមាន៖

- មុខងារសមស្របសម្រាប់ការស្នាក់នៅ ការផ្តល់ការងារ ការសិក្សា កន្លែងលំហែកម្សាន្ត និងការធ្វើចរាចរណ៍ ប្រកបដោយសុខភាព សោភណភាព សុវត្ថិភាព សណ្តាប់ធ្នាប់ និងភាពងាយស្រួល
- ការលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គម កិច្ចការពារបរិស្ថាន ការពារជាតិ សន្តិសុខសៀង និងការថែរក្សា សម្បត្តិវប្បធម៌
- ការលើកកម្ពស់គុណភាពនិងប្រសិទ្ធភាពនៃការកែលម្អ ការអភិវឌ្ឍ និងការការពារហេដ្ឋារចនាសម្ព័ន្ធសាធារណៈរាជធានី ក្រុង និងទីប្រជុំជន
- តុល្យភាពនៃការអភិវឌ្ឍនិងការអភិរក្ស ព្រមទាំងទំនាក់ទំនងរវាងទីក្រុងនិងជនបទ ដោយផ្អែកលើ[illegible]ភូមិសាស្ត្រនិងលក្ខណៈពិសេសនៃតំបន់នីមួយៗ
- ការតម្រង់ទិសច្បាស់លាស់ដែលអាចដឹងមុនបាននូវការអភិវឌ្ឍនៅរាជធានី ក្រុង និងទីប្រជុំជន។

រយៈពេល៣០(សាមសិប)ថ្ងៃខាងលើនេះអាចត្រូវបានបន្ថែមរយៈពេលយ៉ាងយូរ៣០(សាមសិប)ថ្ងៃទៀតនៃថ្ងៃធ្វើការឬស្របតាមទំហំការងារជាក់ស្តែង

- គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត ត្រូវពិនិត្យ ផ្តល់ការឯកភាព និងធ្វើសំណើសុំការសម្រេចចុងក្រោយពីគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ ក្នុងរយៈពេលយ៉ាងយូរ៦០(ហុកសិប)ថ្ងៃនៃថ្ងៃធ្វើការ។ ក្នុងករណីដែលតម្រូវឲ្យមានការកែសម្រួលសេចក្តីព្រាងចុងក្រោយរយៈពេល៦០(ហុកសិប)ថ្ងៃខាងលើនេះ អាចត្រូវបានបន្ថែមរយៈពេលស្របតាមទំហំការងារជាក់ស្តែង ដែលត្រូវបានកំណត់ដោយគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ។

ប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីទីប្រជុំជន ត្រូវសម្រេចដាក់ឲ្យប្រើប្រាស់ដោយគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ។

**មាត្រា១៧ .-**

ការរៀបចំប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីទីក្រុង ត្រូវគោរពតាមគោលការណ៍ដូចមានចែងក្នុងមាត្រា៩នៃអនុក្រឹត្យនេះ។

ប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីទីក្រុង ត្រូវធ្វើបច្ចុប្បន្នកម្មដោយត្រូវកត់ត្រាទុកជាប្រចាំនូវស្ថានភាពវិវត្តរបស់ទីក្រុង ដើម្បីងាយស្រួលក្នុងការរៀបចំជាសេចក្តីព្រាងសំណើប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដី សម្រាប់ស្នើសុំកែសម្រួលសរុបក្នុងរយៈពេល៥(ប្រាំ)ឆ្នាំម្តង។

ការកែសម្រួលប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីទីក្រុង ត្រូវអនុវត្តតាមនីតិវិធីដែលមានលក្ខណៈដូចដំណើរការធ្វើប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីថ្មីនៅទីក្រុងដែរ។

ការកែសម្រួលប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីនៅទីក្រុងមុនពេលកំណត់ អាចប្រព្រឹត្តទៅបានក្នុងករណីដែលមានតម្រូវការចាំបាច់សម្រាប់បម្រើផលប្រយោជន៍សាធារណៈឬផលប្រយោជន៍ជាតិ។ ប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីដែលបានកែសម្រួលរួច ត្រូវស្នើសុំការសម្រេចដាក់ឲ្យប្រើប្រាស់ជាផ្លូវការតាមនីតិវិធីដូចការសម្រេចប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីថ្មីដែរ។

ក្នុងករណីដែលទីប្រជុំជនមានទីតាំងស្ថិតនៅលើតំបន់ប្រសព្វរវាងរដ្ឋបាលថ្នាក់ក្រោមជាតិពីរឬច្រើន រដ្ឋបាលថ្នាក់ក្រោមជាតិទាំងនោះត្រូវសហការគ្នារៀបចំប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីនៅតំបន់នោះ។

**មាត្រា១៨ .-**

សេចក្តីណែនាំបច្ចេកទេសនិងនីតិវិធីលម្អិតនៃការរៀបចំប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីទីក្រុងនិងប្លង់លម្អិតនគរូបនីយកម្ម ព្រមទាំងវិធីដោះស្រាយការតវ៉ាផ្សេងៗ ត្រូវកំណត់ដោយគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ។

## ជំពូកទី៥
## បទប្បញ្ញត្តិនៃការប្រើប្រាស់ដី

**មាត្រា១៩ .-**

ប្រព័ន្ធផែនការប្រើប្រាស់ដីនៅទីក្រុងនៃព្រះរាជាណាចក្រកម្ពុជាត្រូវបានបែងចែកជា២ប្រភេទ រួមមាន៖

១- ប្រភេទដីអាចសាងសង់បាន

២- ប្រភេទដីកម្រិតការសាងសង់។



ថ្ងៃខាងលើនេះ អាចត្រូវបានបន្ថែមរយៈពេល ស្របតាមទំហំការងារជាក់ស្តែងដែលត្រូវបានកំណត់ដោយគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ។

**ត្រា១៥ .-**

ចំពោះនីតិវិធីនិងដំណើរការនៃការរៀបចំប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីថ្នាក់ក្រុងនិងប្លង់លប្រើប្រាស់ដីថ្នាក់ខណ្ឌ គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវអនុវត្តដូចងក្រោម៖

- ប្រមូល សម្រង់ ចងក្រង និងវិភាគទិន្នន័យ
- រៀបចំចក្ខុវិស័យ យុទ្ធសាស្ត្រ គំនូសប្លង់ ផែនការសកម្មភាពនិងសេចក្តីណែនាំអនុវត្ត ការគ្រប់គ្រងការអភិវឌ្ឍ ការអភិរក្ស និងការសាងសង់ ព្រមទាំងរបាយការណ៍បច្ចេកទេស
- រៀបចំសិក្ខាសាលាពិគ្រោះយោបល់ ដោយមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ
- បិទផ្សាយជាសាធារណៈនូវសេចក្តីព្រាងចុងក្រោយនៃការរៀបចំប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដីរយៈពេល៣០(សាមសិប)ថ្ងៃ ដើម្បីទទួលមតិយោបល់សាធារណៈឬការតវ៉ាផ្សេងៗ
- ធ្វើការបូកសរុបមតិសាធារណៈ ក្នុងរយៈពេលមិនលើសពី៣០(សាមសិប)ថ្ងៃនៃថ្ងៃធ្វើការ ព្រមទាំងផ្តល់យោបល់ ដើម្បីផ្ញើជូនទៅគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត ពិនិត្យនិងផ្តល់ការឯកភាព។ ក្នុងករណីដែលតម្រូវឲ្យមានការកែសម្រួលសេចក្តីព្រាងចុងក្រោយរយៈពេល៣០(សាមសិប)ថ្ងៃខាងលើនេះ អាចត្រូវបានបន្ថែមរយៈពេលយ៉ាងយូរ៣០(សាមសិប)ថ្ងៃទៀតនៃថ្ងៃធ្វើការឬស្របតាមទំហំការងារជាក់ស្តែង
- គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត ត្រូវពិនិត្យ ផ្តល់ការឯកភាព និងធ្វើសំណើសុំការសម្រេចចុងក្រោយពីគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ ក្នុងរយៈពេលយ៉ាងយូរ៦០(ហុកសិប)ថ្ងៃនៃថ្ងៃធ្វើការ។ ក្នុងករណីដែលតម្រូវឲ្យមានការកែសម្រួលសេចក្តីព្រាងចុងក្រោយរយៈពេល៦០(ហុកសិប)ថ្ងៃខាងលើនេះ អាចត្រូវបានបន្ថែមរយៈពេលស្របតាមទំហំការងារជាក់ស្តែង ដែលត្រូវបានកំណត់ដោយគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ។

**ត្រា១៦ .-**

ចំពោះនីតិវិធីនិងដំណើរការនៃការរៀបចំប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីទីប្រជុំជន គណៈកម្មា-រៀបចំដែនដីនិងនគរូបនីយកម្ម ថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវអនុវត្ត ដូចខាងក្រោម៖

- ប្រមូល សម្រង់ ចងក្រង និងវិភាគទិន្នន័យ
- រៀបចំចក្ខុវិស័យ យុទ្ធសាស្ត្រ គំនូសប្លង់ ផែនការសកម្មភាពនិងសេចក្តីណែនាំអនុវត្ត ការគ្រប់គ្រងការអភិវឌ្ឍ ការអភិរក្ស និងការសាងសង់ ព្រមទាំងរបាយការណ៍បច្ចេកទេស
- រៀបចំសិក្ខាសាលាពិគ្រោះយោបល់ ដោយមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ
- បិទផ្សាយជាសាធារណៈនូវសេចក្តីព្រាងចុងក្រោយនៃការរៀបចំប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដីរយៈពេល៣០(សាមសិប)ថ្ងៃ ដើម្បីទទួលមតិយោបល់សាធារណៈឬការតវ៉ាផ្សេងៗ
- ធ្វើការបូកសរុបមតិសាធារណៈក្នុងរយៈពេលមិនលើសពី៣០(សាមសិប)ថ្ងៃនៃថ្ងៃធ្វើការ ព្រមទាំងផ្តល់យោបល់ ដើម្បីផ្ញើជូនទៅគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្ម ថ្នាក់រាជធានី ខេត្ត ពិនិត្យ និងផ្តល់ការឯកភាព។ ក្នុងករណីដែលតម្រូវឲ្យមានការកែសម្រួលសេចក្តីព្រាងចុងក្រោយរយៈ

# ឧបសម្ព័ន្ធទី២ ៖

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:..២៤៣....អនក្រ.បក

**អនុក្រឹត្យ**

**ស្ដីពី**

**មុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលខណ្ឌនៃរាជធានីភ្នំពេញ**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៥ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្ដីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ២១៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្ដីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានីភ្នំពេញ និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៩ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៩ ស្ដីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

ឧបសម្ព័ន្ធទី១៖ អង្គការលេខរបស់រដ្ឋបាលខណ្ឌ

ភ្ជាប់នឹងអនុក្រឹត្យលេខ១៨៣ អនក្រ.បក ចុះថ្ងៃទី ៤ ខែ ធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរបស់រដ្ឋបាលខណ្ឌនៃរាជធានីភ្នំពេញ



# ឧបសម្ព័ន្ធទី៣ ៖

## អនុក្រឹត្យលេខ១៨១ អនក្រ.បក ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីការដាក់ឱ្យអនុវត្តប្លង់គោលប្រើប្រាស់ដីរាជធានីភ្នំពេញ ចក្ខុវិស័យឆ្នាំ២០៣៥


ឆ្នាំទី១៥ លេខ ៩៥ សប្តាហ៍ទី ៤ ថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០១៥ រាជកិច្ច ទំព័រ ១០០៩៤

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៨១ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការដាក់ឱ្យអនុវត្តប្លង់គោលប្រើប្រាស់ដីរាជធានីភ្នំពេញ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

សម្រេច

មាត្រា១ ...

មាត្រា២ ...

មាត្រា៣ ...

មាត្រា៤ ...

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

# ឧបសម្ព័ន្ធទី៤ ៖
# អនុក្រឹត្យលេខ ១៤៥ អនក្រ.បក ស្តីពីការបំបែកសង្កាត់ស្ទឹងមានជ័យ នៃខណ្ឌមានជ័យ រាជធានីភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៤៥ អនក្រ.បក

**អនុក្រឹត្យ**

**ស្តីពី**

**ការបំបែកសង្កាត់ស្ទឹងមានជ័យ នៃខណ្ឌមានជ័យ រាជធានីភ្នំពេញ**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៥ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សម្រេច**

មាត្រា ១.-

ត្រូវបានបំបែកសង្កាត់ស្ទឹងមានជ័យ នៃខណ្ឌមានជ័យ រាជធានីភ្នំពេញ ជា០៣ គឺ **សង្កាត់ស្ទឹងមានជ័យទី១ សង្កាត់ស្ទឹងមានជ័យទី២ និងសង្កាត់ស្ទឹងមានជ័យទី៣** ដូចខាងក្រោម៖



- សង្កាត់ស្ទឹងមានជ័យទី១ មានភូមិចំនួន០៨ គឺ ភូមិមានជ័យ ភូមិមានជ័យ១ ភូមិមានជ័យ២ ភូមិថ្មី ភូមិត្រា ភូមិត្រា១ ភូមិត្រា២ និងភូមិត្រា៣។
- សង្កាត់ស្ទឹងមានជ័យទី២ មានភូមិចំនួន០៨ គឺ ភូមិត្នោត ភូមិដំណាក់ធំ ភូមិដំណាក់ធំ១ ភូមិដំណាក់ធំ៤ ភូមិឫស្សី ភូមិឫស្សី៣ ភូមិព្រែកតាល់ និងភូមិព្រែកតាល់១។
- សង្កាត់ស្ទឹងមានជ័យទី៣ មានភូមិចំនួន០៦ គឺ ភូមិត្រា៤ ភូមិឫស្សី១ ភូមិឫស្សី២ ភូមិដំណាក់ធំ២ ភូមិដំណាក់ធំ៣ និងភូមិដំណាក់ធំ៥។

ព្រំប្រទល់រដ្ឋបាលសង្កាត់ស្ទឹងមានជ័យទី១ សង្កាត់ស្ទឹងមានជ័យទី២ និងសង្កាត់ស្ទឹងមានជ័យទី៣ ត្រូវបានកំណត់ដូចមានក្នុងផែនទីជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

មាត្រា២.-

ត្រូវបានផ្ទេរទីតាំងសាលាសង្កាត់ស្ទឹងមានជ័យដែលស្ថិតនៅក្នុងភូមិថ្មី ទៅជាសាលាសង្កាត់ស្ទឹងមានជ័យទី១។
ទីតាំងសាលាសង្កាត់ស្ទឹងមានជ័យទី២ ត្រូវស្ថិតនៅក្នុងភូមិដំណាក់ធំ។
ទីតាំងសាលាសង្កាត់ស្ទឹងមានជ័យទី៣ ត្រូវស្ថិតនៅក្នុងភូមិដំណាក់ធំ២។

មាត្រា៣.-

ការរៀបចំរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលសង្កាត់ស្ទឹងមានជ័យទី១ សង្កាត់ស្ទឹងមានជ័យទី២ និងសង្កាត់ស្ទឹងមានជ័យទី៣ ត្រូវអនុលោមទៅតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់។

មាត្រា៤.-

ការបំបែកសង្កាត់ស្ទឹងមានជ័យ ត្រូវចូលជាធរមានសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៤ ស្របតាមខ្លឹមសារមាត្រា១៨ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់។

ក្រុមប្រឹក្សាសង្កាត់ស្ទឹងមានជ័យត្រូវបន្តគ្រប់គ្រងរដ្ឋបាលសង្កាត់ស្ទឹងមានជ័យ រហូតដល់មានក្រុមប្រឹក្សាសង្កាត់ស្ទឹងមានជ័យទី១ ក្រុមប្រឹក្សាសង្កាត់ស្ទឹងមានជ័យទី២ និងក្រុមប្រឹក្សាសង្កាត់ស្ទឹងមានជ័យទី៣ មកជំនួស។

មាត្រា៥.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា៦.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ក្រុមប្រឹក្សារាជធានីភ្នំពេញ គណៈអភិបាលរាជធានីភ្នំពេញ ក្រុមប្រឹក្សាខណ្ឌមានជ័យ គណៈអភិបាលខណ្ឌមានជ័យ ក្រុមប្រឹក្សាសង្កាត់ស្ទឹងមានជ័យ ក្រុមប្រឹក្សាសង្កាត់ស្ទឹងមានជ័យទី១ ក្រុមប្រឹក្សាសង្កាត់ស្ទឹងមានជ័យទី២ និងក្រុមប្រឹក្សាសង្កាត់ស្ទឹងមានជ័យទី៣ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៦
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ